# ច្បាប់ផ្សេងៗ



បោះពុម្ពផ្សាយជាធម្មទាន
ដោយ
អង្គការសន្តិស្ម័គ្រចិត្តជប៉ុន ប្រចាំនៅកម្ពុជា ( អេស វី អេ )
ភ្នំពេញ
ព.ស. ២៥៤៩ - គ.ស. ២០០៥

# ច្បាប់ផ្សេងៗ

បោះពុម្ពឡើងវិញលើកទី២
ចំនួន ១០,០០០ ច្បាប់
ដើម្បីចែកជាធម្មទាន

ISBN-10: 99950-56-02-X

ISBN-13: 978-99950-56-02-5

អង្គការសន្និស្ស័គ្រចិត្តជប៉ុន ប្រចាំនៅកម្ពុជា (អេស វី អេ)

ភ្នំពេញ

ព.ស. ២៥៤៩ - គ.ស. ២០០៥

## និវាទនកថា

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើង ដោយអង្គការសន្តិស្ម័គ្រចិត្តជប៉ុន ប្រចាំនៅកម្ពុជា (SVA) ក្រោមការឧបត្ថម្ភថវិការបស់អង្គការ រិស្សូ កូសី-កៃ (RKK) នៃប្រទេសជប៉ុន ។

យើងខ្ញុំអធិដ្ឋាន សូមអោយសៀវភៅនេះ បានជាវិភាគទាន ដល់ការរក្សាមិត្តភាព ជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនា និងសម្បត្តិវប្បធម៌របស់ប្រជាជនកម្ពុជា ។

## ACKNOWLEDGEMENT

This book has been printed by the **Shanti Volunteer** Association (SVA) in Cambodia and financially supported by the **Rissho KoseiKai** (RKK) of Japan.

We pray that this book would contribute to the friendship with Cambodia people and their religious and cultural preservation.

# **បុព្វកថា**

សៀវភៅ “**ច្បាប់ផ្សេងៗ**” នេះបោះពុម្ពផ្សាយជាធម្មទាន ដោយអង្គការសន្និស្ព័គ្រជប៉ុនប្រចាំនៅកម្ពុជា (SVA) ក្រោមការឧបត្ថម្ភថវិការបស់អង្គការ រីស្សូកូសី-កៃ (RKK) នៃប្រទេសជប៉ុន ។

ការបោះពុម្ពផ្សាយលោកនេះ មានចំនួន ១០,000ច្បាប់ ដោយថតចម្លងតាមច្បាប់ដើម ដែលបោះពុម្ពផ្សាយដោយសមាគមសម្តេច ជួន ណាត ច្បាប់បោះពុម្ពលើកទី១ ក្នុងគ.ស.១៩៧៤ ដើម្បីចែកប្រគេនទៅគ្រប់វត្តអារាម ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយសារយើងខ្ញុំយល់ថា “**ច្បាប់ផ្សេងៗ**” នេះមានដើមកំណើតចេញមកពីសាស្ត្រាស្លឹករឹតដែលអ្នកប្រាជ្ញរាជបណ្ឌិតខ្មែរបុរាណ លោកបានចារនិងតម្កល់ទុកក្នុងវត្តអារាមនៅទូទាំងប្រទេស ។ ចំណេរតមក អ្នកប្រាជ្ញជំនាន់ក្រោយបានចម្លងច្បាប់ទាំងនោះបោះពុម្ពជាសៀវភៅ ហើយយកទៅប្រើនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ដោយភាគច្រើន ។ ច្បាប់ទាំងឡាយនេះពុំបានវិលទៅរកកន្លែងដើមគឺ ហោត្រ័យ នៅតាមវត្តអារាមវិញទេ ហើយប្រសិនបើមាន ក៏មានដោយតិចតួច ។ អាស្រ័យហេតុនេះ កូនចៅខ្មែរនៅតាមជនបទស្រែចំការ ដែលចូលទៅបួសរៀនក្នុងវត្តអារាមជំនាន់ក្រោយៗមក ពុំសូវបានរៀនច្បាប់ទាំងនេះទេ ។

“**ច្បាប់ផ្សេងៗ**” គឺជាកម្រងសីលធម៌របស់ជាតិខ្មែរ ដែលពលរដ្ឋម្នាក់ៗគប្បីប្រតិបត្តិតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួននៅក្នុងទំនាក់ទំនងសង្គម រាប់ចាប់តាំងពីក្នុងឋានៈជាសមាជិកម្នាក់ក្នុងគ្រួសារដ៏តូចមួយឡើងទៅ ដើម្បីសេចក្តីថ្លៃថ្នូររបស់ខ្លួនម្នាក់ៗផង ទាំងដើម្បីសេចក្តីចម្រើនរុងរឿងរបស់ជាតិមាតុភូមិផង ។

យើងខ្ញុំយល់ឃើញថា ទោះបីបច្ចុប្បន្ននេះ ទំនាក់ទំនងសង្គមបានឈានទៅដល់សម័យសកលោបនីយកម្មនៃវប្បធម៌ និងសង្គមក៏ដោយ ក៏ច្បាប់ដែលជាបេតិកភណ្ឌវប្បធម៌និងជាគតិបណ្ឌិត ដែលអ្នកប្រាជ្ញខ្មែរបុរាណបានបន្សល់ទុកជាកេរនេះ នៅតែមានតម្លៃអាចប្រើប្រាស់បាននៅក្នុងសម័យទំនើបនេះ ព្រោះថាសីលធម៌នាំមកនូវសេចក្តីថ្លៃថ្នូរ និង

គុណធម៌សម្រាប់មនុស្ស ដែលរស់នៅក្នុងសង្គមប្រកបដោយការរីកចម្រើនខាងវប្បធម៌ និងមានអរិយធម៌រុងរឿង ។

ការបាត់បង់ក្បួនខ្នាតជាច្បាប់សីលធម៌នេះ ក៏ជាហេតុមួយនាំទៅរកការស្រុតចុះនៃតម្លៃសីលធម៌របស់ជាតិ និងបន្សល់ទុកនូវផលវិបាកយ៉ាងធ្ងន់ធ្ងរខាងការអប់រំនាបច្ចុប្បន្នកាល និងនៅអនាគត ។

យើងខ្ញុំយល់ឃើញថា ការបោះពុម្ពផ្សាយនូវសៀវភៅ **"ច្បាប់ផ្សេងៗ"** នេះគឺជាការរួមចំណែកមួយផ្នែកដល់ការស្តារឡើងវិញនូវតម្លៃវប្បធម៌ និងសីលធម៌ខ្មែរ ដែលភាគច្រើនមានដើមកំណើតចេញពីវត្តអារាមនោះ ឱ្យទទួលនូវការរីកចម្រើនឡើងវិញដូចពីសម័យបុរាណកាល ។

យើងខ្ញុំសូមឧទ្ទិសផលានិសង្ស ដែលកើតឡើងដោយសាធម្មទាននាពេលនេះជូនចំពោះវិញ្ញាណក្ខន្ធអស់លោកអ្នកប្រាជ្ញរាជបណ្ឌិត ដែលជាអ្នកករីនិពន្ធនៃច្បាប់ទាំងឡាយនោះ សូមលោកបានទៅសោយសុខនៅសុគតិភព កុំបីក្លាយជាប្រការដទៃឡើយ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះឯកឧត្តម ឃុន ហាំងទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និងឯកឧត្តម ឈន អៀងរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ដែលបានជួយជ្រោមជ្រែង និងលើកទឹកចិត្តដល់ការបោះពុម្ពផ្សាយនូវច្បាប់ទាំងឡាយនាពេលនេះ និងសូមថ្លែងនូវអំណរគុណជាពិសេសចំពោះអង្គការ រីស្សូ កូសី-កៃ នៃប្រទេសជប៉ុន ដែលបានឧបត្ថម្ភថវិកាសម្រាប់ចំណាយក្នុងការបោះពុម្ពឡើងវិញនូវច្បាប់ផ្សេងៗនាពេលនេះ ។

យើងខ្ញុំសូមអភ័យទោស និងសូមមេត្តាជួយកែតម្រូវចំពោះការខុសឆ្គងទាំងឡាយ ដែលអាចកើតមានជាយថាហេតុក្នុងការបោះពុម្ពផ្សាយលើកនេះ ។

**ឃី ធន់**

ទីប្រឹក្សាវប្បធម៌

អង្គការសន្តិស្ម័គ្រចិត្តកម្ពុជា

# ច្បាប់ផ្សេង ៗ

ចម្លងពីសាស្ត្រាស្លឹករឹត

បោះពុម្ពលើកទី ១

ការផ្សាយរបស់

**សមាគម សម្តេច ជួន ណាត**

លេខ ៩៨ ផ្លូវ តេជោដាំឌិន

ភ្នំពេញ

ព.ស ២៥១៨

គ.ស ១៩៧៤

# សន្លឹកនេះទំនេរ

# អារម្ភកថា

គោលបំណង ដែលចែងយ៉ាងច្បាស់ ក្នុងលក្ខន្តិកៈរបស់ខ្លួន ត្រង់មាត្រា វគ្គទី១ សមាគម សម្ដេច ជួន ណាត មានមុខងារខាងផ្សាយស្នាដៃរបស់ខ្មែរពិតប្រាកដ មានស្នាដៃខាងសិល្បៈ និងអក្សរសិល្ប៍ជាដើម ដើម្បីតម្រូវតាមនាមរបស់សមាគម គឺ សម្ដេច ជួន ណាត ដែល ជាអ្នកប្រាជ្ញធំរបស់ខ្មែរសុទ្ធសាធ ។

កាលពីឆ្នាំមុនៗ យើងមានបោះពុម្ពសៀវភៅខ្លះៗ ហើយដែរ តែច្រើនជាវប្បធម៌ទូទៅ ទើបតែមកដល់ពេលប្រជុំ នាថ្ងៃពុធ ទី១៧ កក្កដា ១៩៧៤ កន្លងទៅនេះ គណៈកម្មាធិការនាយក ក៏បានសម្រេច មូលមតិគ្នាថាៈ ត្រូវចាត់ការបោះពុម្ពផ្សាយស្នាដៃអក្សរសិល្ប៍បុរាណខ្មែរយើង ឱ្យបានច្រើនបំផុត តាមមធ្យោបាយដែលអាចធ្វើបាន ដើម្បី ក្នុងគោលបំណងជួយផ្សព្វផ្សាយស្នាដៃអ្នកប្រាជ្ញខ្មែរ និងជួយប្រមូលឯកសារ ជូនអ្នកសិក្សាទូទៅ ឱ្យបានសាយភាយពេញផ្ទៃប្រទេស និង ឆ្លងទៅកាន់ប្រទេសក្រៅទៀតផង ។ ដោយសារសេចក្ដីសម្រេចនេះហើយ ដែលកើតបានជារូបរាងសៀវភៅនេះឡើង សម្រាប់ជាគូដៃដល់អ្នកសិក្សា និងជាជំនួយខាងអង្គការបោះផ្សាយឯទៀតៗ ក្នុងប្រទេសយើង ។

បន្ទាប់ៗទៅទៀត សមាគម សម្ដេច ជួន ណាត ខំប្រឹងស្រាវជ្រាវរកស្នាដៃបុរាណដ៏ល្អៗ មកបោះផ្សាយបន្តទៅទៀត ទាំងផ្នែកអក្សរសិល្ប៍ ទាំងផ្នែកវប្បធម៌ទូទៅ ឱ្យតែសម្គាល់ថា ជាការមានប្រយោជន៍សម្រាប់វប្បធម៌ជាតិ និងជាកេរ្ដិ៍អក្សរសិល្បខ្មែរសុទ្ធសាធ ។

សមាគម សូមថ្លែងអំណរគុណ យ៉ាងស្មោះ ទុកជាមុន ចំពោះអស់លោក-អ្នក ដែលជួយឧបត្ថម្ភដល់ការផ្សាយ របស់សមាគម សម្ដេច **ជួន-ណាត** ឱ្យកាន់តែបានរីកបម្រើនឡើង ។

*ភ្នំពេញ, ខែសីហា ១៩៧៤*

**សមាគម សម្ដេច ជួន-ណាត**

# សេចក្ដីសង្កេតចំពោះច្បាប់ផ្សេងៗ

ច្បាប់ដំបូន្មាន ដែលអ្នកប្រាជ្ញបុរាណ ចងក្រងទុកមក សម្រាប់ប្រៀនប្រដៅ ពត់ហាត់កាយ វាចា ចិត្ត របស់កុលបុត្ត-កុលធីតា មានច្រើនច្បាប់ណាស់ ដែលគេប្រមូលផ្ដុំគ្នាមក ឱ្យឈ្មោះសរុបមួយ ថា ៖ "ច្បាប់ផ្សេងៗ" ។ ដើម្បីយល់ពីផលប្រយោជន៍ និងទ្រង់ទ្រាយច្បាប់ទាំងនេះឱ្យច្បាស់លាស់ គប្បីធ្វើការសង្កេត ដូចតទៅនេះ ៖

## ១-ប្រភពដើម៖

អត្ថបទច្បាប់ទាំងនេះ សុទ្ធតែគ្មានចុះកាលបរិច្ឆេទ ឱ្យយើងដឹងច្បាស់ថា កើតនៅក្នុងឆ្នាំណាប្រាកដប្រជាទេ តែអ្នកសិក្សាអាចសម្គាល់បានថា ជាអត្ថបទកើតនៅក្នុងសម័យឧត្តុង្គ គឺរវាងសតវត្សទី ១៧ - ១៨ និង ១៩ ប៉ុណ្ណោះ ដោយសារគេប្រមាណ តាមគោលគំនិត ពាក្យសម្ដី និង ទំនៀមទម្លាប់ ដែលមានចែងក្នុងអត្ថបទទាំងនោះ ។

ក្នុងច្បាប់ផ្សេងៗ គេរកឃើញកំណើតដើមនៃគំនិត តែងតែដកស្រង់បានពីប្រភព ៣ គឺ៖

ក- មួយភាគធំ អ្នកនិពន្ធដកស្រង់គំនិតអំពីដំបូន្មានរបស់ព្រះពុទ្ធ (ពុទ្ធឱវាទ) ព្រោះអ្នកនិពន្ធ ច្រើនជាអ្នកបានរៀនសូត្រជ្រៅជ្រះ ខាងពុទ្ធ-សាសនា ដ៏ជាវិជ្ជាជាន់ខ្ពស់ ក្នុងកិច្ចសិក្សារបស់ខ្មែរយើង សម័យនោះ ។

១- អ្នកនិពន្ធស្រង់គំនិតនិងពាក្យសម្ដី ដែលជាទំនឹមទំនៀមបុរាណ ហើយដែលអ្នកស្រុកចាំមាត់តៗគ្នា មកអធិប្បាយ ។

គ- អ្នកនិពន្ធដកស្រង់ ការពិសោធន៍ផ្ទាល់ ដែលគេបានជួបប្រទះក្នុងជីវភាពរាល់ថ្ងៃ តែងមានដំណើរត្រូវខ្លះ ខុសខ្លះ ដែលអ្នកនិពន្ធនិយមធ្វើការសង្កេត ហើយចងចាំទុកយកមកប្រៀនប្រដៅកូន ចៅតៗមកទៀត ។

អាស្រ័យដោយប្រភពទាំងបីនេះ ទើបន័យក្នុង ច្បាប់ផ្សេងៗ មានលាយការហួសសម័យនិយមខ្លះ ខាងផ្នែកទំនៀមរស់នៅ ប៉ុន្តែ ត្រូវជានិច្ច ខាងគោលការណ៍អប់រំ ឬ គោលសីលធម៌ ។

**២-ន័យខ្លឹមសារ**

ច្បាប់ផ្សេងៗ ពត់ហាត់មនុស្សឱ្យមានចរិយាល្អ ដើម្បីរស់នៅសុខសាន្តក្នុងសង្គម ដែលច្បាប់ទាំងនេះមាន អប់រំតាមន័យផ្សេងគ្នា ដូចជា ៖

ក- អប់រំឱ្យមានសណ្ដាប់ធ្នាប់ត្រឹមត្រូវ តាមគន្លងប្រពៃណីជាតិដែលជាកេរអរិយធម៌យូរអង្វែងហើយ ។

១- ដឹកនាំឱ្យមានប្រាជ្ញាវាងវៃ កាលបើឮ ឬបើឃើញ បញ្ហាអ្វីមួយកើតឡើងភ្លាម ក៏អាចយកប្រាជ្ញានោះទៅដោះស្រាយបានភ្លាមៗ គ្រប់ពេលដែលគេជួបប្រទះ ក្នុងមុខរបរ ឬក្នុងការងារប្រចាំថ្ងៃ ។

គ- បង្កើនសណ្ដាប់ល្អ ក្នុងរបបរស់នៅតាមគន្លងច្បាប់គ្រប់គ្រងប្រទេស ព្រមទាំងជាគតិដាស់តឿនក្រើនរំលឹកដល់អ្នកក្រោយៗទៀតផង ។

រួមសេចក្ដីទៅ **ច្បាប់ផ្សេងៗ** ជាកម្រងចំណេះប្រាជ្ញាមនុស្ស ក្នុងសម័យនីមួយៗ ដែលជាមធ្យោបាយ ជួយដោះស្រាយបញ្ហាវាយរងក្នុងសង្គម និងរៀបចំគ្រួសារ ឬសង្គមជាតិ ឱ្យសុខសាន្តល្អ ។

**៣- កាលបរិច្ឆេទ និងអ្នកនិពន្ធ**

ច្បាប់ផ្សេងៗ ទាំងអស់ មិនសូវមានចុះកាលបរិច្ឆេទ ឱ្យយើងដឹងច្បាស់ទេ ឯអ្នកនិពន្ធ ក៏មិនសូវបានស្គាល់នាមដែរ ខ្លះគ្រាន់តែដាក់ ប្រាប់ងារ ឬ ប្រាប់មុខរបរ ដូចជាថា "អរិយសត្ថា" ឬថា "សេដ្ឋី" ជាអ្នកផ្ដើមសរសេរឡើង ។ មានតែច្បាប់ប្រុស ច្បាប់ស្រីទេ ដែលអ្នកនិពន្ធប្រាប់នាមថា "ម៉ឺនមៃ" ជាអ្នកតែង តែគ្មានបញ្ជាក់ថា លោកជាមន្ត្រីអ្វី? នៅស្រុកណា? តែងពីឆ្នាំណាឡើយ ។

*ច្បាប់ត្រីនេតិ* *ច្បាប់កូនចៅ* *និងច្បាប់វិធូរបណ្ឌិត* ពិតជាកើតពីអ្នកប្រាជ្ញាធំជុំណាស់ ព្រោះមានខ្លឹមសារពិសេស ប្រកបដោយអត្ថន័យជ្រាលជ្រៅទូលំទូលាយ ។ *ច្បាប់អរិយសត្ថា* *ច្បាប់ក្រម* កើតពីព្រះសង្ឃឧបជ្ឈាយាចារ្យ ដែលប្រៀនប្រដៅសិស្ស *ច្បាប់ពាក្យចាស់* *ច្បាប់ហៃមហាជន* កើតពីចាស់ៗព្រឹទ្ធព្រេង ប្រដៅក្មេងៗ តាមតម្រាយបុរាណ, *ច្បាប់កេរកាល* កើតពីអ្នកមានម្នាក់ ប្រដៅកូន ។ ឯច្បាប់ *ព្រះរាជសម្ភារ* គឺព្រះរាជសម្ភារខ្លួនឯង ជាអ្នកតែង ហើយទោះជាលោកដាក់ឈ្មោះច្បាប់នេះថា "*រាជនេតិ*" តែអ្នកស្រុក នៅតែហៅ

*ច្បាប់ព្រះរាជសម្ភារ* ដដែល ។ សរុបសេចក្តីទៅ គឺថា វិធីអប់រំរបស់ចាស់បុរាណ លោកតែងប្រើតាមមធ្យោបាយអក្សរសិល្ប៍ គឺសរសេរជាពាក្យកាព្យឱ្យទន្ទេញចាំមាត់ រួចហើយស្រង់យកន័យដែលចាំមាត់នោះរំលឹកទូន្មានខ្លួនឯងតែម្តងទៅ ។ អ្នកសិក្សាសព្វថ្ងៃ នៅតែដកស្រង់យកន័យល្អៗ ពីក្នុងនេះ មកប្រតិបត្តិអាចត្រូវបានជាដរាបដែរ បានជាគេចាត់ទុក **ច្បាប់ផ្សេងៗ** ជាអក្សរសិល្បសាមញ្ញមួយ ផ្នែកខាងការអប់រំមនុស្ស ។

# ច្បាប់ដែលមានក្នុងសៀវភៅនេះ


ទំព័រ

- ច្បាប់ក្រម .................................................... ០០១
- ច្បាប់កេរកាល .................................................... ០០៨
- ច្បាប់អរិយសត្ថា .................................................... ០១២
- ច្បាប់ស្រី .................................................... ០២០
- ច្បាប់ប្រុស .................................................... ០៣៣
- ច្បាប់ទូន្មានខ្លួន .................................................... ០៤៤
- ច្បាប់កូនចៅ .................................................... ០៥១
- ច្បាប់ពាក្យចាស់ .................................................... ០៦៣
- ច្បាប់បណ្ដាំបិតា .................................................... ០៧៨
- ច្បាប់កូនចៅល្បើក.................................................... ០៩០
- ច្បាប់វិធូរបណ្ឌិត .................................................... ១០៦
- ច្បាប់ត្រីនេតិ .................................................... ១១៤
- ច្បាប់ព្រះរាជសម្ភារ .................................................... ១២៨

# ច្បាប់ក្រម

## បទភាកគតិ

១- នេះគឺច្បាប់ក្រម ប្រសើរឧត្តម ទូន្មានអ្នកផង
ប្រើឱនលំទោន កុំបីមានឆ្គង ប្រាជ្ញាបុណ្យផង
កើតដោយប្រណិប័តន៍ ។

នរអ្នកណា ទោះយកអាត្មា ចូលសាសន៍ពុទ្ធរត្ន
ចូរធ្វើឱ្យត្រង់ ដោយនូវបន្ទាត់ ហៅស្វែងសម្បត្តិ
យកផ្លូវនិព្វាន ។

នរអ្នកផង ទោះដឹងយល់ហោង ចិត្តនោះឱ្យហ៊ាន
បំពេញព្រះផ្នួស ដោយព្រះទូន្មាន កុំធ្វើលឹកលាន
ដោយចិត្តអន្ធពាល ។

ម្ដាយឪពុកសោតណា ស្រឡាញ់ស្ងួនភ្ងា ហៅកូនសង្សារ
អាចមកបំបួស ហេតុចង់សម្ភារ ប្រើបង់អន្ធពាល
រៀនដោយក្រមច្បាប់ ។

៥- សង្វាតសរសេរ អស់អញកុំខ្ជិល ទើបបានជាគាប់
សង្វាតសូត្ររៀន ដោយគ្រូប្រញប្ដ[១] កុំធ្វើលេលាប់
ដោយចិត្តមាក់ងាយ ។

---

១ -បញ្ញត្ត

ហែអស់សាមណេរ ម្ដាយមកបង្វែរ អ្នកជាបាធ្យាយ
សង្វាតសូត្ររៀន ដូចលោកទាំងឡាយ កុំធ្វើពាយងាយ
ដូចនៅគ្រហស្ថ ។

កុំធ្វើរាយមាយ នឹងគ្រូបាធ្យាយ ទុកស្មើអម្ចាស់
សង្វាតសរសេរ សូត្ររៀនឱ្យណាស់ ប្រាជ្ញាយល់ច្បាស់
នាំញាតិទាំងឡាយ ។

អាសូរមេបា ចិញ្ចឹមរក្សា កុំឱ្យអន្តរាយ
អាចយកមកផ្ញើ នឹងគ្រូបាធ្យាយ ហេតុចង់ពណ្ណរាយ
ប្រយោជន៍ទាំងបី ។

មួយចង់ក្ដីច្បាប់ ឱ្យបានខ្លួនគាប់ នៅនាលោកិយ
មួយចង់ប្រាជ្ញា មិនឱ្យអប្រិយ មួយចង់បារមី
នាំញាតិទាំងឡាយ ។

១០- ហែអស់សាមណេរ កុំធ្វើដែលដែរ ត្រង់ក្ដីពាយងាយ
លំអុតបម្រើ អ្នកជាបាធ្យាយ ជូនបុណ្យទៅម្ដាយ
ឪពុកទីទៃ ។

សង្វាតសូត្ររៀន កុំធ្វើអៀនប្រៀន ក្នុងចិត្តសព្វថ្ងៃ
លំអុតបម្រើ ផ្ដាប់ដោយហឫទ័យ បារម្ភមែៗ
ក្ដីច្បាប់កុំបីបង់ ។

ច្បាប់នេះសោតណា ទូន្មានអាត្មា ដោយនូវក្រឹត្យសង្ឃ
ត្រង់ណាហៅច្បាប់ កាន់ខ្ជាប់កុំបីបង់ ចំណោះទៅលង់
ខ្លួនបានជាធំ ។

សព្វថ្ងៃសោតណា ទូន្មានអាត្មា ដោយនូវក្រឹត្យក្រម
បម្រើបាធ្យាយ ឱ្យមានបារម្ភ ទើបខ្លួនជាធំ
ទៅដល់មហាក្សត្រិយ៍ ។

ច្បាប់នេះសោតណា ទូន្មានអាត្មា ថេរនៅពុំបាត់
ទោះខ្លួនឥតបុណ្យ បម្រើមហាក្សត្រិយ៍ គោរពប្រតិបត្តិ
យសនោះពុំលែង ។

១៥- ហេតុបានដឹងច្បាប់ បានដូចបង្គាប់ ចិត្តគ្រូយល់ស្តែង
ទោះទៅបម្រើ ស្តេចជាគម្ពែង យសនោះពុំលែង
ប្រាកដពណ្ណរាយ ។

ក្តីនេះជាច្បាប់ ឱ្យសាមណេរត្រាប់ សព្វសរិលទាំងឡាយ
កុំសើចតិះដៀល អ្នកជាបាធ្យាយ អ្នកហោងស្មើម្តាយ
បង្កើតក្តីច្បាប់ ។

សាមណេរណាៗ ទោះមានប្រាជ្ញា នឹងចង់រៀនត្រាប់
ឱ្យយកត្រចៀក នោះឱនចូលស្តាប់ ធ្វើដោយក្រមច្បាប់
នៃគ្រូបាធ្យាយ ។

សាមណេរណាសោត ចិត្តនោះក្រេវក្រោធ ឱ្យចៀសចេញឆ្ងាយ
ច្បាប់នេះមិនទំ សាមណេរទាំងឡាយ តាមចិត្តសប្បាយ
អាត្មាទីទៃ ។

នរអ្នកណា នឹងស្វែងប្រាជ្ញា ឱ្យបានខ្លួនថ្លៃ
ចូរដឹងខុសគាប់ ដោយអធ្យាស្រ័យ ផ្គាប់ដោយហឫទ័យ
អ្នកជាបាធ្យាយ ។

២០- ទោះនឹងស្វែងធម៌ ឱ្យមានសម្គាល់ កុំធ្វើរាយមាយ
ទោះនឹងស្វែងច្បាប់ កាន់ខ្ជាប់កុំបីណាយ កុំឱ្យអន្តរាយ
នូវច្បាប់ក្រមផង ។

រីគ្រូបាធ្យាយ ប្រដូចនូវម្តាយ ឪពុកយើងផង
ហ្វឹកហ្វឺនប្រដៅ មិនឱ្យមានឆ្គង តាមដោយគន្លង
ព្រេងព្រឹទ្ធបុរាណ ។

នរអ្នកណា នឹងស្វែងប្រាជ្ញា ជារស្មីប្រាណ
ឱ្យគិតជញ្ជឹង រំពឹងលែងបាន កុំធ្វើបំពាន
ប្រទូស្តរឹងស្លូង ។

នាបីហៅគ្រូ ដូចអ្នកនាំផ្លូវ ដើរដោយគន្លង
ទោះនឹងឆ្ពោះទៅ ស្រុកតូចធំផង សឹងដូចបំណង
នៃចិត្តចិន្តា ។

WAT KHEMARARATANARAM

វីនឹងចេះឯង ដូចអ្នកវង្វេង កណ្ដាលអធ្វា
ពុំនោះដូចខ្វាក់ តែម្នាក់អាត្មា ចរចេញយាត្រា
ឥតអ្នកដឹកដៃ ។

២៥- សូម្បីរកផ្លូវ ពុំដែលនឹងត្រូវ សឹងពានឯព្រៃ
ហេតុត្បិតនេះឯង ឥតអ្នកដឹកដៃ ចិត្តនោះសង្ស័យ
ដូចដល់ពុំដល់ ។

នេះដូចអ្នកផង ពុំដោយគន្លង នៃលោកណាយល់
សឹងធ្វើមោហោ ទោសោកំហល់ ពុំអាចទប់ទល់
នាធ្ងន់នាស្រាល ។

ប្រដៅក្ដីច្បាប់ សឹងថាពុំគាប់ ហេតុចិត្តអន្ធពាល
ក្ដីច្បាប់ទម្ងន់ សឹងថាជាស្រាល ហេតុចិត្តអន្ធពាល
ចង់តែសប្បាយ ។

ពុំដឹងដើមគ្រូ បង្កើតអភិរូប ប្រដូចនូវម្ដាយ
ក្ដីពីមនុស្សលោក រួចដល់សួគ៌នាយ ចៀសចតុរាបាយ
នរកទាំងបួន ។

នាបីហៅគ្រូ កុំធ្វើមូទូ ចិត្តនោះឱ្យស្លូន
កុំធ្វើតម្កើង ចង់ធំតែខ្លួន ក្រែងបាបមកចួន
នៅនាលោកិយ ។

៣០- រីគ្រូបាធ្យាយ អាចឱ្យពណ្ណរាយ មានរូបរស្មី
ហើយឱ្យរុងរឿង អស់បញ្ចិន្ទ្រិយ ស្មើព្រះជននី
ជនកសោតហោង ។

ព្រះជនកសោតណា បង្កើតអាត្មា ឱ្យមានសរិលផង
រក្សាពីតូច មិនឱ្យមានហ្មង អស់សុខទុក្ខផង
ពុំដែលនឹងឆ្អន់ ។

ព្រះជនកព្រះជននី បើនឹងស្រដី ប្រសើរពេកពន់
ថាភ្នំព្រះសុមេរ៍ នោះហោងមហាធ្ងន់ ថាបើនឹងគណន៍
ពុំអាចកន្លង ។

រីគ្រូបាធ្យាយ ប្រដូចនូវម្ដាយ ឪពុកឯងហោង
អាចឱ្យក្ដីច្បាប់ ប្រដៅធម៌ផង ដោយនូវគន្លង
ព្រះពុទ្ធទាំងឡាយ ។

នរអ្នកណា ទោះមានប្រាជ្ញា ឱ្យគិតវែងឆ្ងាយ
គុណនោះទាំងបី ហោមហាទូលាយ កុំឱ្យអន្តរាយ
ក្ដីពីព្យាយាម ។

៣៥- រីបុណ្យនិងបាប អំពើសភាព នោះវាតែងតាម
ប្រដូចស្រមោល អន្ទោលតាមប្រាណ ពុំដែលចៀសបាន
ត្រង់ក្ដីសល់វ៉ល់ ។

WAT KHEMARARATANARAM

ឱ្យគិតជញ្ជឹង ហើយឱ្យរំពឹង ប្រាជ្ញាឱ្យយល់
ឱ្យមានវីរិយំ សច្ចំកុសល កុំធ្វើសល់រំលង
នឹងក្តីទុក្ខសោក ។

នរអ្នកណា នឹងនាំអាត្មា ឧស្សាហ៍អធ្យោគ
ស្វែងធម៌ជាផ្លូវ ទៅកាន់បរលោក ចូលមហាបថមោក្ខ
គឺនិព្វានហោង ។

( **ចប់** )

# ច្បាប់កេរ្តិ៍កាល[១]

## បទព្រហ្មគីតិ

១- កេរ្តិ៍កាលពីព្រេងព្រឹទ្ធ សាងសុចរិតទៀងទុកនៅ
សេដ្ឋីផ្តាំប្រដៅ បុត្រសង្សារទុកក្រោយហោង ។
កូនអើយកេរ្តិ៍មេបា ចូររក្សាគន់គិតគ្រង
ថែទាំចាំរួសរង ប្រុងប្រយ័ត្នប្រយោជន៍យូរ ។
ធម្មតាអ្នកជាជាតិ កាលគេអាទ៌ឱ្យគិតគួរ
កុំខ្ជិលដេកទទូរ ដល់ថ្ងៃរះពេញពន្លឺ ។
តាក់តែងខ្ញុំកំដរ ចេញទៅរកធ្វើស្រែភ្លឺ
ចិញ្ចឹមគោក្របី រកខ្សែវល្លិ៍បោះក្រោលឃ្នង ។
២- ធ្វើស្រែទិសប្រាំបី ខ្ញុំប្រុសស្រីចេញជួញផង
មើលផ្ទះស្រះរបង វាំងចំណារគួររក្សា ។
ឱ្យមានក្តីបារម្ភ ធ្វើស្រែកុំចោលចំការ
ដឹងដែកកាំបិតព្រា ទុកឱ្យជាកុំឱ្យបាត់ ។
ដេកយប់ឱ្យវាំងទ្វារ ទ្រព្យសម្រាលរៀបប្រយ័ត្ន
ចងទូកកុំឱ្យសាត់ ផ្ទះបាក់បែកឆាប់ទល់ទ្រ ។
សារពើទ្រព្យអ្វីៗ ប្រុងស្មារតីទុកឱ្យល្អ
ឱសទឹកស្រូវអង្ករ យកចេញចាយមានកំណត់ ។

---

១- កេរកាល

កុំអាងមានទ្រព្យច្រើន ពុំក្រវើនរកផ្គង់ផ្គត់
យកចាយៗដោយបទ ទោះនឹងទុកៗដោយខ្នាត ។
១០- រទេះសេះដំរី រាប់បញ្ជីកុំឱ្យឃ្លាត
ខុំណាមានមារយាទ ទុកដាក់ដៃឱ្យរក្សា ។
សប្បុរសយល់ដោយមុខ ស៊ុកគ្រលុកពេកពុំជា
កំណាញ់ក្រៀតម្រា សោតសឹងអាប់ប្រយោជន៍យស។
រក្សាខ្លួនឱ្យរុង- រឿងឧត្តុង្គឧត្តមខ្ពស់
ប្រដាប់ដោយស័ក្តិយស ខ្លួនជាធំឱ្យថៃថ្នូន ។
ឱ្យទានតាំងចិត្តស្មោះ កុំអាឡោះអាល័យស្ងួន
ទ្រព្យនេះនឹងនាំខ្លួន ទៅបរលោកពុំសោះសូន្យ ។
ទ្រព្យធនទោះថោកថ្លៃ កុំដាក់ដៃឱ្យតែកូន
នូវអស់ទាំងបងប្អូន អ្នកជនទៃរក្សាតាង ។
១៥- ទុកចិត្តខ្ញុំមើលដាក់ ស្មើភ្នែកខ្វាក់ទាំងសងខាង
ឱ្យកូនគន់មើលតាង ស្មើភ្នែកម្ខាងពុំពេញពីរ ។
ធ្វើអ្វីធ្វើឱ្យហើយ កុំទុកឡើយបង្កើតកេរ
សំអាតអស់សរិល កុំឱ្យមានក្តីនិន្ទា ។
ដំណេកដេកជាខ្នាត ឱ្យសំអាតសំអាងជា
ទើបទេវតារក្សា ចម្រើនសុខស្រីសួស្តី ។
គ្រឹះហាឱ្យផ្ចិតផ្ចង់ កុំឱ្យផង់ផុយធូលី
ជម្រះបារបោសដី ឱ្យហ្មត់ហ្មងកើតសុខា ។

អញ្ចុលទុកឱ្យគង់ ប្រាក់ក្នុងថង់ទុកឱ្យជា
ប្រើខ្ញុំមើលមុខវា ទោះកាចជាមើលឱ្យស្ដែង ។
២០- សារពើរួសរៀនរិះ ឱ្យចាំចេះៗចារចែង
ចង់គាប់ប្រើស្វះស្វែង រករៀនរិះសារពើក្ដី ។
សប្បុរសពេកចាញ់ធន នាទុជិនចាញ់ឥន្ទ្រិយ
ប្រពន្ធល្អច្រើនចាញ់ប្ដី ពាក្យច្រើនភូតចាញ់អាត្មា ។
ឈើផ្លែច្រើនចាញ់ស្លឹក ត្រីច្រើនទឹកល្អក់ពុំជា
ទ្រព្យច្រើនព្រួយរក្សា ទ្រព្យតិចណាព្រួយរិះគិត ។
ដេកយប់កុំដិអក់ ឱ្យលង់លក់ក្រៅសុចរិត
ខ្ញុំណាមានគំនិត គួរឱ្យគិតប្រណីវា ។
ចងទូកបោះបង្គោល រិះរកថ្នោលពួរយុថ្កា
ការខ្យល់កាចពុំជា ក្រែងពានពារបោកបែកបាត់ ។
២៥- រៀនរិះសារពើក្ដី ទោះស្រដីកាន់ពាក្យសត្យ
ចាំក្បួនចាំឱ្យស្ទាត់ កុំអៀនព្រៀនសមពាក្យពោល ។
ការក្រកុំគិតងាយ ការសម្ចាយជាកម្រោល
សន្សឹមកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា ។
រៀនរិះរួសរវាំង ធ្វើស្រែប្រាំងស្រែវស្សា
ធ្វើស្រែមានចំណារ ធ្វើចំការចាររបង ។
ផ្លូវវៀចកុំបោះបង់ ផ្លូវណាត្រង់កុំដើរហោង
ដើរដោយផ្លូវគន្លង តម្រាយអ្នកចាស់បុរាណ ។

ឆ្អែតជាឱ្យបាយឆី ដេកនៅដីចាំធនធាន
គ្រឿងសឹកទុកទាហាន កេរ្តិ៍គម្ពីរទុកប្រាជ្ញប្រាយ ។

៣០- យល់តូចកុំអាលទំ ទោះយល់ធំកុំអាលស្រាយ
គិតក្តីកុំគិតងាយ មើលពិនិត្យពិនិស្ស័យ ។

កូនអើយកេរ្តិ៍មេបា ចូររក្សាចាំសព្វថ្ងៃ
ទ្រព្យធននោះថោកថ្លៃ គួររក្សាកុំបីធ្លោយ ។

ពាក្យនេះជាត្រកាល ជាខ្លឹមសារទៀងទុកឱ្យ
កូនចៅនៅឯក្រោយ តែងទូន្មានអង្គអាត្មា ។

ថៃទាំទើបគង់ទ្រព្យ រៀបរណ្តាប់ទុកទើបជា
ចាយវាយក្រៅតម្រា សឹងវិនាសធនធានផង ។

បានមកទុកឱ្យគង់ កុំឱ្យបង់បាត់បំណង
រៀនរិះរក្សាគ្រង យកចេញចាយដោយរដូវ ។

៣៥- ដឹងហាបឱ្យដឹងតុល ភ្នែកឱ្យយល់ទៀងត្រាជូ
គិតគ្រប់សព្វដោយផ្លូវ ក្តីចន្លោះកុំបីមាន ។

ពាក្យនេះស្មើខ្លួនហើយ កូនចៅអើយចូរចាំប្រាណ
អស់អាថ៌ឱវាទទាន ជាសួរេចបណ្តាំហោង ។

**( ចប់ )**

# ច្បាប់អរិយសត្ថា

## បទភាកគតិ

១- អរិយសត្ថា[១] គង់គិតថ្លែងចារ ចងទុកជាច្បាប់
ឱ្យអស់សិស្សផង ត្រងត្រាប់សណ្ដាប់ យកជាតម្រាប់
តម្រង់អាត្មា ។

ឱ្យមានប្រយោជន៍ ប្រយ័ត្នអសោច រាល់រូបអ្នកណា
អម្បាលមករៀន រៀនសាស្ត្រា ប្រយ័ត្នអាត្មា
ការកេរ្តិ៍លោកិយ ។

ទោះនឹងចេញទៅ ប្រយោជន៍នានៅ ផ្គាប់ផ្គុនមន្ត្រី
ឱ្យត្រូវនឹងច្បាប់ សណ្ដាប់ស្លូស្ដី ដូចលោកស្រដី
ប្រដៅទុកមក ។

បើមិនចង់ទេ ចង់នៅទំនេរ ជួញប្រែរិះរក
ចិញ្ចឹមជីវិត គួរគិតរៀនយក រៀនរៀននោះមក
ទើបរកទ្រព្យបាន ។

៥- វាយលេខទាត់ក្បាច់ សឹងផ្សំសម្រេច ឱ្យបានដឹងដាន
ដឹងដើមដឹងចុង ដឹងបង់ដឹងបាន ដឹងគិតប្រមាណ
កត់ត្រាបញ្ជី ។

---

១- អរិយសត្ថា ជាសមណសក្តិ ទីមេគណ ឬចៅអធិការ ដែលជាអ្នកតែងច្បាប់នេះ បានជាគេឱ្យឈ្មោះថា " ច្បាប់អរិយសត្ថា " ដូច្នេះ ។

ឱ្យបានប្រយោជន៍ ប្រយ័ត្នអសោច ជាអ្នករកស៊ី
សម្រាប់លោកិយ ប្រក្រតីជាទី សម្គាល់បញ្ជី
ស្មៀនត្រាសៀវភៅ ។

គន់គិតប្រយ័ត្ន អស់ទ្រព្យសម្បត្តិ ឱ្យស្ទាត់ដោយនូវ
វាយលេខទាត់ក្បាច់ ឱ្យស្រេចឃើញផ្លូវ សឹមថយចេញទៅ
តាមផ្លូវលោកិយ ។

ល្មមដឹងតិចច្រើន ល្មមដឹងក្រវើន ទ្រព្យធនអ្វីៗ
លេខនិងអក្សរ កំដរស្មារតី សម្រាប់លោកិយ
នោះឯងទើបត្រូវ ។

បើតែវិលវេះ ខ្វិលដេកស្រមេះ ស្រមូញស្ងួញសស្ងូវ
ស្រទាងលើខ្នើយ កន្តើយលក់ទៅ នរណានឹងនៅ
ដាស់តឿនឱ្យទៀត ។

១០- មិនដឹងឬអ្វី ក្នុងរាជ្យលោកិយ រាជការចង្អៀត
នរណាទុកឯង លេងវាយដៃព្រាត ឃើញហើយគេបៀត
តម្រៀតរាជការ ។

ហេតុនេះគួរគិត គួរកាន់គំនិត គួរគិតឧស្សាហ៍
សង្វាតរករៀន របៀនសាស្ត្រា តម្រិះប្រាជ្ញា
បង្ការទុកទៅ ។

បើដោះខ្លួនរួច រាប់ជាអ្នកស្រួច ដឹងគិតរាក់ជ្រៅ
ក្នុងរាជ្យលោកិយ សេចក្ដីឥឡូវ គិតឱ្យឃើញផ្លូវ
នឹងទៅមុខទៀត ។

រីត្រង់ឯខ្លៅ គេថយចេញទៅ រកស៊ីចង្អៀត
គិតគូរម្ដេចម្ដា ប្រវាបែរបៀត ពឹងអ្នកកន្ទៀត
ដូចខ្លួនកាលណា ។

ហេតុតែខ្លួនឯង ចេះគិតតាក់តែង ឱ្យគ្រប់ប្រការ
ទាំងលេខទាំងក្បាច់ ស្រេចនូវអាត្មា ឯងឱ្យអស់ការ
គិតគូរសព្វសាយ ។

១៥- ទើបបានគេកោត គេមានចំណោទ គេកោតប្រាជ្ញប្រាយ
គេយល់ឯងចេះ ចំណេះលៃបវាយ ពុំមានក្លែងក្លាយ
បំបាត់បានឡើយ ។

រីត្រង់អ្នកខ្លៅ ផ្ដេកផ្ដិតចិត្តទៅ យកគេជាត្រើយ
កាលម្ដងគេត្រង់ គង់ចិត្តនៅឡើយ ដល់ពីរដងហើយ
គេប្រែប្រាជ្ញា ។

គេគិតទាយទាត់ វាយលេខបំភ្លាត់ បំផ្លាញអាត្មា
ចំណេញទៅគេ ទទេអសារ ខ្លួនឯងឥតការ
ខាតទុនក្រខ្លួន ។

នេះឯងក្មេងអើយ កុំប្រហែសឡើយ រៀនទុកជាក្បួន
ទាំងលេខទាំងក្បាច់ អាស្រ័យនៅខ្លួន អក្សរឱ្យសួន
ទាន់ខ្លួននៅក្មេង ។

តែចាស់បន្តិច វិញ្ញាណភ្លាំងភ្លេច គំនិតប្រែផ្សេង
គិតការច្រើនមុខ កើតទុក្ខកន្ទេង ប្រាប់អស់ក្មេងៗ
ឱ្យដឹងឱ្យហើយ ។

២០- កុំអាងម៉ែឪ សម្បត្តិដែលនៅ មានច្រើននោះឡើយ
ក្រែងឥតនឹងម៉ែ នឹងឪទៅហើយ ខ្លួនខ្លៅឆោតឆើយ
ងងឹតល្ងង់មោហា ។

ក្រែងអស់ទាំងទ្រព្យ នោះវាមិនខ្ជាប់ នៅនឹងអាត្មា
ខ្លួនឯងឆោតឆៅ កំឡៅមោហា មិនចេះរក្សា
មិនបានគង់ទេ ។

ខូចខាតមិនខាន គំនិតមិនបាន ប្រហែសខ្ញុំគេ
គេវាយគេធាក់ គេប្រើគេជេរ មិនឱ្យទំនេរ
ខ្មាសគេតិចអ្វី ។

ដូច្នេះគួរគិត គួរឃើញគំនិត គួរគិតសេចក្តី
ជាមនុស្សដូចគេ គួរតែឃ្មាតខ្មី រំឭកស្មារតី
ស្រឡាញ់របៀន ។

កុំគិតខ្ជិលពេក　　កុំគិតពួនដេក　　កុំគិតវេះវៀន
កុំគិតមានពុត　　រមត់កិចកៀន　　កុំគិតអៀនប្រៀន
វេះវៀនចិត្តកាច ។

២៥- ឱ្យរៀនចិត្តល្អ　　ដឹងធម៌អក្សរ　　គួរគិតកោតខ្លាច
ការកេរ្តិ៍ប្រយ័ត្ន　　គួរកាត់ចោលកាច　　គួរឱ្យខ្លួនខ្លាច
កុំឱ្យគ្រូទាយ ។

ពាក្យគ្រូធ្ងន់ណាស់　　ដំនៀលដល់ចាស់　　ពីព្រេងមុននាយ
ឯត្រង់ពាក្យម្ដាយ　　ទំនាយគ្រូទាយ　　នេះឯងមិនងាយ
អាក្រក់ណាស់ណា ។

ឱ្យប្រុងប្រយ័ត្ន　　បម្រើប្រណិប័តន៍　　កាន់ចិត្តស្នេហា
កុំឱ្យអន់អាក់　　ថ្នាំងថ្នាក់ចិន្ដា　　គ្រូទាយហើយណា
ឆុតឆាប់ណាស់ហោង[១]។

ឱ្យដឹងបាបបុណ្យ　　ស្គាល់ទោសនិងគុណ　　ជាទុនទៅមុខ
គុណគ្រូបាធ្យាយ　　គុណម្ដាយឪពុក　　រៀមច្បងទំនុក
ឱ្យសុខអនុកូល ។

គ្រូមួយផងគ្នា　　រួមរ័ក្សចិត្តជា　　ស្នេហាមិត្រមូល
កុំនាំអុជហេតុ　　បំបែកចេញចូល　　កាច់កិនត្រកូល
បង្កើតមាត់ក ។

---

១- ឃ្លាតពីនេះ ប្រហែលជាបាត់មួយគាថា បានជាបាត់ដួន ។

៣០- កុំធ្វើមាក់ងាយ　នឹងគ្រូបាធ្យាយ　រៀនចិត្តឱ្យល្អ
ទោះអ្នកឯណា　ណែផ្លូវអក្សរ　អ្នកនោះឯងអរ
ឱ្យចិត្តមេត្រី ។

កុំឱ្យសៅហ្មង　លើលោកកន្លង　ពោលពាក្យស្រដី
រឹងរូសទ្រគោះ　ឈ្លាសឈ្លោះសេចក្តី　កើតទោសអប្រិយ
ដេរពោលប្រមាថ ។

អ្នកនោះស្មើគ្រូ　បង្កើតអភិរូហ៍　គុណគេឱវាទ
គេជួយប្រដៅ　គេហៅឱបាត　ដាស់តឿនសង្វាត
ឱ្យឯងចេះឆាប់ ។

បើឯងចេះហើយ　កុំភ្លេចគុណឡើយ　ឱ្យដឹងដោយច្បាប់
គួរគិតកោតខ្លាច　ដើរតាមសណ្តាប់　គន្លងធម៌ច្បាប់
កុំឱ្យមាក់ងាយ ។

នេះឯងគន្លង　ត្រឹមត្រូវទំនង　អំពីព្រេងនាយ
ឯករាជ្យឥឡូវ　ច្រើនតែមាក់ងាយ　ចេះហើយដេរម្តាយ
ប្រមាថគ្រូវិញ ។

៣៥- ហេតុដូច្នេះឯង　លោកិយយល់ស្តែង　តែងឃើញម្តេចមិញ
បានហោចសូឡសុង　លិចលង់ទៅវិញ　ទោសនោះឯងមិញ
កើតពីឯណា ។

កើតពីចិត្តឯង បង្កើតស្វះស្វែង បំផ្លាញអាត្មា
រោលរាលក្នុងពោះ ឆេះក្នុងឧរា បង្កើតទោសា
ឱ្យទុក្ខរូបឯង ។

ចេះតែបន្តិច លើកខ្លួនកំប៉ិច កំប៉ោងឥតក្រែង
តែងឃើញរៀងមក យ៉ាងដូច្នេះឯង ម្លោះហើយវាតែង
ខុសនឹងទេព្តា ។

វិអ្នកចិត្តល្អ ដឹងធម៌អក្សរ ចេះពិចារណា
ស្គាល់គុណនិងទោស សន្តោសអាត្មា អត់ឱនចិន្តា
ពុំដែលសៅហ្មង ។

អ្នកនោះឯងនៃ សោតសឹងប្រពៃ សួស្តីកន្លង
បរលោកលោកិយ ឥតបីសៅហ្មង ទាំងទេព្តាផង
ចម្រើនឱ្យសុខ ។

៤០- ជរាបរៀងទៅ សុខពីឥឡូវ រៀងទៅឯមុខ
ចៀសចាកប្រាសប្រាណ ពីស្ថាននរក រៀងរួចបានសុខ
ដល់សួគ៌ាល័យ ។

អរិយសត្ថា	គន់គិតថែងចារ	ថែងចងសេចក្តី
តម្រង់តម្រាប់	ជាច្បាប់យ៉ាងថ្មី	ជាស់តឿនស្រដី
សិស្សសព្វប្រការ ។

៤២- គួរគិតរករៀន	កិច្ចការរបៀន	របបសាស្ត្រា
តាមច្បាប់និទាន	ទូន្មានអាត្មា	រៀលរាល់រូបា
សូរេចចប់ហោង ។

(**ចប់**)

📖 ❦ 📖
📖

# ច្បាប់ស្រី

មុីន-មៃ វៀងវៀង

## បទភុជង្គលីលា

នេះបទកំណាត់ចងជា ភុជង្គលីលា ចងជាច្បាប់ស្រី ។
កាលនាងឥរន្ធវតី ចរចាកតាមប្តី គឺបុណ្ណកយក្សា[១]។
នាងវិមលាជាព្រះមាតា បើកបន្ទូលថា ហៃកូនពិសី ។
នាងនឹងត្រាច់ត្រង់តាមប្តី ចេញចាកអំពី ពិភពនាគនេះ ។
ទៅឋានមនុស្សលោកនាយអេះ ចូរនាងចាំចេះ បម្រើស្វាមី ។
ធ្វើវត្តប្រតិបត្តិប្រក្រតី កុំឱ្យស្វាមី អាក់អន់ចិន្តា ។
នាងអើយគម្លែងក្រឡា ជាម្ចាស់សិរសា កូនកុំមាក់ងាយ ។
ហៃកូនស្រីស្ងួនមាសម្តាយ ក្រណាស់នាងអាយ តាមដោយច្បាប់ស្រី។
ក្រមួយមិនបានសម្តី ពាក្យទន់តិចនៃ ឱ្យញាតិចូលចិត្ត ។
ក្រមួយមិនចេះរិះគិត ឃើញញាតិឆ្ងាយជិត ហៅឡើងធីស្វា ។
ទោះមានមិនមានក្តីណា ពាក្យផ្អែមចរចា ទើបគេស្រឡាញ់ ។
កុំជួចិត្តស្វរកំណាញ់ មិនមានអស់អញ នឹងញាតិសន្តាន ។
កើតយសរបស់ផងបាន កើតសុខក្សេមក្សាន្ត ពីព្រោះកូនស្រី ។
ទោះនឹងនិយាយស្រដី ការកើតជាស្រី កុំស្តីឡេះឡោះ ។

---

១- តាមទម្លាប់គេហៅថា ប៉ុន-ណាក់ យក្សា ។

ថាលេងដូចក្មេងញ៉េះញ៉ោះ ឃើញប្រុសកំឡោះ សសៀរចូលជិត ។
សើចព្រៀងបញ្ឆៀងមិនគិត ប្រុសព្រើលបានចិត្ត វាបានដោយសារ ។
ហៅស្រីអប្រិយឥតការ ឥតមានឥរិយា មារយាទក្នុងខ្លួន ។
សើរើពុំធ្វើនឹងនួន ស្រដីមិនមួន មិនមានអៀនអន់ ។
ឃើញគេបៀតបែរគយគន់ សើចសួរចំអន់ ចំអកឱ្យប្រុស ។
ហៅស្រីអប្រិយទុរយស មិនខ្លាចខ្លួនខុស មារយាទក្រឹត្យក្រម ។
ធ្វើការអង្អុយប្រទ្បុំ នឹងសមពុំសម ថាឯងជាស្រី ។
មិនកោតមិនខ្លាចចិត្តប្ដី ឱ្យប្រុសដទៃ មាក់ងាយប្ដីណា ។
ហៅស្រីឥតលក្ខណា ឥតមានកិរិយា មារយាទពុំសម ។
ធ្វើការផងណាប្រើខំ ទោះត្បាញចាក់ដំ នាងខំឱ្យហើយ ។
កុំទុកទៅមុខទៀតឡើយ ថាចាំបង្ហើយ កម្រណាស់ណា ។
ទោះធ្វើហូលគោមព្រៃផ្កា ដាក់ត្បាញហើយណា បានស្រេចសឹមធ្វើ ។
ធ្វើឱ្យកើតកេរ្ដិ៍ប្រសើរ ហើយកុំឱ្យដើរ លេងផ្ទះគេណា ។
ឱ្យស្ងួនខ្ចឹមខ្លួនរក្សា នាងខំធ្វើការ ទាន់ខ្លួនក្រមុំ ។
មានប្ដីបានអ្វីជាខំ រវល់កូនយំ កម្រចេះឆ្ងៀត ។
ព្រួយចិត្តគំនិតចង្អៀត មួយហើយមួយទៀត យំទារតែធី ។
រឹងព្រួយទាំងមួយទាំងពីរ រកបានឱ្យធី ទើបបានបាត់មាត់ ។
ទោះកាន់ការធ្វើឱ្យស្ទាត់ ហូលគោមគាតកាត់ អន្ទងត្បាញទៅ ។
កុំទុកក្នុងស្មុគស្មាញនៅ ក្រែងដល់យូរទៅ ខាតខូចអសារ ។

ហៃកូនស្រីស្ងួនមាតា ចូរចាំរក្សា កុំភ្លេចស្មារតី ។
ចូររករៀនយកច្បាប់ស្រី ឱ្យកោតខ្លាចប្ដី គម្ដែងក្រឡា ។
ធ្វើវត្តប្រតិបត្តិសោតណា ឱ្យនាងរក្សា ភ្នក់ភ្លើងទាំងបី ។
ឱ្យកាត់ឱ្យគង់ប្រក្រតី សព្វថ្ងៃកុំបី ភ្លេចផ្ដិឱ្យឆេះ ។
ក្រែងរាលដូចដាលព្រាយប្រេះ កើតក្ដៅរលេះ រលាយអស់អង្គ ។
ភ្លើងក្រៅកុំនាំទៅក្នុង ឱ្យឆេះបំផ្លុង រឹងផ្ដិបង្កាត់ ។
ភ្លើងក្នុងមិនប្រុងប្រយ័ត្ន នាំមកបង្កាត់ ឱ្យឆេះឯក្រៅ ។
អុជអាលបណ្ដាលឱ្យក្ដៅ ដាលដល់កូនចៅ អសោចអប្រិយ ។
ឱ្យនាងរំប្រុងស្មារតី មើលភ្លើងទាំងបី រក្សាឱ្យគង់ ។
ភ្លើងនោះឱ្យគុណពុំលង់ នឹងឱ្យឧត្ដុង្គ ឧត្ដមកន្លង ។
កើតយសរបស់ទ្រព្យផង បរិបូណ៌ឥតហ្មង ប្រសើរក្ដាត់ណា ។
ភ្លើងមួយនោះឱ្យរក្សា គឺគុណមាតា បិតាស្ងួនគ្រង ។
ឱ្យនាងធ្វើដោយគន្លង ប្រណិប័តន៍កុំឆ្គង នឹងម្ដាយឪពុក ។
ឱ្យរំថៃទាំញិកញ៉ុក ចំណីចំណុក ចំណង់អាត្មា ។
កុំឃ្លានទុកធីឡើយណា ឆ្ងាញ់ឈ្ងុយពិសា ជូនជាប្រក្រតី ។
ពាក្យពេចន៍ការកិច្ចអ្វីៗ អត់ឱនកុំបី ឱ្យអាក់ចិន្ដា ។
ភ្លើងមួយគម្ដែងក្រឡា គឺប្ដីអាត្មា បិតថេររួមរ័ក្ស ។
ឱ្យនាងប្រណិប័តន៍ជៀកជាក់ កុំធ្វើឱ្យអាក់ ឱ្យអន់ចិត្តប្ដី ។
អត់ឱនខ្លាចខ្លួនជាស្រី កុំឱ្យស្រដី ទុកគេជាស្មើ ។

ទោះកើតហេតុភេទសារពើ ពាក្យពុំប្រសើរ ជញ្ជឹងចាំស្តាប់ ។
ទោះប្តីស្រដីពុំគាប់ ពុំគួរឱ្យប្រាប់ បានដឹងដល់ម្តាយ។
កើតវឹងវែងរឹងខ្វះវាយ ឮពាក្យពីម្តាយ ឱ្យបង្វៀរប្រាប់ប្តី ។
មិនក្សាន្តបែកបានពីរបី កើតជាសម្តី សួរចុះសួរឡើង ។
ពុំស្ងាត់ស្ងៀមមាត់ចចើង ជជែកនាំឡើង ចចើងមិនបាត់ ។
តតាំងពាក្យខ្លាំងមិនស្ងាត់ មិនស្ងៀមឱ្យបាត់ ឱ្យបានទីសុខ ។
ជជែកស្ទើរបែកទាំងស្រុក មិនមានហៅសុខ យូរលង់ឡើយនៃ ។
នេះហៅភ្នក់ភ្លើងទាំងបី ម្តាយផ្តាំកូនស្រី ឱ្យចាំរក្សា ។
នាងអើយគម្លែងក្រឡា ខុសឆ្គងម្តេចម្តា ម្តាយផ្តាំកូនស្រី ។
ឱ្យអត់សង្កត់ហឫទ័យ កូនកុំស្រដី ដើមប្តីកំបាំង ។
កុំជេរកុំចេញជាខ្លាំង ខ្សត់ខ្សោយខ្លៅខ្លាំង នាងកុំមើលងាយ ។
ល្ងង់ខ្សោយប្រើឱ្យនិយាយ ណែនាំលេងលាយ ឱ្យស្រួលវាចា ។
ទោះប្តីស្រដីម្តេចម្តា ខេវឹងជេរថា បោះពាក្យទម្ងន់ ។
ក្រោធក្រេវក្រុលឆេវមិនអន់ មិនអាក់ស្រាកស្រន់ ដោយចិត្តគ្នាន់ក្នាញ់។
រអ៊ូរទាំទន្ទេញ ជេរថាជន្ទេញ ត្បិតទាស់នឹងចិត្ត ។
ឱ្យកូនស្រីស្ងួនខំអត់ ឱ្យបានរលត់ រលាយកំហឹង ។
កុំកូនកាន់ខ្លួនប្រែប្រឹង តតបទៅនឹង អ្នកជាស្វាមី ។
ខេវឹងត្រញឹងសម្តី មិនគិតខ្លួនស្រី ស្រដីទ្រគោះ ។

| | | | |
|---|---|---|---|
| | ប្រកែកស្តីពាក្យគំរោះ | គំរាមបញ្ជោះ | បញ្ជោរឱ្យខឹង ។ |
| | រឹងរូសមើលមុខសំឡឹង | សំឡក់ទៅរឹង | ចចើងចង់ឈ្លោះ ។ |
| | រឹងឆ្លងឆ្លើយពាក្យបញ្ជោះ | បំបែកជាឈ្លោះ | បំបែរពុំទៀង ។ |
| | ដេរថាឆ្កែឆ្មាបំព្រៀង | ដៀលត្មះបញ្ឆៀង | បញ្ឈឺចិត្តប្តី ។ |
| ៧៩- | បោះបោកប្រទះអ្វីៗ | ចាប់ចោលទៅដី | បែកបាក់ពុំគិត ។ |
| | មិនស្រួលទទួលបាត់មាត់ | ម្នះម្នេញក្នុងចិត្ត | ឱ្យបានប្តីចាញ់ ។ |
| | ទើបបានសុខចិត្តជាវិញ | ហៅស្រីម្នះម្នេញ | អាប់កេរ្តិ៍សន្ធាយ ។ |
| | ហៃកូនស្រីស្ងួនមាសម្តាយ | ខ្លួនណាស់នាងអាយ | កុំធ្វើដូចគេ ។ |
| | ទោះបីបើប្តីនាងជេរ | នាងចូលទៅឯ | ដំណេកគិតសិន ។ |
| ៨០- | ចេញមកនាងយកពាក្យទន់ | ស្រដីឱ្យអន់ | ស្រាយទោសនោះទៅ ។ |
| | ទោះបីបើប្តីប្រដៅ | ចូរនាងចាំនៅ | ទុកក្នុងអាត្មា ។ |
| | ពាក្យពេចន៍កុំភ្លេចឡើយណា | ក្រែងឆ្លងម្តេចម្តា | ត្បិតបានផ្តាំស្រាប់ ។ |
| | ព្រោះឯងមិនក្រែងមិនស្តាប់ | ពាក្យគេបង្គាប់ | បង្អើតតែឈ្លោះ ។ |
| | ឥតសុខអាក្រក់តែឈ្មោះ | ឮគេប្រឈ្លោះ | មិនចេះហៅល្ហែ ។ |
| ៨៥- | នេះពុំរាប់ជាស្រីទេ | ជាអ្នកប៉ោខ្សែ | ចិត្តចោរដកទង ។ |
| | ឱ្យមាត់បង្រួបប្តីផង | ឱ្យគេស្តាប់ហោង | ថាឯងគ្រាន់បើ ។ |
| | គឺមោះនាងនោះមិនប្រើ | មិនបើកឱ្យដើរ | បញ្ជើរឱ្យទេ ។ |
| | ទោះបីប្តីប្រើមាសមេ | កុំកូនចំអែរ | ចំអៀកមិនទៅ ។ |
| | ឆ្ងាយជិតកុំគិតរង់នៅ | ក្រោកក្រេសដើរទៅ | កុំឱ្យប្តីជេរ ។ |
| ៩០- | កុំទៅនៅយូរផ្ទះគេ | រវល់ទំនេរ | រវៀសមកណា៎ ។ |

ហៃកូនវិមខ្លួនមាតា ជាស្រីនេះណា៎ កម្រណាស់នាង ។
មិនថាត្បិតល្អរូងរាង មិនរើសត្បិតជាង ចេះការទាំងគ្រប់ ។
មិនបានស្គាល់ទីគោរព ស្គាល់តែឱបទ្រព្យ ទាំងជប់ប្រការ ។
ហៅតែនឹងល្អរូបា ពិតហើយចេះការ គួរកោតដោយយ៉ាង ។
៩១- មួយល្អរូបសសន្លាង ឥតគេផ្ដឹមខាង ច្បាប់ផងមិនចេះ ។
ល្អពិតគំនិតមិនផេះ ទោះខ្មៅក្រងេះ ការសោតសមគួរ។
គឺមោះនាងនោះមិនជួ ចេះដឹងសមគួរ ស្គាល់អស់ឥរិយា ។
នេះឯងពីព្រេងលោកថា ហៅល្អរូបា កបកល្យាណី ។
ហៃកូនស្រីស្ងួនពិសី ម្ដាយប្រាប់អំពី ឱបទ្រព្យចង្រៃ ។
១០០- កាន់ក្បាលប្ដីហើយរកចៃ មិនបានលើកដៃ បិទទូលសំពះ ។
លោកទុកស្មើកុកទំផ្ទះ រង្គំរង្គះ នឹងបង់អស់ទ្រព្យ ។
កន្លងជើងប្ដីពុំគាប់ ព្រោះចិត្តចង់ឆាប់ រំលងជើងប្ដី ។
ស្មើសត្វលលកខ្មោចវិ ហើរប្រាលអប្រិយ កើតព្យាធិរោគា ។
ចង្រៃមួយនៃរាល់គ្នា ចេញចូលមាត់ទ្វារ ពុំបានបិទបាំង ។
១០៥- ធ្វេសប្រាណខុសខាងមិនរាំង មិនរុញបំបាំង មើលយល់សាយសុស។
ទុកស្មើគេអុជចន្លុះ ឱ្យចោរចូលចុះ យកទ្រព្យទាំងឡាយ។
ស្រីមួយសើចលេងក្អាកក្អាយ ឮលេចចម្ងាយ រំលងផ្ទះបី ។
ស្មើសត្វចចាតបក្សី ចូលភូមិផងក្ដី ចង្រៃក្ដាត់ណា៎ ។
ស្រីមួយដេកដាក់កាយា ប្រះប្រែអាត្មា ឱ្យខ្នងទៅប្ដី ។

១១០- ទុកស្មើពស់ក្រោយអប្រិយ ឡើងផ្ទះឥតបី ឥតបើគណនា ។
ចង្រៃកាចក្រៃពុំជា នឹងព្រាត់ប្រាសគ្នា ពុំបានវែងឆ្ងាយ ។
ស្រីមួយសក់វែងអន្លាយ រំសុសរំសាយ សក់សោតរេរា ។
នៅមាត់អណ្តូងមាត់ទ្វារ បីដូចមជ្ឈរា ឆ្មាលាក់ក្រចក ។
ចង្រៃឥតបីបើរក រេរាសំកក មិនចុកសក់ងាយ ។
១១៥- ស្រីមួយដើរទៅទាត់ជាយ ឮលាន់ស្មើរផ្គាយ ប្រថពីសន្ធឹក ។
សំពត់ដាច់ដាចមិននឹក ដើរឮគគឹក ស្មើសួររន្ទះ ។
ញាំញៀដំណើរលេះ ដាក់ជើងលើផ្ទះ គគ្រាំគគ្រេង ។
កក្រើកផ្ទះទាំងបីល្វែង ដូចកលគេសែង របស់ចេញទៅ ។
ស្រីមួយឃើញទ្រព្យនៅផ្លូវ កន្លងហួសទៅ មិនចាប់ចេញទុក។
១២០- ពុំចេរចំណោរទៅមុខ ពុំចេះដាក់ទុក រាយរាល់តែល្វែង។
ទ្រព្យនោះរលោះចេញឯង ចង្រៃទាស់ទែង ធ្វើឱ្យអន្តរាយ ។
ទោះឆីចំណីនូវបាយ លបលួកកកាយ ពមពុំសណ្តាប់ ។
កូនអើយនេះហើយចូរស្តាប់ ហៅក្តីឱបទ្រព្យ ទាំងដប់ប្រការ ។
ឱ្យចៀសអស់ទាំងនេះណា ឱ្យរៀនលក្ខណា ទាំងប្រាំពីរផង ។
១២៥- គឺព្រះមានបុណ្យកន្លង ទេសនាចែងចង ជាបទគាថា ។
មួយមាតុមួយមិត្តភរិយា ភាតុភរិយាជា ទាសភរិយាផង ។
ទាំងបួនប្រសើរឥតហ្មង គួរឱ្យចាំចង ទុកក្នុងអង្គា ។
រីឯហៅមាតុភរិយា ប្រពន្ធនោះជា លោកទុកស្មើម្តាយ។

ចរិតបីប្រការក្នុងកាយ មួយចង់ខ្វល់ខ្វាយ ប្រយោជន៍ឱ្យប្ដី ។
បានថ្កើងរុងរឿងឮល្បី មិនឱ្យអាប់ប្ដី ឱ្យបានស័ក្តិយស ។
មួយបើប្ដីស្លៀកពាក់ចាស់ យកថ្មីឱ្យផ្លាស់ ចាស់ស្លៀកខ្លួនឯង។
ចេះរៀបសណ្ដាប់តាក់តែង ចំណីផងស្ងែង រកមកឱ្យប្ដី ។
មួយបើប្ដីឈឺថ្កាត់អ្វី ព្រួយប្រឹងមើលប្ដី រកថ្នាំសង្កូវ ។
រកពេទ្យមេមត់នូវគ្រូ គ្រោះយាមគន់គូរ មើលប្ដីឱ្យជា ។
រីឯហៅភាតុភរិយា ប្រសើរសោភា ប្រពន្ធស្មើបង ។
នោះមានចរិតពីរផង ដូចប្អូននិងបង ចិត្តមូលមួយប្រាណ ។
មួយធ្វើឱ្យប្ដីក្សេមក្សាន្ត របស់ប្ដីបាន ចេះទុករក្សា ។
មួយទោះពាក្យអ្នកណា គេតិះដៀលថា ស្រដីពីប្ដី ។
ពុំត្រូវអាស្រូវអប្រិយ ចេះការកេរ្ដិ៍ប្ដី បែរបានជាសុខ ។
ទោះបីបើប្ដីមិនទុក្ខ គិតឱ្យបានសុខ យកខ្លួនធានា ។
មួយសោតឯមិត្តភរិយា មានចរិតជា បីប្រការមិញ ។
បីដូចកលមិត្តសំឡាញ់ មានចិត្តអស់អញ មិនឱ្យមានហ្មង ។
បីដូចកលប្អូននិងបង ប្រាសយូរលង់ហោង ទើបមកជួបគ្នា ។
មានចិត្តប្រតិព័ទ្ធមហិមា ត្បិតបានជួបគ្នា មិនឱ្យមានហ្មង ។
មួយមានមារយាទកន្លង ទោះឃើញប្រុសផង មិនស្អៀងចិត្តទៅ។
រីទាសភរិយានោះក្ងូវ ក្នុងមាត្រាត្រូវ ប្រពន្ធខ្ញុំប្ដី ។
ចរិតប្រាំបីប្រការទ្មី មួយចិត្តខ្លាចប្ដី ក្រែងប្ដីវាយដេរ ។

ប្រុងចិត្តការគិតខ្មាសគេ    មិនឱ្យប្ដីដេរ    បន្ទោសខ្លួនបាន ។
ទោះប្ដីខឹងក្រៃប៉ុន្មាន    មិនចេះហៅហាន    ឆ្លើយឈ្លោះតមាត់។
មួយទោះប្ដីនោះកាចក្ដាត់    ខឹងផល់វាយវាត់    ដេរចោរជកទង ។
មិនហ៊ានឆ្លើយឈ្លោះរំលង    តតបទៅផង    ក្រែងពួកេរ្តិ៍ឆ្ងាយ ។
មួយចេះប្រដាប់រៀបបាយ    ប្ដីដើរជិតឆ្ងាយ    មិនហ៊ានបរិភោគ។
អត់ចាំទំរាំប្ដីមក    ជួបជុំទើបយក    បរិភោគផងគ្នា ។
នេះឯងហៅទាសភរិយា    សម្ដេចភគវា    ទេសនាប្រោសប្រាប់ ។
បើអស់ស្រីណាបានស្ដាប់    យកទុកជាច្បាប់    ក្នុងប្រាណសព្វថ្ងៃ។
លុះអស់អាយុក្សិណក្ស័យ    បានទៅកើតពួ    តុសិតសួគ៌នាយ ។
នឹងបានក្សេមក្សាន្តពណ្ណរាយ    សេពសុខសប្បាយ    និរទុក្ខភយា ។
រីឯប្រពន្ធពុំជា    ពេជ្ឈឃាតភរិយា    ចរិតមានបួន ។
កុំឱ្យយកទុកក្នុងខ្លួន    ឱ្យចៀសចេញជួន    កើតកម្មវេរា ។
មួយចិត្តគំនិតចងជា    ឆ្លាស់ឆ្លើយបំពារ    បំពានឱ្យប្ដី ។
ប្រទូសរឹងរូសខ្វូវខ្វី    មិនចេះចាញ់ប្ដី    ថាឯងគ្រាន់បើ ។
ឆ្លើយឆ្លងស្វរសងបណ្ដើរ    ចង់ឈ្លោះឱ្យស្មើ    ឱ្យលើសប្ដីវិញ ។
មួយមិនចង់ធ្វើបំពេញ    បង្គាប់ប្ដីវិញ    ឱ្យផ្ដើងខ្លួនឯង ។
អាងចេះដៀលតិះពុំក្រែង    ឱ្យប្ដីស្ដាប់ឯង    ដោយចិត្តអន្ធពាល។
មួយមានចិត្តនោះស្រើបស្រាល    ចង់ត្រេកត្រអាល    ចោរពេញមុខប្ដី ។
មួយចិត្តទ្រឹស្ដទ្រុស្ដអប្រិយ    ចង់សម្លាប់ប្ដី    ស្រឡាញ់ប្រុសទៀត ។

| | | |
|---|---|---|
| គិតកាប់សម្លាប់បងមៀ្យត | នឹងយកប្រុសទៀត | ធ្វើប្តីមរណា ។ |
| រីឯសត្រូវភរិយា | ចរិតពុំជា | ប្រាំពីរប្រការ ។ |
| មួយមិនខ្លាចប្តីអាត្មា | បង្គាប់ត្រង់ណា | ពុំធ្វើតាមចិត្ត ។ |
| ១៧០- មួយទ្រឹងទ្រមឹងស្ងៀមស្ងាត់ | ប្តីសួរបីម៉ាត់ | ពុំស្រដីផង ។ |
| មួយប្តីស្រដីគន្លង | ប្រដៅច្បាប់ផង | ពុំចូលចិត្តស្តាប់ ។ |
| មួយមិនចង់ឱ្យប្តីគាប់ | មិនចង់ប្រដាប់ | ឱ្យប្តីថ្កុំថ្កើង ។ |
| មួយទោះនឹងស្រដីឡើង | ពាក្យធំចចើង | ចចេសនឹងប្តី ។ |
| មួយទោះប្តីលោះខ្ញុំស្រី | វាបម្រើប្តី | មិនឱ្យអាក់អន់ ។ |
| ១៧៥- ឃើញគាប់រឹងស្អប់ខ្ពាញ់ក្នាន់ | ក្នុងចិត្តប្រចណ្ឌ | ជេរថានាយអាយ។ |
| មួយត្បិតប្តីមានសប្បាយ | ហួរហែកសុសសាយ | ឱ្យប្តីអាស្រូវ ។ |
| រីចោរភរិយានោះកូវ | ចរិតពុំត្រូវ | មានបីប្រការ ។ |
| មួយចង់ចាយទ្រព្យប្តីណា | ឱ្យខូចអសារ | មិនគង់ជាល្អ ។ |
| មួយប្តីឃ្មាតខ្មីខ្មំរក | របស់បានមក | មិនថែទាំទុក ។ |
| ១៨០- លួចឱ្យទៅម្តាយឪពុក | ប្តីសួររកមុខ | មិនប្រាប់ឡើយណា។ |
| មួយខ្ជិលមិនចង់ធ្វើការ | កុហកមុសា | ថាឯងរវល់ ។ |
| ដេកលេងចំខែងអស់កល | លុះប្តីគេយល់ | ពុតធ្វើជាឈឺ ។ |
| ទទូរដេកថ្ងូរហ៊ឺៗ | ប្តីហៅមិនឮ | ពុតចង់តែស្លាប់ ។ |
| នេះហៅប្រពន្ធពុំគាប់ | ស្រីណាកាន់ខ្ជាប់ | ពុំដែលរសាយ ។ |
| ១៨៥- លុះអស់អាយុក្ស័យក្ស័យ | ធ្លាក់ទៅអបាយ | ទាំងបួនចំពូក ។ |

តែងនឹងរងទុក្ខរងសោក　　រំដោះរួចមក　　កើតជាមនុស្សឡើយ។
ហេតុអកុសលនេះហើយ　　ត្បិតខ្លួនឥតត្រើយ　　ធ្វើខុសគន្លង ។
ខុសវត្តប្រតិបត្តិឆ្គាំឆ្គង　　មិនរៀនមិនរង　　ខុសនឹងច្បាប់ស្រី ។
មាក់ងាយនោះមានប្រាំបី　　មានក្នុងបាលី　　ព្រះធម៌លោកថា ។
មាក់ងាយមួយនោះឯងណា　　ត្បិតប្តីពិការ　　មិនបានមួនមាំ ។
ទឹងស្អប់ធុញថប់មិនទ្រាំ　　មិនមានរកថ្នាំ　　គ្រូគ្រោះមេមត់ ។
មើលប្តីឱ្យជាឆាប់ផុត　　ទឹងវិញមិនអត់　　បន់ឱ្យប្តីស្លាប់ ។
មាក់ងាយមួយប្តីខ្សត់ទ្រព្យ　　គ្មានកេរ្តិ៍កោះគាប់　　ស្មើនឹងអាត្មា ។
ដៀលត្មះថាប្រាសដោយសារ　　ព្រោះខ្ជិលធ្វើការ　　ទើបគ្មានរបស់ ។
មាក់ងាយត្បិតប្តីអប្បយស　　ឯងត្រកូលខ្ពស់　　ពូជពង្សពុំស្មើ ។
ឆ្មើងខ្លួនឱ្យប្តីបម្រើ　　ឈ្លោះឡើងហើយដើរ　　ដៀលត្មះពូជពង្ស ។
មាក់ងាយមួយត្បិតប្តីល្ងង់　　ខ្លៅខ្លួនទ្រមង់　　ទ្រមក់យឺតយូរ ។
ដៀលត្មះពុំចេះអាស្រូវ　　សម្តីខ្មោះខ្វូរ　　មិនក្រែងប៉ុនសក់។
មាក់ងាយមួយប្តីអាក្រក់　　សាច់ខ្មៅប៉ប៉ក់　　មុខអុតស៊ីសុស ។
កន្ទ្រួលរោងរលក្រអុះ　　សក់ស្កាញស្កូវសុស　　ពោះធំប៉ុនពាង ។
ខ្លួនឯងចិញ្ចែងរូបរាង　　ខ្លួនសល្អជាង　　ថាប្តីមិនសម ។
មាក់ងាយមួយប្តីមិនទំ　　ធ្វើការលេលាំ　　ខ្ជែឡដើរលេង ។
ឆ្លៀតឆ្លើយបោះពាក្យគគ្រេង　　ឈ្លោះដេរមិនឈ្វេង　　គិតខុសមាត្រា ។
មាក់ងាយមួយប្តីផឹកស្រា　　ស្រវឹងចោលការ　　ដើរលេងតែគោ ។

២០៥- ពាក្យក្អេងរាំច្រៀងឡោៗ ឱ្យឆ្អែព្រុសឆោ ផ្អើលភ្ញាក់កូនចៅ។
ឮមាត់ប្តីហើយខឹងក្តៅ ប្រទេចដើរទៅ តាមដោយចិត្តខ្ញាញ់ ។
មាក់ងាយមួយទៀតនោះមិញ ត្បិតប្តីស្រឡាញ់ លល្ងកប្រឡែង ។
មួលបិចចាក់ចុចជាល្បែង មិនមានកោតក្រែង បានចិត្តដើរវិញ ។
ត្បិតតែយល់គេស្រឡាញ់ ស្រដីផងមិញ គំរោះគំរើយ ។
២១០- ធ្វើខ្ញាញ់បែរចេញព្រងើយ គេនឹងកន្តើយ ក្និចក្នក់មាយា ។
ពុំបានក្សេមក្សាន្តនឹងគ្នា មាក់ងាយនេះជា គម្រប់ប្រាំបី ។
កូនអើយនេះហើយច្បាប់ស្រី ឱ្យកូនពិសី រករៀនរក្សា ។
យកទុកក្នុងអង្គអាត្មា ប្រសើរក្តាត់ណា កើតសុខស្តួស្តី ។
ប្រសើរទាំងនាលោកិយ ទោះបរលោកក្តី សឹងលុះប្រាថ្នា ។
២១៥- ទោះចិត្តគន់គិតសច្ចា ជាពុទ្ធមាតា សឹងបានបរិបូណ៌។
ដូចចិត្តឆាប់ឆុតពុំយូរ កបកើតសម្បូរ សម្បត្តិទ្រព្យផង ។
កើតយសខ្ពង់ខ្ពស់កន្លង យឺនយូរឥតហ្មង ដូចក្តីប្រាថ្នា ។
ច្បាប់នេះឧត្តមថ្លៃថ្លា ទោះស្រីឯណា ឮហើយមានភ័ព្វ ។
ជាល្អកម្របានស្តាប់ ស្តាប់ហើយចូរចាប់ ចូរចាំគ្រប់គ្នា ។
២២០-បានដល់មគ្គផលសួគ៌ា ប្រសើរសោភា ចូលចាំកុំភ្លេច ។
ចរចាអស់អាថ៌ពាក្យពេចន៍ ពាក្យពិតកាព្យកិច្ច បរិបូណ៌ប្រពៃ ។
ប្រាជ្ញប្រែរីឯនាមនៃ ខ្ញុំឈ្មោះ **ម៉ឺន-ម៉ៃ** មែនមានសទ្ធា ។

WAT KHEMARARATANARAM

មានចិត្តក្លួចគិតកាព្យ    កបកើតជ្រះថ្លា    ត្រេកត្រង់កុសល។
សច្ចាប្រាថ្នាមគ្គផល    ផុលផុសឃោបល់    លេចលើកទុកទៅ ។
២២៥-ទោះបីសេចក្តីខុសត្រូវ    សូមទានតម្រូវ    តម្រង់ឱ្យផង ។
កុំត្មះតិះដៀលឡើយហោង    សូមសាងផលផង    ទុកតសាសនា ។
សម្រាប់ជាច្បាប់មាត្រា    សូរេចបការា    បរិបូណ៌ចែងចប់។

**(ចប់)**

# ច្បាប់ប្រុស

បណ្ឌិត ម៉ៃ រៀបរៀង

## បទព្រហ្មគីតិ

១- នេះបទព្រហ្មគីតិ ពីព្រេងព្រឹទ្ធទុកទូន្មាន
ចែងចងជានិទាន ទុកគ្រាន់មើលជាច្បាប់ថ្មី ។
ឱ្យអស់កូនចៅក្រោយ ស្តាប់កុំឱ្យភ្លេចស្មារតី
ប្រដៅទាំងប្រុសស្រី យកទុកខ្លួនគ្រប់អាត្មា ។
ធម្មតាកើតជាមនុស្ស ទោះស្រីប្រុសក្រណាស់ណា
ក្រគិតក្នុងចិន្តា ឱ្យបានដឹងសមនិងគួរ ។
នឹងអស់ញាតិសន្តាន សោះគេមានពាក្យថាជួ
កុំឆ្មើងកុំតែងតួ ធ្វើកំប៉ោងកុំពាក្យធំ ។
៥- នឹងដើរដូចភុជង្គ ឱ្យឱនអង្គអាចបារម្ភ
ឱ្យត្រូវនឹងច្បាប់ក្រម គួរប្រតិបត្តិកុំឱ្យឆ្គង ។
រៀនបទរៀនបាទចាស កុំប្រឡោតលើរៀមច្បង
ស្រដីនឹងអ្នកផង ពាក្យឱ្យគួរកុំឯងវ៉ី ។
អឺអើអញដាច់សាច់ ឆ្គងពាក្យពេចន៍គេស្រដី
ដើមដៀលឱ្យអប្រិយ ស្រដីថាកូនអត់ពូជ ។

ចាស់ទុំមិនប្រដៅ ជេរកូនចៅទើបវាខូច
គេថាកូនឥតពូជ មិនដឹងច្បាប់និងចាស់ទុំ ។
គេដៀលដល់ម៉ែឪ កេរ្តិ៍អាស្រូវស្អុយរហ៊ុំ
គេស្តីដើមជៀវជុំ ដំនៀលនោះដល់មកចាស់ ។
១០- កុំកាចកុំស្លូតពេក កុំចំអៀករៀនរហ័ស
កុំខ្លាចកុំហ៊ានណាស់ ឱ្យរំពឹងរំពៃគ្រប់ ។
ទោះដេកឱ្យរហ័ស ភ្ញាក់មុនចាស់ដោះឡើងលុប
មុខមាត់មើលឱ្យគ្រប់ ទ្រព្យរបស់សឹមដេកវិញ ។
ស្លាម្លូស៊ីឱ្យច្រៀក កុំបីបៀកទាំងមូលមិញ
តូចធំឱ្យច្រៀកចេញ តាមពាក្យចាស់ថាអភ័ព្វ ។
ដេកយប់កុំដេកយូរ ហើយទទូរដូចគេងាប់
សម្លត់ស្លៀកឱ្យខ្ជាប់ កុំឱ្យអាក្រាតក្រៅខ្លួន ។
នឹងដេកកុំទ្រមក់ ឱ្យលង់លក់ក្រៅពីក្បួន
បើភ្ញាក់ឱ្យដឹងខ្លួន ឡើងអង្គុយកុំមាត់ខ្លាំង ។
១៥- ប្រែប្រាណប្រុងវិញ្ញាណ ខ្លាចក្រែងមានចោរចិត្តខ្លាំង
ប្រួញប្រាណប្របជញ្ជាំង ជញ្ជូនទ្រព្យលួចយកចេញ ។
បើឥតមោះមន្ទិល កុំឱ្យខ្ជិលដេកទៅវិញ
ភ្ញាក់ហើយឱ្យក្រោកចេញ រកជក់ថ្នាំស៊ីម្លូស្លា ។

ទោះពេលពន់ព្រលប់ គន់ឱ្យគ្រប់ទ្រព្យនានា
កាំបិតខាងអាត្មា ឱ្យសិតទឹកដាក់ចុងជើង ។
ប្រអប់ដាក់ទឹមស្មា ថ្វាយទេព្តារក្សាយើង
ហើយឱ្យបំពក់ភ្លើង នៅក្រានក្រៅកុំឱ្យដាច់ ។
កុំឱ្យអស់រលីង រលត់ធេងហើយថាភ្លេច
សព្វថ្ងៃមើលកុំដាច់ កុំដើរយកពីផ្ទះគេ ។
ថែទាំមើលជើងក្រាន ឱ្យឧសមានកុំទំនេរ
បង្កាត់បង្កើតកេរ្តិ៍ កុំប្រហែសឱ្យស្ងួនឡសុង ។
ប្រយ័ត្នក្រែងក្រងាយ ពុំសប្បាយឈឺពោះពុង
បង្កាត់កំដៅអង្គ អុជបំភ្លឺមើលនេះនោះ ។
មានកាលយប់ងងឹត ភ្លេចមិនគិតជួនកូនជុះ
គ្មានភ្លើងអុជចន្លុះ ក្រានរលុះរលត់ធេង ។
រត់រកភ្លើងសស្រោក់ ព្រួយលំបាកតែខ្លួនឯង
ហេតុខ្ជិលពុំគិតក្រែង ក្រយប់ថ្ងៃព្រួយដើរឆ្ងាយ ។
ហើយឱ្យថែទាំទឹក ទោះយប់ព្រឹកកុំគិតងាយ
ដងដាក់ក្អមរាត់រាយ សព្វពួចពាងអាងអុងធំ ។
កុំឱ្យស្ងួតក្អមធេង អស់រលីងពីពាងធំ
គ្មានសោះនោះមិនសម ជួនក្រែងក្រងាយយប់ថ្ងៃ ។

ទោះដើរទៅឆ្ងាយជិត កាន់កាំបិតកំដរដៃ
ក្រែងមានមែកឈើព្រៃ កាប់កាន់មកធ្វើជាឧស ។
ជូនកាលក្រែងបន្លា មុតអាត្មាគ្រាន់ចាក់ជួស
ជាគ្រឿងគ្រប់មិនខុស ការសត្រូវទោះឆ្មាឆ្កែ ។
ដើរព្រៃឱ្យមើលលើ ឃើញស្លឹកឈើជាបន្លែ
កាប់កាន់កុំដៃទទេ អង្គុយគន់មើលឆ្វេងស្តាំ ។
ក្រែងមានឈើព្រៃងាប់ គួរកាច់កាប់យកជាថ្នាំ
ផ្ញើក្រានគ្រាន់ដណ្តាំ បាយបានឆ្អិនឆាប់ដូចចិត្ត ។
៣០- សោះស្រីស្រដីបាន បើឧសមានមិនព្រួយគិត
សព្វថ្ងៃប្រុងគំនិត ថែទាំទើបគង់របស់ ។
មាសប្រាក់ស្រូវអង្ករ ទុកឱ្យល្អកុំសប្បុរស
សំចៃកុំឱ្យអស់ មើលថែថ្នមខ្លួនឯងណា ។
ស្លូវស្លួចកុំឱ្យដាច់ បើវាតិចឱ្យឧស្សាហ៍
រិះរកផ្សំទៀតណា ឱ្យបានច្រើនក្រវើនទុក ។
នឹងចាយឱ្យគិតក្រោយ ទោះនឹងឱ្យៗមើលមុខ
កុំឱ្យស៊ុកគ្រលុក ទោះនឹងទុកឱ្យចំណាំ ។
រដូវធ្វើចំការ ឱ្យឧស្សាហ៍គ្រឿងគ្រាប់ដាំ
ស្លឹកគ្រៃខ្ញីគ្រប់ត្រុំ ត្រាវត្រសក់សព្វបន្លែ ។

៣៩- កុំខ្ជិលកុំប្រអូស ទៅងងូសរត់សុំគេ
គេមិនឱ្យឯងទេ តែគឺមោះព្រោះខ្ជិលដាំ ។
ទោះធ្វើស្រែចំការ ឱ្យឧស្សាហ៍មើលថែទាំ
កុំខ្ជិលកុំប្រចាំ ចបចូកជីកស្មៅរល្ងឹផង ។
កុំឱ្យបង់កម្លាំង ទោះខែប្រាំងប្រើឱ្យផង
ទឹកទៅស្រោចស្រប់ផង ឱ្យល្វតលាស់មានផ្កាផ្លែ ។
ធ្វើការកុំគិតព្រួយ ខ្លួនឯងមួយកុំត្អូញត្អែរ
ខ្លាំងខ្សោយកុំឱ្យល្ហែ ខ្លាចតែនឿយហើយមិនធ្វើ ។
ជាងយប់បិតឫស្សី ត្បាញជាល្អីតោកញ្ញើ
កុំឱ្យស្រីស្ដីលើ ឥតអំពើធ្វើលេងទៅ ។
៤០- កុំទុកដៃទទេ ជាងទំនេរបោចស្មៅព្រៅ
ខាងផ្ទះខាងលំនៅ ឱ្យវាលកាលកើតសុខា ។
ឱ្យមានក្ដីបារម្ភ ធ្វើស្រែកុំចោលចំការ
ដឹងដែកកាំបិតព្រា ទុកឱ្យជាកុំឱ្យបាត់ ។
ដេកយប់ឱ្យរាំងទ្វារ ទ្រព្យជាៗប្រុងប្រយ័ត្ន
គ្រចៀកចាំកុំភ្លាត់ កុំភ្លេចចោលមិនដឹងខ្លួន ។
ប្រយ័ត្នប្រយោជន៍យូរ ទោះលក់ដូរមើលថែថ្នួន
ទោះទ្រព្យរបស់ខ្លួន ឱ្យសួរក្ងួនសួរប្រពន្ធ ។

កុំអាងឯងជាប្រុស ចាយរបស់មិនគិតគន់
មិនដឹងដល់ប្រពន្ធ ព្រមព្រៀងគ្នាឥតបើថា ។
៤៥- ទោះបីបើបងប្អូន ពឹងរកខ្លួនទៅណាៗ
ទោះទៅលេងឥតការ ឥតគេរកដើរឆ្ងាយជិត ។
ឱ្យប្រាប់អ្នកនៅផ្ទះ កុំរលះឥតគំនិត
គេភ័យព្រួយចិត្តគិត ព្រោះមិនដឹងជាទៅណា ។
បើទៅជាមានភ័ព្វ ប្រសើរគាប់នោះឥតថា
ប្រសិនពានពស់ខ្លា ឱ្យល់ចាប់ចុកឥតគេសម ។
ទោះដើរមានដំណឹង ឱ្យរំពឹងគិតបារម្ភ
នឹងដើរៗឱ្យសម យប់ព្រលប់ឱ្យមាត់ក ។
កុំស្មៀមកុំស្ងាត់ពួន លបលាក់ខ្លួនខ្លាចមិនល្អ
ឱ្យមើលឱ្យមាត់ក ដើរឱ្យស្មោះសោះគេថា ។
៥០- ទោះខ្លួនជាប៉ុន្មាន ពាក្យសន្តានវែងមុសា
គេម៉ែមកអាត្មា តាមដំណឹងដំណើរខុស ។
កូនអើយបាកុំឆ្លោយ កុំធ្លាប់ឱ្យអាប់កេរ្តិ៍យស
ធម្មតាកើតជាប្រុស ឱ្យរករៀនច្បាប់មាត្រា ។
លោកថាហៅឆ្កួតបី មួយឆ្កួតស្រីមួយឆ្កួតស្រា
មួយឆ្កួតល្បែងពាលា លេងបៀប៉ៅធ្លូកំតាត់ ។

ទាក់មាន់ទាក់ទទា ផល់ភ្នាល់គ្នាបរបាញ់សត្វ
អន្ទាក់ដាក់បង្កាត់ ល្បែងអស់នោះមិនកំណើត ។
ធម្មតាយ៉ោនិងបៀ មិនដែលខ្មែរណានឹងកើត
មិនឮមានកំណើត មានតែលិចលង់ខ្លួនទេ ។
៥៩- ជួនកាលគេចាញ់ឯង រៀងរាល់ល្បែងតែងនឹងរេ
មានកាលឯងចាញ់គេ កុំទុកចិត្តថាឯងប៉ិន ។
ពីព្រឹកស្លៀកហូលជរ ល្ងាចស្លៀកសខ្វះចងក្បិន
ពីព្រឹកត្បូកក្បាលចិន ល្ងាចមិនទាន់ចិនដាក់ខ្នោះ ។
ជួនកាលវាចងជើង ព្យួរខ្ពស់ឡើងក្បាលដាំចុះ
ភ្នែកស្លឹងតឹងក្រញុះ វាទារប្រាក់ឱ្យបានឆាប់ ។
មើលមុខល្អតិចអ្វី មិនខ្មាសស្រីផ្សារឈរស្តាប់
មុខមិញដូចគេស្លាប់ មាត់ស្មេញស្មាញពេបដូចក្មេង ។
ស្រែកថ្ងូរអេះអ្ហយអើយ អាចិកអើយអាណិតលែង
អញរកប្រាក់ឱ្យឯង ឱ្យអាចិកស្អែកនេះបាន ។
៦០- ចិនឮព្រមស្រាយមក បណ្តើររកប្រាក់សន្តាន
តឹងទារទាល់តែបាន ទ្រព្យឱ្យទៅទើបវាលែង ។
អ្នកអាយអ្នកអើយកុំ គួរបារម្ភរាល់តែល្បែង
កុំលកុំលូកលេង គួរឱ្យវាងឱ្យវៀរសោះ ។

កុំឈរកុំឈប់ជិត ក្រែងមិនអត់បង់កេរកោះ
កុំល្បួងល្បែងនោះសោះ គួរឱ្យដោះឱ្យដើរចេញ ។
ច្បាប់នេះចាំរាល់ខ្លួន ទោះបងប្អូនមិត្តសំឡាញ់
ពឹងខ្លួនឯងឱ្យចេញ ធានាទ្រព្យគេយកទៅ ។
ឯទ្រព្យបានទៅវា ឯងធានាស្រាប់តែនៅ
វាបានទ្រព្យយកទៅ ខ្លួនឯងនៅធានាស្រាប់ ។
៦៥- ដល់គេមកតឹងទារ អ្នកធានាក៏បានឆាប់
មិនបានគេប្រចាប់ ទៅជាខ្ញុំព្រោះធានា ។
ទោះបងប្អូនធុរៈ ក្រជំពាក់គេតឹងទារ
បើមានទ្រព្យជួយជា កុំធានាណាំអ្នកអាយ ។
កូនអើយចូរបាចាំ ឪពុកផ្ដាំកុំបីណាយ
ប្រយ័ត្នរាល់រូបកាយ កុំឱ្យភ្លេចពាក្យនេះណាំ ។
មួយទៀតហៅឆ្កួតស្រី គួរកុំបីសេពកាមា
វាតែងទាញអាត្មា នាំវង្វេងភ្លេចបាបបុណ្យ ។
ភ្លេចសីលទានសូន្យសោះ ភ្លេចឃ្មាងខ្មោះដល់ជីពជន្ម
ភ្លេចទោសភ្លេចទាំងគុណ ភ្លេចទាំងការកាន់រសាយ ។
៧០- បង្កើតតែទោសទុក្ខ បើបានសុខសឹងប្រែក្លាយ
បង្កើតក្ដៅក្រហាយ ឱ្យទាស់ទែងវឹងនឹងគ្នា ។

ចងទោសគុំគង្កួន មិនគិតខ្លួនខ្លាចមរណា
មានកាលក្ដួយនិងមា គុំធ្វើគ្នាឱ្យសោះសូន្យ ។
បង្កើតតែចិត្តធំ ចៅគំនុំនឹងជីដូន
ឯបងវឹងនឹងប្អូន ម្ដាយនិងកូនគុំធ្វើគ្នា ។
រីខ្ញុំគុំកាប់ម្ចាស់ ឱ្យក្ដៅណាស់ក្នុងអង្គា
កើតទោសវឹងនឹងគ្នា ជាគំនុំពុំត្រាស្បើយ ។
មានកាលគេដាក់ឃ្នាង វាមិនរាងចាលចិត្តឡើយ
លក់ព្ញៃខ្ញុំគេហើយ មិនខ្លាចស្លាប់ផល់អាត្មា ។
៧៥- គេកាប់ដោតទាំងក្បាល មិនចេះចាលចិត្តឡើយណា
ភ្លេចខ្លួនសូន្យសោះសា នឹកតែត្រង់សេពសប្បាយ ។
រីឯកាមកិលេស កុំប្រហែសគួរឱ្យណាយ
ស្អិតណាស់ណាអ្នកអាយ អ្នកអើយកុំគិតសង្ស័យ ។
នេះឯងហៅឆ្កួតស្រី គួរកុំបីឱ្យអាល័យ
ចូរចងចាំសព្វថ្ងៃ ទុកទូន្មានអង្គអាត្មា ។
អ្នកប្រាជ្ញលោកនិទាន ទុកទូន្មានរាល់រូបា
មួយហៅឆ្កួតសុរា នោះកុំផឹកវាស្រវឹង ។
វានាំភ្លេចវិញ្ញាណ ភ្លេចសីលទានសោះសូន្យឈឹង
ផឹកហើយមិនដែលនឹង នាំចិត្តនោះឱ្យធំក្រៃ ។

៨០- ឯខ្លួនឯងតូចទេ មើលទៅគេប៉ុនមេដៃ
កម្លាំងឯងស្មើថៃ មិនកោតគេតិចឡើយណា ៗ
ក្អេងក្អាងពាក្យកក្អេ អួតពូកែបទបានស្រា
មិនមានខ្លាចនរណា ស្រដីកោងរកកលឈ្លោះ ៗ
បញ្ជោរបញ្ជៀសផ្តាស ដេរវាងវាសមិនចំឈ្មោះ
នាំហេតុតែខាងឈ្លោះ ឆ្លើយឆ្លងពាក្យឱ្យបានទាក់ ៗ
ប្រពន្ធឃើញឃាត់ទៅ ប្តីមិនត្រូវថាកុំអ្នក
ឯងវឹងលោវាយធាក់ ដោយចិត្តធំបទបានស្រា ៗ
មានការជូនស្រវឹង ពុំមានដឹងខ្លួនឡើយណ៎ា
ដើរដួលដេកផ្កាប់ផ្ងារ ស្រាតសំពត់អស់ពុំដឹង ៗ
៨៥- គេឃើញអស់ខ្មាសខ្ញុំ ក្មេងជៀវជុំសើចទ្រហឹង
ដេកដូចគេស្លាប់ឈឹង ក្អែរក្អួតពាសពេញទាំងខ្លួន ៗ
កំណើតអ្នកផឹកស្រា កុំអួតថាឯងនឹងនួន
ដឹងហើយស្រវឹងម្លួន ខ្លួនខ្សត់ទេអួតថាមាន ៗ
អ្នកស្លូតទៅជាកាច ឯអ្នកខ្លាចទៅជាហ៊ាន
ខុសត្រូវទៅបំពាន បំពុលខ្លួនឱ្យបានបាប ៗ
នេះឯងហៅឆ្កួតស្រា ក្នុងធម៌ថាពៀរដរាប
អ្នកណាផឹកហើយបាប បង់កិត្តិយសពុំសួស្តី ៗ
គួរកុំសេពសុរា នាំអាត្មាឱ្យអប្រិយ
នឹងធ្លាក់ទៅអវិចី នរករងទុក្ខវេទនា ៗ

WAT KHEMARARATANARAM

៩០- ហែអស់ជនទាំងឡាយ កុំវាយមាយក្នុងអង្គា
ចូរស្ដាប់ច្បាប់នេះណា ទុកទូន្មានខ្លួនសព្វថ្ងៃ ។
នេះឯងហៅឆ្លួតបី លោកស្រដីក្នុងធម៌ថ្លៃ
បើអ្នកណាមួយនៃ នឹងប្រាថ្នាដោយចំណង់ ។
លោកចងជាឧបមា ឱ្យអ្នកណាមួយផ្ចិតផ្ចង់
យកដែកដុលបោះបង់ ក្នុងភ្លើងក្រាននេះប្រាលឆ្អៅ ។
បើកាន់ដែកដែលដុត នោះមិនមុតមិនមានក្ដៅ
កាន់បាននោះទើបហៅ ចិត្តមុតមែនពិតគិតប្រាណ ។
នោះទើបលោកឱ្យធ្វើ នូវអំពើទាំងបីបាន
ដោយធម៌ពីបុរាណ លោកឧបមាដូច្នេះណា ។
៩៥- ចាត់ចែងតែងជាបទ ព្រហ្មប្រាកដកាលបិតា
ប្រដៅខ្ញុំនេះណ៎ា សព្វសេចក្ដីដូច្នេះនៃ ។
កិច្ចកាព្យវាយរៀបរោះ ខ្ញុំនាមឈ្មោះបណ្ឌិតមៃ
គិតចងជាសេចក្ដី ប្រដៅជនចប់ម្ល៉េះហោង ។

**(ចប់)**

# ច្បាប់ទូន្មានខ្លួន

## បទព្រហ្មគីតិ

១- មនុស្សកាចកុំប្រសព្វ　　កុំទៅភប់នឹងចោរក្លួយ
គេចាប់ចងទៅក្រោយ　　វាយបណ្ដើរយល់អប្រិយ ។
កុំគប់នឹងខ្ញុំគេ　　កុំប៉ោឡែខ្វល់នឹងស្រី
កុំជួញនឹងមន្ត្រី　　នឹងខាតទុនធនឯងហោង ។
កូនអើយឪពុកបា　　នឹងឧបមាមួយទៀតផ្គង
បាស្ដាប់គ្រាប់ត្រងរង　　ទុកទូន្មានអង្គឥន្ទ្រិយ ។
គេដើរកុំអាលបាញ់　　បើស្រឡាញ់កុំឱ្យខ្វី
សួរឱ្យស្មោះទៅនៃ　　នៅគង់ជាភ្ងាយឺនយូរ ។

៥- សួរចូលកុំឱ្យចេញ　　សួរឱ្យទិញកុំឱ្យដូរ
សាច់ញាតិឱ្យប្រមូល　　កុំស្រដីពាក្យសល់វ៉ល់ ។
មនុស្សកាចកុំបីប្រើ　　ការក្រធ្វើកុំឱ្យសល់
ចែកទានកុំឱ្យយល់　　ពាក្យបញ្ឆោះកុំឱ្យមាន ។
ពាក្យខុសកុំឱ្យស្ដាប់　　សេចក្ដីគាប់ឱ្យគិតធ្យាន
អំពើបាបកុំឱ្យមាន　　សីលនិងទានឱ្យរិះគិត ។
សីលសោតគួររក្សា　　ខំប្រាថ្នាឱ្យបានជិត
ពិបាកឱ្យគន់គិត　　រកគំនិតគិតឱ្យដល់ ។

ស្អប់គេកុំអាលថា　　មានប្រាជ្ញាឱ្យចេះយល់
ពាក្យភូតស្តាប់គួរឆ្ងល់　　មានកង្វល់កុំអាលថែង ។

១០- ពាក្យក្រកុំអាលប្រាប់　　ពាក្យឥតសព្ទកុំអាលថ្លែង
ពាក្យពិតកុំឱ្យថែង　　ពាក្យពិតស្លែងពុំគួរលាក់ ។

គេប្រាប់កុំអាលក្រោធ　　គេបញ្ឆោតកុំអាលភ្ញាក់
សឹកដេញកុំអាលបាក់　　គ្នាជំពាក់ប្រើដោះសា ។

គេរត់កុំអាលដេញ　　គេលើកចេញកុំអាលថា
សឹកដល់កុំអាលឆ្លា　　ឮវាចាកុំអាលយក ។

គេប្រើកុំអាលទៅ　　គេឱ្យហៅកុំអាលមក
គេឱ្យកុំអាលយក　　គេសង្ស័យកុំអាលថយ ។

ខ្លួនតូចកុំទំពារ　　ខ្លួនអ្នកជាកុំគិតធ្លោយ
ឱ្យគិតក្រែងក្រក្រោយ　　ខ្លួនខ្សត់ខ្សោយឱ្យបារម្ភ ។

១៥- ទំនៀមទំនឹមព្រេង　　ច្បាប់ថ្លាថ្លែងដោយក្រឹត្យក្រម
ពាក្យនេះជាឧត្តម　　ចូរបាទំៗត្រងត្រាប់ ។

សង្វាតរកស៊ីចុក　　ផ្ទួញលលក់ទិញតាមច្បាប់
ខ្សត់គ្មានឃ្លានស្ទើស្លាប់　　កុំខុសច្បាប់ព្រះធម្មា ។

មានទ្រព្យត្បិតសំណាង　　ជាតិមុនសាងទានសីលា
ទើបកើតជាតិនេះណា　　មានទ្រព្យធនត្បិតទានគេ ។

WAT KHEMARARATANARAM

បើខ្លួនមានស័ក្តិបុណ្យ បានទ្រព្យធនខ្ញុំពលរេហ៍
ធ្វើចិត្តឱ្យត្រង់ត្រៃ ជាតិទៅមុខនឹងបានទៀត ។
ស៊ីបានៗនឹងខំ លោកវាយដំគេបៀនបៀត
បំបាត់ទ្រព្យគេឆ្អៀត ខុសច្បាប់ផងមិនទេឡើយ ។
២០- ល្អតែនៅលោកិយ លុះដល់ក្ស័យជីវិតហើយ
ទល់ទុក្ខពុំដែលស្បើយ រូបវេរងរងកម្មវេទនា ។
ព្រះទ្រង់ទេសនាមក គួរតែយកទុកសិរសា
មនុស្សសត្វផងក្តីណា ពុំដែលវៀរពីក្តីស្លាប់ ។
គួរតែសាងសីលទាន នោះនឹងបានបុណ្យលាងបាប
រក្សាសីលដរាប នោះប្រសើរពេកកូនអើយ ។
អស់ទ្រព្យសម្បត្តិនៅ មិនបានទៅតាមខ្លួនឡើយ
មានតែសីលទានហើយ ទៅកំដរបរលោកនាយ ។
អស់ទាំងគ្រឿងរបស់ ខ្ញុំស្រីប្រុសផងទាំងឡាយ
សឹងខានចោលនៅអាយ ជារបស់គេរស់នៅ ។
២៥- គួរដឹងរិះគិតឲ្យាន គួរឱ្យទានធ្វើបុណ្យទៅ
ទាន់ខ្លួនជីវិតនៅ នោះប្រសើរក្រៃពេកពន់ ។
បើបានធ្វើតែបាប មិនសុភាពចិត្តកាចលន់
ធ្វើបាបមិនធ្វើបុណ្យ លែងជាតិទៅនៅនរក ។

បើបាបានធ្វើបុណ្យ បានសងគុណម្តាយឪពុក
ឲ្យទានចាំសីលសុខ នោះនឹងបានឋានសួគ៌ា ។
ខ្លួនធំខំរកស៊ី ចាស់ព្រឹទ្ធិគួរអនិច្ចា
កើតជាមនុស្សនេះណា មានវេរាពុំដែលរួច ។
មួយសោតកុំស្នេហ៍ស្និទ្ធ កុំមានចិត្តគិតកាន់កួច
ភរិយាគេកុំលួច នៅលោកិយក្តីនិន្ទា ។
៣០- ដល់ខ្លួនលែងជាតិនោះ នឹងចូលចុះនរកណា
នឹងឡើងដើមរកា- ដែកនោះធំៗខ្ពស់ក្រៃ ។
យមបាលរត់ទៅជ្រោម កាន់គ្រឿងចោមចាក់ទីទៃ
ក្អែកត្មាតទង់ជើងដៃ ចចឹកស៊ីជាអាហារ ។
មានខ្លួននោះដាចដាច់ អស់ទាំងសាច់ឈឺខ្លោចផ្សា
វាត្រូវនឹងបន្លា សឹងដែកជាមុតធ្លាយធ្លុះ ។
ហើយធ្លាក់ពីបន្លា ដើមរកាដែកធំនោះ
ធ្លាក់ចុះក្នុងទឹកខ្ទុះ ប្រែផ្សាក្តៅឥតសម្រាន្ត ។
ហើយហែលក្នុងទឹកនោះ ស្លាប់ហើយរស់លំបាកប្រាណ
ពីរពាន់ឆ្នាំទើបបាន រួចមកកើតជាមនុស្សា ។
៣៥- រួចនោះបានមកកើត យកកំណើតមនុស្សនេះណា
ហេតុកម្មពៀរវេរា កើតជាស្រីប្រាំរយជាតិ ។

រួចនោះជាខ្មៅខ្មើយ		កូនចៅអើយកុំប្រមាទ
ភរិយាគេមិនឃ្លាត		ពីនរកនោះឡើយណា ។
មួយសោតឪពុកផ្តាំ		ចូរបាចាំកុំផឹកស្រា
វានាំចិត្តពាលា		ពោលោលទន់ពន់ពេកក្រៃ ។
ផឹកស្រាជាអ្នកកាច		ពុំក្រែងខ្លាចអ្នកដទៃ
វានាំបាត់ស្មារតី		នឹងរកស៊ីបាត់ប្រាជ្ញា ។
នៅនាលោកិយហោង		អស់អ្នកផងគេនិន្ទា
លុះខ្លួនជួនមរណា		ទៅនរករងទុក្ខនៅ ។
៤០- នៅតែរងវិបាក		ខ្លួនរលាកនឹងដែកក្តៅ
អស់ថ្លើមប្រមាត់នៅ		ក្នុងពុងពោះឈើពន្លឹក ។
ដែកក្តៅឆេះជាភ្លើង		ផ្សែងផ្សព្វឡើងពួគគឹក
យមបាលសោតបំផឹក		ទឹកទង់ដែកឆេះព្រោងព្រាយ ។
ទាក់កទាញផ្តេកផ្តួល		នឹងបង្គោលដែកទាំងឡាយ
មាត់នោះឆេះព្រោងព្រាយ		ហេតុបាបបានផឹកសុរា ។
ពាក្យនេះមិនថាឯង		មានពីព្រេងព្រះទេសនា
អ្នកណាបរទារការ		សេពសុរាដូច្នេះនៃ ។
គិតគួរគួរឱ្យចាំ		សីលនានាំឱ្យល្អក្រៃ
រៀនធម៌គម្ពីរថ្លៃ		បានវៀរបាបផងនានា ។

៤៦- ហៃអស់កូនចៅអើយ    ចាំឲ្យហើយធម៌ទេសនា
អ្នកមិនផឹកសុរា    អ្នកនោះបានឋានសួគ៌ហោង ។
រកស៊ីគិតពីរក្តី[១]    គិតលោកិយបរលោកផង
ក្រែងខ្លួនជួនមកយោង    ផលជួយជូនបានសុខា ។
ច្បាប់នេះព្រះបន្ទូល    គួរតែចូលចិត្តគ្រប់គ្នា
ទូលទុកលើសិរសា    កុំបីភ្លេចដល់មួយថ្ងៃ ។
ថ្ងៃសីលរកផ្កាភ្ញី    ទៀនធូបក្តីផ្សំម្រាមដៃ
ថ្វាត់ថ្វាយព្រះរ័ត្នត្រ័យ    កុំបីដាច់ថ្ងៃមួយឡើយ ។
អ្នកណាអាចបានស្តាប់    ត្រេកត្រេងគ្រាប់ធម៌ជាត្រើយ
លុះលែងជាតិទៅហើយ    នោះនឹងបានឋានសួគ៌ា ។
៥០- ទោះបីបានកើតមក    យកកំណើតជាតិនេះណា
ប្រកបដោយប្រាជ្ញា    អង្គកាយាល្អប្រិមប្រិយ ។
កើតកបទ្រព្យរបស់    ខ្ញុំស្រីប្រុសគោក្របី
មាសប្រាក់ឥតខ្វះអ្វី    មានទូកក្តារច្រវាហោង ។
មានកេរកោះស្រែស្រូវ    ចេកអំពៅដូងស្លាផង
នោះច្រើនៗពេកហោង    សឹងលើសលន់ពន់ប្រមាណ ។

---

១ គិតពីរក្តី= គិតដំណើរពីរ ឬ រឿងពីរ គឺគិតលោកិយផង និងបរលោកផង ។ ពាក្យក្តី: ក្នុងទីនេះ សំដៅយក គតិ រឿង, ហេតុ, សេចក្តី, ដំណើរផ្លូវ ។

ពាក្យនេះស្មើខ្លួនហើយ កូនចៅអើយចូរចាំប្រាណ
អស់អាថ៌ឱវាទទាន ជាសូរេចបណ្ដាំហោង ។

៥៥- ចូររិះចូររៀនយក ជាពន្លកចិត្តចាំចង
ស្មើស្ពានចាំចម្លង ទៅដាក់ដល់ថ្នល់និព្វាន ។

**(ចប់)**

# ច្បាប់ កូនចៅ

## បទភាគគតិ

១- កូនចៅអើយស្តាប់ ឪពុកនឹងប្រាប់ ប្រដៅគ្រប់គ្នា
ចូរចាំចូរចាប់ ជាច្បាប់អាត្មា រួសរងរក្សា
ទីទៃគ្រប់ប្រាណ ។

ធម្មតាអ្នកជា អ្នកមានប្រាជ្ញា មានផៅសន្តាន
ពុំចេះអាងអួត ប្រកួតរានកាន បំពាក់បំពាន
បំពោតអួតអង្គ ។

ទោះនឹងយាត្រា ទៅទីស្ថានណា ដើរដូចកុជង្គ
សិរសាទន់ទាប សុភាពផ្គត់ផ្គង់ លំអុតឱនអង្គ
ការកេរ្តិ៍អ្នកជា ។

វីអ្នកសាមាន្យ ខ្សត់ខ្សោយសន្តាន អាប់ឥតប្រាជ្ញា
ដំណើរអែងអោង កែងកោងហត្ថា ដូចខ្ជួយសោះសា
មែនមានពិសទិច ។

៥- បំពោងបំពើត ចំកោងស្ងួយស្ងើត ពីងពិសទ្រនិច
ខ្លួនតូចត្រឡាំង កំឡាំងសោតតិច ពីងពិសទ្រនិច
ទិចតើប៉ុន្មាន ។

ធម្មតាអ្នកជួ ពុំដែលថ្លឹមត្លួ នឹងអ្នកជាបាន
ហេតុលោកការកេរ្តិ៍ ឥតពីរថ្លឹមប្រាណ លោកការសន្តាន
សន្តាប់ផៅផង ។

កូនចៅអើយចាំ ឪពុកនឹងផ្ដាំ ដោយនូវគន្លង
គាថាបាលី គិតពីព្រេងហោង ចូរចេះចាំចង
ទីទៃកុំភ្លោយ ។

ពាក្យនេះជាច្បាប់ ទូន្មានឱ្យគាប់ កូនចៅឯក្រោយ
ឪពុកឥតទ្រព្យ អ្វីគាប់ទុកឱ្យ តែពាក្យនេះដោយ
ព្រះបាលីថា ។

លោកថាភ្លើងភ្លឺ មែនពិតមោះឬ ពុំស្មើសុរិយា
លោកថាសូរ្យសែង ភ្លឺថែងវេហាស៍ មោះពុំស្មើនា
ព្រះធម៌ព្រះពុទ្ធ ។

១០- ភ្លើងភ្លឺអស់ចិត្ត អស់កាលហើយបាត់ រលាយរលត់
ព្រះសូរ្យភ្លឺឡើង ថ្មំថ្មើងប្រាកដ អាប់អស្ដង្គត
ពុំយល់រស្មី ។

រីព្រះធម៌ថ្លៃ ភ្លឺហើយភ្លឺក្រៃ នៅនាលោកិយ
ដល់បរលោកនាយ ភ្លឺឆ្ងាយបារមី រុងរឿងរង្សី
ពុំរលត់ឡើយ ។

កូនចៅអើយណា ពាក្យមួយលោកថា ស្ករឃ្មុំឯងហើយ
ផ្អែមក្រៃលែងផ្អែម ល្ហឹមល្ហែមជាត្រើយ មោះផ្អែមនោះស្បើយ
ពុំចាប់ចាំនៅ ។

តែពាក្យលោកថា លោកមានមេត្តា ទូន្មានប្រដៅ
នោះផ្អែមក្រៃលែង ស្ករឃ្មុំអំពៅ ចាំចងទុកនៅ
អស់កាលដ៏លង់ ។

លោកថាល្វាផង សម្បកក្រៅហោង ភ្លឺផ្លេកយល់យង់
រីឯក្នុងផ្លែ សឹងតែមមង់ ក្រាស់ក្រៃនៅក្នុង
នោះហោងលោកថា ។

១៥- អ្នកមួយថៃចូវ រអែរអូវ វៀចវេប្ញស្យា
បញ្ចេចបញ្ចេី ពាក្យពេីមាយា ដូចកលផ្លែល្វា
ល្អល្អះតែក្រៅ ។

មួយដូចខ្នុរណាំង សម្បកស្មោកស្មាំង បន្លាច្រូងនៅ
ឯក្នុងសឹងក្លែប ក្រអែបផ្អែមទៅ ទាល់ក្នុងឥតសៅ
រសសឹងពិសា ។

រីអ្នកមានធម៌ សប្បុរសមានអាថ៌ លោកផ្ទឹមឧបមា
ដូចខ្នុរក្លិនក្លែប ក្រអែបពិសា ក្រៅក្រាស់បន្លា
មោះក្នុងផ្អែមក្រៃ ។

មួយសោតលោកថា កន្លង់និងផ្កា ស្ពានឆ្ងាយទីទៃ
ហោតុចិត្តចង់ក្រេប ជញ្ជាបក្លិននៃ ហើរហួសច្រៀវច្រៃ
រសរកបុប្ផា ។

ដូចអ្នកមួយមាន ចិត្តនោះចង់បាន ច្បាប់ក្បួនសាស្ត្រា
ស្ទះស្វែងរកអ្នក មួយមានប្រាជ្ញា រួសរងឧស្សាហ៍
សង្វាតអាលជ្វី ។

២០- មួយនីឯរុយ រករោមសំអុយ អសោចអប្រិយ
ដូចមនុស្សអបល័ក្ខណ៍ ស្វែងស្ទះរកក្តី ពុំគិតក្រក្រី
ក្រែងក្រោយឡើងនៃ ។

មួយនីក្រមច្បាប់ លោកពុំឱ្យគ្រាប់ អំពើពុតជ្រៃ
កាលណាដូចដុះ ចាប់ចុះអាស្រ័យ ត្រង់ស្ថានណានៃ
អ្នកដើមអន្តរាយ ។

មួយនីលោកថា អំពើពុតខ្លា យល់សាច់ទាំងឡាយ
ចង់ប៉ុន្តែស៊ី ផតបីរសាយ អស់មនុស្សទាំងឡាយ
កុំគ្រាប់ពុតខ្លា ។

កើតជាមនុស្សនេះ ដូចកង់រទេះ វិលត្រូវគ្រប់គ្នា
មានកាលត្រូវគេ ល្វែឯអាត្មា ហេតុនេះលោកថា
ប្រើគ្រាប់ពុតកង់ ។

វីឈើវិស័យ ដុះនៅនាព្រៃ ខ្លះវៀចខ្លះត្រង់
ឯអ្នកនគរ ក្សត្រក្សាន្តទ្រទ្រង់ ខ្លះចិត្តទៀងត្រង់
ខ្លះខ្វៅសាមាន្យ ។

២៩- ពពួកសត្វផង សាហាវយង់ឃ្នង គេអាចញាំងបាន
ត្រង់មនុស្សសាហាវ ពោលោឈ្លានពាន លោកឱ្យប្រែប្រាណ
ចៀសចេញឱ្យឆ្ងាយ ។

កូនចៅអើយស្ដាប់ ពាក្យនេះជាច្បាប់ ប្រដៅបរិយាយ
ពាក្យនេះជាថ្នល់ តម្កល់ទុកឆ្ងាយ កូនចៅទាំងឡាយ
នាំគ្នាស្ដាប់វ៉ា ។

ហៃអស់កូនចៅ តំណក្រោយទៅ ត្រកូលវង្សា
ចូរចេះរាប់រក ស្រករគ្នីគ្នា ខុសគាប់កាចជា
អត់ឱនត្រងរង ។

ឱកូនចៅអើយ អាពុកចាស់ហើយ ពុំបាននៅផង
នរណានឹងនៅ ប្រដៅបាហោង នរណានឹងស្នង
អាពុកនេះបាន ។

តែខ្លួនទៅបាត់ ទុកពាក្យមួយម៉ាត់ ប្រដៅទូន្មាន
ពាក្យនេះអាពុក សង់ទុកជាស្ពាន ឱ្យកូនចៅបាន
ឆ្លងទៅត្រើយនាយ ។

៣០- ពាក្យមួយនេះមិញ ហេតុមិនស្រឡាញ់ មានពាក្យថាឆ្ងាយ
ទោះទូកបែកបាក់ សំពៅធ្លុះធ្លាយ ទាល់លង្កានាយ
សឹងមករកបាន ។

កូនចៅអើយគិត ផ្ចត់ផ្ចង់គំនិត រក្សាខ្លួនប្រាណ
កុំអាងស័ក្តិបុណ្យ លោភលន់ចង់បាន បំពារបំពាន
ពុំធ្វើដោយធម៌ ។

ធម្មតាជាមនុស្ស ឱ្យដឹងគាប់ខុស បុណ្យបាបឱ្យស្គាល់
ថ្វីមិនចង់បាន ចង់គ្មានអង្គាល់ ឱ្យបានដោយធម៌
នោះទើបយឺនយូរ ។

បើបាននឹងទំ លោភោវាយដំ សន្សំចាក់ចូល
ចំណេះទ្រព្យនោះ នៅពុំបរិបូណ៌ ស្មើរកប្រមូល
ទុកឱ្យគេទេ ។

កូនចៅអើយអត់ គិតក្តីកំសត់ កុំធ្វើប៉ោឡៃ
កុំអាងមានទ្រព្យ កុំត្រាប់ពុតគេ ចូរចេះរិះរេ
សាយសព្វសារពើ ។

៣៥- ធម្មតាជាស្រី កុំចង់មេត្រី សាយសព្វអន្ទើ
យកម្តេចវ័ណ្ណស្តុរ មកគរទុកលើ ស្រមោចហើយតើ
អត់ម្តេចមិនស៊ី ។

មួយដូចប្រុសខ្វោះ[១] ពាលពេញកម្លោះ ចិត្តចោរចង់ស្រី
កលមួយដូចក្អែក ចេញលួចរកឆី មិនដឹងឬអ្វី
យកពងមាន់ផ្ញើ ។

---

១- ខ្វោះ = ពាក្យបុរាណ ខ្វោះ គឺកំឡោះ ។

កលមួយសោតណា នេះនឹងឧបមា អណ្ដើកឯងតើ
ពងលាក់ជាហើយ ម្ដេចឡើយទៅផ្ញើ អស់ពាក្យពេចន៍លើ
អាអូតមហាចោរ ។

ប្រើប្រុងប្រយ័ត្ន ពាក្យពេចន៍សួរសត្យ សារស័ព្ទពំនោល
ពីរោះមធូរ បរិបូណ៌ពាក្យពោល កុំអាលខឹងឃោរ
ចារចែងភាសា ។

កុំអាលកន្ទើង កុំស្ថិតខិតឡើង លើលោកព្រឹទ្ធា
គិតការដំណៀល លោកដៀលនិន្ទា អង្គឱ្យកើតជា
និន្ទាអាស្រូវ ។

៤០- ទោះប្រុសទោះស្រី កើតនាលោកិយ លោកឱ្យគាប់គ្រូ
ក្រែងមានឆ្នេះឆ្នាប ស្រឡាបត្រង់ត្រូវ ក្រែងជួពុំជួ-
កាលកម្មវេរា ។

លោកថាឆ្កួតបី ឆ្កួតមួយនឹងស្រី ឆ្កួតមួយនឹងស្រា
ឆ្កួតមួយនឹងល្បែង អំពើពាលា ឆ្កួតនេះហៅមហា
ឆ្កួតក្រែកន្លង ។

ឆ្កួតស្រីឆ្កួតស្រា ឆ្កួតល្បែងពាលា អំពើសឹងឆ្គង
លោកពុំឱ្យសេព ឱ្យវាងជាម្ដង វាតែងឱ្យហ្មង
ភ្លេចភ្លាំងស្មារតី ។

ឱ្យភ្លេចក្ដីគាប់ ភ្លេចទាំងខ្លួនស្លាប់ ភ្លេចសាស្ត្រសួស្ដី
ភ្លេចសីលភ្លេចទាន ភ្លេចញាណវុឌ្ឍី ភ្លេចច្បាប់ប្រក្រតី
ឆ្គួតបីប្រការ ។

កុំអាងចំណេះ កុំអួតថាចេះ កុំដោយពុតពាល
កុំសមកុំសេព កុំស្រើបកុំស្រាល កុំអរកុំអាល
ត្រេកទៅដោយវា ។

៥៥- ថាបើនឹងចង់ សេពដោយចំណង់ អំពើពាលា
អាចារ្យលោកចង ជាពាក្យឧបមា ឱ្យអ្នកមួយណា
ដុតដែកឱ្យក្ដៅ ។

បើកាន់ដែកបាន នោះទើបឱ្យហ៊ាន សេពសមចូលទៅ
អំពើទាំងបី ដូចដែកប្រាលឆ្អៅ លុះកាន់មិនក្ដៅ
នោះទើបសេពបាន ។

អំពើគុណគាប់ កូនចៅអើយស្ដាប់ អាពុកទូន្មាន
រៀនគុណទាំងប្រាំ សឹងនាំរូបបាន រួមរក្សាប្រាណ
ពិតពុំឃ្លាតឃ្លា ។

កាលណាសឹកមាន ថ្មើងឯទាហាន ពន្លឹកមហិមា
កាលបើមានអាថ៌ នូវសារបញ្ហា ដោះស្រាយប្រស្នា
ថ្មើងឯប្រាជ្ញប្រាយ ។

មួយសោតកាលបើ រិះគិតនឹងធ្វើ កិច្ចការសម្មាយ
ច្រើងឯអ្នកជាង ជំនាងសុសសាយ កិច្ចការទំនាយ
ច្រើងឯហោរា ។

៥០- កាលកើតព្យាធិ រោគរោមឥន្ទ្រិយ៍ ច្រើងឯពេទ្យា
រីអ្នកទាំងប្រាំ សឹងនាំអាត្មា ឱ្យគាប់ដោយនា
ចំណោះទីទៃ ។

មួយសោតជាសង្ឃ នោះឱ្យផ្គត់ផ្គង់ តាមព្រះវិន័យ
ជាស្រីសោតផ្គត់ មារយាទប្រពៃ ជាមនុស្សសព្វថ្ងៃ
ឱ្យវៀរបាបបង់ ។

ចូរចេះដាក់ខ្លួន គួរគិតក្តីសួន រក្សាផ្គត់ផ្គង់
ស្គាល់ទៅស្គាល់នៅ ប្រាជ្ញខ្ទៅគង់ ស្គាល់វៀចស្គាល់ត្រង់
ស្គាល់ឱ្យគ្រប់ក្រៃ ។

លោកថាឱ្យត្រាប់ នូវសត្វកុកសាប់ អំពើប្រពៃ
កុំត្រាប់កុកស ភោភាវសព្វថ្ងៃ ហើរទំអាស្រ័យ
ពុំប្លែកប្លែងប្រាណ ។

លោកថាដែកផង ហៅរឹងកន្លង គេដុតដំបាន
រូសកោសជាការ តាមចិត្តប្រមាណ ពុំដែលនឹងមាន
ប្រកែកឡើយណា ។

| | | | |
|---|---|---|---|
| ៥៩- | ដំរីក្នុងព្រៃ | សាហាវហ៊ានក្រៃ | មមីសោះសា |
| | គេទាក់មកបាន | ផ្ទះផ្សាំងជិះជា | ពុំដែលនឹកថា |
| | | ប្រកែកមិនទៅ ។ | |
| | គ្រង់ពាលប្រទូស្ត | ប្រទះរឹងរូស | ពុំលុះប្រដៅ |
| | រឹងលើសពីដែក | នឹងដំរីនៅ | ដោយនាកម្លៅ |
| | | កម្លាំងមោហា ។ | |
| | លោកថាក្អែកពិត | យកម្តេចមណីរតន៍ | កែវទៅបូជា |
| | ម្រឹគជាតិវិស័យ | ពាក់ម្តេចជដា | ធម្មជាតិជាស្វា |
| | | ស្លៀកម្តេចសំពត់ ។ | |
| | យកម្តេចព្រះធម៌ | ជ្រៅជ្រះមានអាថ៌ | ប្រពៃវិសុទ្ធ |
| | ប្រដៅពាលា | ប៉ោខ្មៅស្មុគទ្រុឌ | យកម្តេចឯមកុដ |
| | | បំពាក់ពានរ ។ | |
| | លោកថាផ្កាផង | ពិដោរពិតហោង | បុស្បាបវរ |
| | ក្លិនក្លែបត្រឡប់ | សាយសព្វទិសករ | ហើយរោយកេសរ |
| | | បាត់បុស្បគន្ធា ។ | |
| ៦០- | តែអ្នកមួយទៀង | ពាក្យពេចន៍ឥតល្មៀង | ចម្រើនមេត្តា |
| | នោះក្លូវក្រអូប | ក្រៃលែងក្លិនផ្កា | ទូទៅនានា |
| | | ដោរដល់សួគ៌ស្ថាន ។ | |

រីអសោចលាមក ហៅស្អុយអាក្រក់ ពេកពន់ប្រមាណ
មោះស្អុយនោះសៀ្វយ ស្ហែស្ហើយគ្រាន់ក្បាន្ត លុមទប់ទល់បាន
ពុំទាន់ជាអ្វី ។

តែអ្នកមួយក្បូរ រអែរអូ្វរ ចិត្តបាបមួទូ
កុហកភរភូត បញ្ឆោតស្រដី នាំពាក្យអប្រិយ
បំបែកមិត្តគេ ។

នោះក្បូរអាក្រក់ ស្អុយក្រៃលែងលាមក ពុំមានល្ហើយល្ហែ
ដល់បរលោកសោត ទៅនៅនិរយេ នរកឯងង
ទល់ទុក្ខវេទនា ។

កុំពារកុំពាន កុំយល់គេមាន ប្រណែនឫស្យា
ចូរវៀរពាក្យស្លែង ថ្លែងទៅពុំជា វៀរពាក្យមុសា
បានបុណ្យក្រាស់ក្រៃ ។

៦៥- កូនចៅអញអើយ ចាំទុកជាត្រើយ គ្រប់ខ្លួនទីទៃ
ដើរដោយគន្លង ផ្លូវផងវិស័យ កុំពារពានព្រៃ
ជាន់ជាប់បន្ទា ។

ក្រកិច្ចក្រកល ក្រដឹងក្រយល់ ក្រកិច្ចធានា[១]
ក្រវៃច្នៃទាស់ ឆ្លើយឆ្លាស់លោកា ក្រជាមាតា
បិតាស្ងួនគ្រង ។

---
១- ច្បាប់ខ្លះថា ក្រចិត្តសទ្ធា ។

ក្រពាក្យពីរោះ ក្រចិត្តអាចស្មោះ ដឹងទុក្ខសត្វផង
ក្រអត់ក្រឱន ស្រឡាញ់ស្លូនត្រង់ ក្រពាក្យឥតឆ្លង
ល្មមនឹងចិត្តគេ ។

ក្រមានពាក្យសត្យ ក្រចិត្តអាចកាត់ ស្រឡះពីស្នេហ៍
ក្រធ្ងន់គំនិត ក្រគិតគុណគេ ក្របានជាមេ-
បាគេទាំងឡាយ ។

ក្តីច្បាប់នេះក្រ នរណាអាចយក៍ ទុកខ្លួនសម្ចាយ
ដ៏លោកនេះគាប់ នៅបានពណ្ណរាយ ដល់បរលោកនាយ
សោយសុខស្រេចស្រាប់។

៧០- ឱពុកចាស់ហើយ អស់កូនចៅអើយ នាំគ្នាស្តែងស្តាប់
ពាក្យពិតទូន្មាន ប្រធានគ្រាន់គ្រប់ ស្មើទ្រព្យសម្រាប់
ទុកឱ្យគ្រប់គ្នា ។

ចូរចាំកុំភ្លេច ទូន្មាននេះស្រេច ស្មើខ្លួនហើយណា
ចាំចងឱ្យខ្ជាប់ ជាច្បាប់អាត្មា ស្ងួរេចអក្ខរា
សុភាសិតហោង ។

**(ចប់)**

# ច្បាប់ ពាក្យចាស់

## បទព្រហ្មគីតិ

១- ពាក្យចាស់ពាក្យពីព្រេង ទោសខ្លួនឯងមើលពុំយល់
ទោសគេតូចសោតសល់ រមិលយល់ប៉ុនទាំងភ្នំ ។
ចូលព្រៃសត្វសាហាវ រកអំពាវ(១)គ្នាមកជុំ
ដល់បានស្ករទឹកឃ្មុំ ពូនក្នុងផ្ទះឆីម្នាក់ឯង ។
បានហើយចង់បានទៀត ឆ្លៀតហើយឆ្លៀតពុំគិតឈ្វេង
មើលយល់តែម្នាក់ឯង មិនយល់គេឯទៀតផង ។
នឹងស៊ីចង់ពិសា ខ្ជិលទំពារឱ្យម៉ដ្ឋហ្មង
យល់នាមថាជាមង យល់ឯផងថាជាក្លួយ ។
៥- យល់តាថាជីដូន យល់ឯកូនថាជាក្មួយ
យល់ពីរថាជាមួយ យល់ឯព្រួយថាជាសុខ ។
យល់ទោសថាជាគុណ យល់ឯបុណ្យថានរក
យល់ល្អថាអាក្រក់ យល់លាមកថាជាផ្កា ។
ស្លៀកស្បង់មិនកោរសក់ ឆ្លុះកញ្ចក់ធ្មេចនេត្រា
យល់សេះថាជាលា យល់គជាថាកណ្ដុរ ។
នេះពាក្យលោកពីព្រេង អ្នកណាឈ្វេងប្រាជ្ញាយល់
ឃើញថ្លុកកុំថាថ្នល់ ក្រែងកំហល់កំហុសមាន ។

---

១- ច្បាប់ខ្លះថា រកកំព្រាវ បានន័យថា អំពាវនាវ ។

អ្នកប្រាជ្ញកាន់ពាក្យទៀង កុំលំអៀងពាក្យបុរាណ
កុំដើរផ្លូវបំពាន ពាក្យអ្នកចាស់លោកដៀលថា ។
១០- ពាក្យនេះពីព្រេងព្រឹទ្ធ គួរឱ្យគិតពិចារណា
កុំអួតអង្គអាត្មា ថាចំណេះចំណាំមាន ។
ដេកយប់កុំដេកយូរ ខ្លាចក្ដីទូជីនដល់ប្រាណ
បើស៊ីកុំតាមឃ្លាន គិតប្រមាណគ្រប់គ្នីគ្នា ។
លើកដាក់តាមកម្លាំង កុំភើចខ្លាំងឈើដល់ស្មា
ប្រើគេប្រើឱ្យត្រា កុំស៊ាំស៊នរនចៅរៅ ។
ទោះគិតកុំរួសរាន់ គិតឱ្យគ្រាន់ទើបដើរទៅ
កុំឱ្យមានអាស្រូវ កើតជំនៀលដល់អាត្មា ។
កុំយកឆ្អិនជានៅ កិច្ចក្នុងក្រៅមានតម្រា
កុំអាងឯងប្រាជ្ញា ចោលច្បាប់ក្បួនលោកព្រេងនាយ ។
១៥- ស្រដីឱ្យស្រួលស្រេច គិតសេចគ្រេច[១]កុំគិតងាយ
រំពឹងឱ្យវែងឆ្ងាយ យល់លង្វែកពាក្យលោកថា ។
ពាក្យព្រេងលោកស្រដី ថាកុំបីចិញ្ចឹមខ្លា
ពាក្យព្រេងលោកឧបមា គិតត្រង់ណាធ្វើឱ្យបាន ។
កាន់កពស់ឱ្យខ្ជាប់ ខ្លាចក្រឡាប់ខាំឯប្រាណ
អួសទូកកុំឱ្យល្មាន ទឹកថ្លាសោតកុំឱ្យល្អក់ ។

---

១- សេចក្ដីភាក់ជ្រៅ ។

ស្លឹកឈើឥតកម្រើក បើកក្រើកត្បិតខ្យល់បក់
ទឹកថ្លាល្អឹកបើល្អក់ ត្បិតរលកខ្លាំងសោះសា ។
យល់តូចកុំខិតខំ គួរសន្សំយកជាគ្នា
បានច្រើនកុំខំពារ សន្សឹមកក្បៀណតិចៗទៅ ។

២៧- អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ
អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនូវសំប៉ាន ។
អ្នកខ្ពស់រក្សាទាប ដោយសភាពធម៌បុរាណ
អ្នកឆ្អែតរក្សាឃ្លាន នាអ្នករុងរក្សាឆ្នារ[១] ។
រក្សាទៅមុខរឹង ឥតកំដឹងអស់អម្បាល
ចំណោចេរកាន់កាល ដូចរបងស្រាស់បន្លា ។
កុំឆ្អែតពេកតែឯង មិនគិតក្រែងអស់គ្នីគ្នា
គេឃ្លានៗផ្ទៃផ្សា ឱ្យធីរ៉ាបានឆ្អែតផង ។
កុំមានចិត្តលលើ ពឹងក្រពើឱ្យចម្លង
កុំកាច់ឧសរបង រាំងចំណារឯអាត្មា ។

២៥- មានទូកហើយមានថ្មោល មានបង្គោលមានយុថ្កា
ទាំងព្រួរទាំងច្រវា ក្រជីងចាប់ដោយនូវគ្រប់ ។
ប្រយ័ត្នក្រែងព្យុះខ្យល់ បក់បោកដល់នឹងទល់ទប់
ប្រយ័ត្នប្រយោជន៍គ្រប់ ទើបហៅជាក់ជាគំនិត ។

---

១-អ្នករុងរក្សាឆ្នារ បានន័យថា អ្នកមានរក្សាអ្នកក្សត់ ។

ពាក្យព្រេងគិតគួរចាំ ជាបណ្ដាំប្រដៅចិត្ត
ពាក្យព្រេងពាក្យព្រេងព្រឹទ្ធ មុខគួរគិតៗឱ្យគ្រាន់ ។
ពាក្យនេះជាសណ្ដាប់ ទុកជាច្បាប់ទៀងជាក់ស្បាន់
ពាក្យនេះជាកំណាន់ កំណត់នៅឥតឃ្លាតឃ្លា ។
២៩- សូរេចនូវនិទាន ពាក្យទូន្មានដោយប្រការ
អម្បាលនេះឯងណា ចាំទុកកាយគ្រប់គ្រាន់ហោង ។

**(ចប់)**

# ច្បាប់ ហៃមហាជន

## បទព្រហ្មគីតិ

១- ហៃមហាជនសប្បុរស ទោះស្រីប្រុសកបកិរិយា
គួរគិតយកប្រាជ្ញា ចងចាំជាប់ជាគន្លង ។
មានច្បាប់ពីបុរាណ លោកទូន្មានតែងទុកឱ្យ[១]
ជនជាតិនៅឯក្រោយ ចងជាច្បាប់ទុកគ្រប់ប្រាណ ។
ធម្មតាអ្នកចិត្តល្អ ពុំដែលក្រខ្សត់ប៉ុន្មាន
ទេព្តាជាប្រធាន តែងចម្រើនសុខឥតសៅ ។
បើធ្វើចិត្តអាក្រក់ ដើរលួចឆក់លោកសៅដៅ
ទ្រព្យនោះណាបាត់ទៅ ដូចអគ្គីឆេះរោលរាល ។
៥- ទេព្តានឹងផ្តន្ទា ឱ្យវេទនានៅកណ្តាល
នរកទុក្ខអម្បាល លំបាកណាស់ណាអ្នកអើយ ។
សម្បត្តិក្នុងលោកិយ បរលោកក្តីពុំត្រាស្បើយ
ទុក្ខច្រើនពេកណាស់ហើយ តែងនឹងរងកម្មវេរា ។
បើចង់ឱ្យបានសុខ ឱ្យរិតក្តក្នុងចិន្តា
ខិតខំពិចារណា នឹងចរចាមានមេត្រី ។
បើចង់បានជាធំ នោះឱ្យខំរៀនសេចក្តី

---

១- ត្រង់នេះតាមច្បាប់ដើម បាត់ចុងចួន យើងមិនហ៊ានកែ ។

ឱ្យច្បាស់តាមបាលី　　កេរ្តិ៍គម្ពីរច្បាប់ធម៌ថា ។
កុំអាងតែស័ក្តិបុណ្យ　　ចិត្តលោភលន់លើតម្រា
វីបុណ្យនោះអសារ　　ទ្រព្យធនណាអន្តរាយ ។
១០- ចេះចាំក្នុងសេចក្តី　　មានមេត្រីពាក្យបរិយាយ
មេត្តាអ្នកទាំងឡាយ　　អ្នកនោះនឹងជួយឱ្យពរ ។
កុសលនោះទ្រទ្រង់　　ជួយឱ្យគង់ស័ក្តិយសល្អ
នោះនឹងចូលអាករ　　ទ្រព្យធនមកពីជិតឆ្ងាយ ។
បើកាន់កាប់ដោយធម៌　　ស័ក្តិយសល្អឃើញសប្បាយ
ទ្រព្យធនផងទាំងឡាយ　　ទុកឱ្យកូនចៅឆីបាន ។
គួរគន់គិតរំពឹង　　រិះជញ្ជឹងមើលប្រមាណ
កុសលព្រេងនោះមាន　　នឹងរំថ្មីពេកអម្បាយ ។
ច្បាប់ធម៌ពីបុរាណ　　មាននិទានជាបរិយាយ
គម្ពីរចោទចែងចាយ　　ទូន្មានមកទុកឱ្យស្តាប់ ។
១៥- កុំរំហួសវាសនា　　កុំចរចាចោលឯច្បាប់
កុំប្រឹងចោលសណ្តាប់　　កុំបន្ទប់ចោលឯខ្នាត ។
ធ្វើអ្វីគួរឱ្យគិត　　មើលពិនិត្យដោយបទបាឋ
គប្បីឱ្យសង្វាត　　កុំឱ្យខាតប្រយោជន៍ខ្លួន ។
ទៅមុខប្រយ័ត្នក្រោយ　　កុំឱ្យធ្លោយគិតឱ្យម្ហូន
ការអ្វីមើលឱ្យថ្លួន　　ឱ្យត្រូវជួននឹងរាជការ ។

កុំអាងថាខ្លួនចេះ អួតចំណេះមានប្រាជ្ញា
ឱ្យដឹងពិចារណា ព្រឹទ្ធាចារ្យទូវតូចធំ ។
រីក្នុងជាតិនេះនៃ ទោះប្រុសស្រីឱ្យគួរសម
ទើបបានធ្វើជាធំ និយាយលើគេនោះបាន ។
២០- ដូចអង្គព្រះអាទិត្យ ដ៏មានឫទ្ធិជាប្រធាន
ពន្លឺភ្លឺសព្វស្ថាន នោះពុំបានចន្លោះឡើយ ។
គិតឃើញគួររំពឹង កុំស្ងៀមឈឹងឈប់ព្រងើយ
កុំស្ងៀមធ្វើកន្តើយ ខ្លួនធំហើយត្រូវត្រួតត្រា ។
បើស្ងៀមពុំរិះគិត នឹងងងឹតដូចយប់ណា
ធ្លាយធ្លុះខុសខូចការ រីទោសាជិតដល់ខ្លួន ។
ហេតុតែពុំពិនិត្យ ដោយសុចរិតតាមច្បាប់ក្បួន
ធ្លុះធ្លាយឱ្យខូចខ្លួន នេះនៃជួនដូចព្រឹក្សា ។
ដើមឈើដុះក្នុងព្រៃ តូចធំក្តីច្រើនគ្រៀបគ្រា
ឱ្យជ្រែនៅដោយសារ គិតខុសការខ្លួនអប្រិយ ។
២៥- ជ្រែឥតអសុរោះ ដូចមនុស្សអឲ្យតិរ្ថិយ
តែងតែមានឱ្យភ័យ អាប់អន់អស់អង្គរូបា ។
បើស្តីឱ្យពិនិត្យ ពាក្យណាពិតសឹមចរចា
កុំចាត់ដោយមុសា កុំពាលោដោយក្បួនច្បាប់ ។
រក្សាកេរ្តិ៍មារយាទ កុំឱ្យឃ្លាតនៃសណ្តាប់

មានក្នុងគម្ពីរស្រាប់ គួរខំរៀនរក្សាខ្លួន ។
រក្សាអស់ទ្រព្យធន យសស័ក្តិបុណ្យឱ្យមាំមួន
ដោយតេជតេជៈខ្លួន កេរគម្ពីរទូន្មានទុក ។
បើចង់ធ្វើមេបា ឱ្យឧស្សាហ៍នៅភូមិស្រុក
ចង់បានប្រាណស្រណុក ច្បាប់ចងទុកឱ្យរៀនគិត ។
៣០- បើបានងារស័ក្តិយស ចិត្តឱ្យស្មោះនឹងមហាក្សត្រ
បើចង់គង់សម្បត្តិ ច្បាប់លោកថាកុំស្ទូវចាយ ។
បើចង់ធ្វើជាហោរ ឱ្យរៀនគូរលេខទំនាយ
ចង់សងគុណទាំងឡាយ បើនិយាយឱ្យបរមត្ថ ។
បើចង់ឱ្យបរិសុទ្ធ ឱ្យលំអុតកេរ្តិ៍មារយាទ
បើចង់រក្សាញាតិ កុំឱ្យឃ្លាតទីប្រតិបត្តិ ។
បើចង់ឱ្យបានសុខ ចៀសចាកទុក្ខឱ្យកំណត់
បើស្តីៗតាមបទ បើឃើញពុតកុំក្រេវក្រោធ ។
សន្តាននៅក្នុងស្រុក អំពល់ទុក្ខកុំពិរោធ
គង់តែគេនឹងកោត ខ្លាចអំណាចអំណាត់នោះ ។
៣៥- បើចង់ឱ្យអប្រិយ បង្កើតក្តីអាក្រក់ឈ្មោះ
បើចង់ឱ្យត្រូវខ្នោះ នោះឱ្យគិតធ្វើជាចោរ ។
សេចក្តីនេះមានច្រើន រាប់រយពាន់ក្នុងនគរ
និទានច្បាប់ទុកមក គ្រាន់តែមើលដឹងសេចក្តី ។

ឱ្យគិតពិចារណា ដោយប្រាជ្ញាញាណវាងវៃ
ត្រិះរិះអធ្យាស្រ័យ គួរឱ្យគិតរក្សាកាយ ។
រីលោកមានស័ក្តិយស បុណ្យខ្ពង់ខ្ពស់ធំទូលាយ
អ្នកតូចកុំមើលងាយ កុំផ្ទឹមកាយនឹងលោកឡើយ ។
បើស្តីឱ្យមានក្រែង កុំជល់ជែងពាក្យលោកឡើយ
តតបថែមរឿយៗ មានទោសហើយខ្លួនអាស្រូវ ។
៤០- ដូចអ្នកចេះពុះឧស ពុំដែលខុសសុទ្ធតែត្រូវ
ឧសសាញដូចម្តេចក្តី ត្រូវជដែលសឹងបែកបាន ។
ហេតុនេះគួរប្រយ័ត្ន តាមព្រះក្រឹត្យធម៌ទូន្មាន
កុំបីធ្វើបំពាន រក្សាប្រាណកុំបីធ្លោយ ។
បើខឹងដូចម្តេចក្តី ប្រុងស្មារតីកុំឱ្យធ្លោយ
ខឹងនោះនឹងខុសក្រោយ ខឹងនោះឱ្យមានទោសា ។
ទោសឱ្យបង់ស័ក្តិបុណ្យ បង់ទ្រព្យធនបុត្រភរិយា
មានកាលក្ស័យជន្មា ដល់អាត្មាសោតសឹងមាន ។
បីដូចសត្វមមាច កាន់ចិត្តកាចទ្រុស្តសាមាន្យ
ហ៊ានហើរដល់ពុះពាន ព្រះអគ្គីឆេះឆាប់ក្រៃ ។
៤៥- ហេតុនេះគួររិះគិត គួរចូលចិត្តកុំសង្ស័យ
គួរប្រឹងប្រុងស្មារតី តាមវិន័យច្បាប់ធម៌ថា ។

ទោះផ្ដាំព្រះមហាក្សត្រ ទាំងព្រាហ្មណ៍ព្រឹទ្ធនូវយោធា
ទោះផ្ដាំព្រះមាតា ព្រះបិតាជាប្រធាន ។
ឱ្យដឹងកលកិច្ចការ មើលអធ្យាស្រ័យប្រមាណ
បើលោកព្រះទ័យក្សាន្ត មានសេចក្ដីសុំចរចា ។
កលមួយលោកនិយាយ អ្នកជិតឆ្ងាយពីរាជការ
ស្ដីលលេងក្ដីណា កុំចរចាកាន់លោកឡើយ ។
ទោះបីលោកសប្បាយ ឈប់និយាយនោះស្រេចហើយ
តាមហេតុនោះអ្នកអើយ កុំចរចាការអ្វីៗ ។
៥០- មួយលោកនឹងស្ដីផង ចូរចាប់ចងចាំសេចក្ដី
កុំបីភ្លេចឡើយនៃ ពាក្យបណ្ដាំគ្រប់ប្រការ ។
មួយបើគ្រូបាធ្យាយ ឪពុកម្ដាយនូវយោធា
ព្រះមហាក្សត្រក្ដីណា លោកមានការក្រជាងាយ ។
លោកប្រើឱ្យទៅមើល៍ សព្វសារពើការទាំងឡាយ
ទោះការនៅជិតឆ្ងាយ គួរពិនិត្យមើលឱ្យជាក់ ។
ឱ្យដឹងការវែងខ្លី តូចធំក្ដីទោះមាសប្រាក់
ពិនិត្យមើលឱ្យជាក់ ក្នុងបញ្ជីជាចំណាំ ។
ទោះបីឥតដំណឹង ការពុំដឹងភ្លេចពុំចាំ
ទោះនឹងធ្វើជាធំ ស្ដីលើគេសោតពុំបាន ។

៥៩- បើដឹងការកលកិច្ច ចាំកុំភ្លេចក្នុងវិញ្ញាណ
ទើបធ្វើជាធំបាន ហេតុដោយមានមារយាទល្អ ។
បើលោកមានក្រេវក្រោធ ស្តីពិរោធខឹងវឹកវរ
ជេរពោលបន្ទោសមក៍ តាមដំណើរដែលខ្លួនធ្វើ ។
កុំប្រឹងតបតឆ្លង ឆ្លើយសាសងកេរដំណើរ
ពាក្យពេចន៍សព្វសារពើ ប្រឹងប្រកែកជជែកឈ្លោះ ។
ប្រៀបដូចជាភ្លើងឆេះ ដំណើរនេះចំចំពោះ
កុំខឹងប្រកែកឈ្លោះ នឹងភ្លើងនោះពុំឈ្នះឡើយ ។
មួយដូចដំណើរខ្លួន អ្នកធំគួនពុំគ្រាស្មើយ
ដូចភ្លើងឆេះឯងហើយ គួរចូលចិត្តគិតចងចាំ ។
៦០- គួរតែយកទឹកទៅ លត់ភ្លើងក្តៅតាមចំណាំ
សោះលោកខឹងមួនមាំ យកអំណត់ទើបលត់បាន ។
អត់ចាំលោកបាត់ក្រោធ ខឹងពិរោធលុះស្រាកស្រាន្ត
កុំថែមដោយដើមដាន ដំណើរនោះជាឯក្រោយ ។
លោកនឹងកោតថាចេះ មានចំណេះមិនថ្វស់ធ្លោយ
លោកគិតអាណិតក្រោយ ឃើញដឹងដោយសេចក្តីត្រង់ ។
លោកថាខ្លួនចេះអត់ មានអំណត់មិនល្ងើល្ងង់
នោះលោកនឹងតម្រង់ ឱ្យកេរ្តិ៍គង់កើតសុខា ។

ទោះបីលោកអាណិត | ទំរិះគិតពិចារណា
រិះរេរកប្រាជ្ញា | រក្សាខ្លួនដោយក្រឹត្យក្រម ។
៦៩- យកលោកជាទីពឹង | លើពំនឹងលោកជាធំ
គួរគិតឱ្យគួរសម | ទោះដេកដើរអង្គុយក្តី ។
ឱ្យមានទីប្រតិបត្តិ | គួរប្រយ័ត្នប្រុងស្មារតី
ទោះទ្រព្យលោកថោកថ្លៃ | គន់រំពៃមើលរក្សា ។
ខ្លួនពឹងលើលោកហើយ | កុំព្រងើយប្រហែសការ
ប្រយ័ត្នប្រុងប្រាជ្ញា | តាមសណ្តាប់ច្បាប់ប្រដៅ ។
ប្រៀបដូចដើមឈើធំ | វល្លិ៍ដុះរុំព័ទ្ធពីក្រៅ
វល្លិ៍សូមសំណាក់នៅ | ដើមឈើនោះដុះខ្ពស់ផង ។
វល្លិ៍ខ្ពស់ព្រោះគុណឈើ | វល្លិ៍ព័ទ្ធលើនោះឯងហោង
វល្លិ៍វារព័ទ្ធទាក់ទង | មានផ្លែផ្កាច្រើនក្រាស់ក្រៃ ។
៧០- ឈើដូចលោកមានបុណ្យ | វល្លិ៍ដុះព័ទ្ធពាក់ប្រស្រ័យ
ដូចអ្នកតូចនោះនៃ | គួរគិតកុំភ្លេចគុណឡើយ ។
បើអ្នកណាដឹងគុណ | កុសលបុណ្យចម្រើនឱ្យ
បើភ្លេចគុណគេហើយ | ជាបផ្តន្ទាឃើញថ្មីៗ ។
បរលោកមើលមិនយល់ | ឃើញដឹងកលកេរ្តិ៍លោកិយ
ដឹងគុណពុំភ្លេចក្តី | ដូចប្រុសស្រីដឹងស្រាប់ហើយ ។

ហេតុនោះគួរវេគិត　　　វិះពិនិត្យកុំព្រងើយ
កុំធ្វេសប្រហែសឡើយ　　　គុណនោះស្មើយានជំនិះ ។
ឈ្មួញទឹកពិតពឹងទូក　　　រីឈ្មួញគោកពឹងរទេះ
សំណាងពឹងចំណេះ　　　ប្រាជ្ញប្រាយចេះពឹងគម្ពីរ ។

៧៩- ព្រះសង្ឃពឹងវិន័យ　　　សត្វភពត្រៃពឹងធរណី
សេនាពឹងឫទ្ធី　　　ឯអ្នកជីពិតពឹងវត្ត ។
រីមូលពឹងក្រឡឹង　　　រីឯត្រង់ពឹងបន្ទាត់
កិរិយាពឹងសំពត់　　　រីបរិសុទ្ធពិតពឹងសីល ។
សត្វត្មាតពិតពឹងរុយ　　　សាច់សត្វស្អុយពឹងអំបិល
មង្គលការពឹងពពិល　　　រក្សាសីលពិតពឹងទាន ។
ទានមានគុណប្រសើរ　　　ទោះនឹងធ្វើបុណ្យសឹងបាន
ជូនឧទ្ទិសសព្វស្ថាន　　　ផលបុណ្យបានដូចប្រាថ្នា ។
រីទាននោះមានច្រើន　　　រាប់រយម៉ឺនក្នុងសីមា
ក្រមានអ្នកឯណា　　　នឹងស្គាល់ទានឱ្យគ្រប់ឡើយ ។

៨០- ទោះបីអ្នកឯណា　　　មានវាសនាប្រាកដហើយ
ប្រតិបត្តិទានជាត្រើយ　　　ទានទ្រទ្រង់ទាំងភពត្រៃ ។
ថាបើបានប្រតិបត្តិ　　　ទានប្រាកដហើយប្រពៃ
បីដូចស្ពានកែវថ្លៃ　　　កែវនៅក្នុងដួងផ្កាល្វា ។

ទានជួយឱ្យបានសុខ រួចនរកបានសុខា
សុខនៅលោកិយណា សុខដល់សួគ៌និញ្វានហោង ។
ពំនឹងពំនាក់នៅ ពឹងឱ្យត្រូវតាមគន្លង
ពឹងខុសនឹងសៅហ្មង នឹងខូចខាតខ្លួនអន្តរាយ ។
ជ្រូកស្រុកពិតពឹងមនុស្ស ទុកចិត្តស្មោះថាវសាយ
យូរទៅកើតដល់កាយ រងទុក្ខទល់ប្រាសព្រាត់គ្នា ។
៨៥- មួយដូចគោក្របី សេះដំរីនូវមាន់ទា
នៅនៃនឹងមនុស្សា យូរប្រែជាសត្រូវផង ។
មានកាលលក់បង្រាស ឱ្យព្រាត់ប្រាសពីមេពង
ជូនក្ស័យជីវិតផង ហេតុបំណងខុសថ្នាំងថ្នាក់ ។
កង្កែបគីង្គក់ហ៊ុង អរឃើញភ្លៀងស្រក់ស្រោក់
នាំគ្នាស្រែកឮជាក់ លោតលេងសាយកាលភ្លៀងនៅ ។
លង់លុះដល់ភ្លៀងរាំង ដីរឹងគាំងស្ងួតទាំងស្មៅ
កង្កែបហ៊ុងអាសៅ នេសាទទៅចាប់វាយធី ។
កង្កែបហ៊ុងលាក់ខ្លួន ជ្រកពឹងពួនក្នុងធរណី
គេតាមទាន់ចាប់ធី លុះជីវីក្សិណក្ស័យហោង ។
៩០- ក្ស័យចោលកូនតូចៗ ខុសខាតខូចបង់ទាំងពង
ព្រាត់ព្រាយប្រាសចោលរូង ត្បិតខំស្រែកសម្រែកខ្លាំង ។

ហេតុនោះគួររិះគិត ប្រុងគំនិតកុំភ័ន្តភាំង
គួរយកព្រះធម៌តាំង ទូន្មានចិត្តតាមនិទាន ។
បើកាន់ចិត្តអាក្រក់ ដូចឈើពុកស្ថិតសព្វស្ថាន
ពុកពីបណ្តូលប្រាណ សឹងបាក់បែករហែកដើម ។
ជ្រុះស្លឹកជ្រុះផ្លែផ្កា វែងវេទនាឃើញសម្បើម
ហេតុនោះគួរឱ្យខ្ពើម ចិត្តអាក្រក់កុំទុកប្រាណ ។
ទុកយូរបន្តិចទៅ ដូនក្រែងត្រូវតាមនិទាន
នឹងកើតក្តីវិនាន កុំឱ្យប្រាណរោយរេចអស់ ។

៩៥- កុំកាន់ចិត្តឫស្យា កុំចរចាចោលសប្បុរស
ឥតទោសកុំថាខុស អ្នកចិត្តស្មោះកុំបញ្ឆោត ។
ផ្គរលាន់ឮគគ្រេង កុំអួតភ្លៀងថាធ្លាក់មក
ក្រែងខ្យល់ផាត់បក់បោក ប្រានពពកមេឃស្រឡះ ។
គិតការគួររំពឹង មើលសំឡឹងឱ្យជាក់ច្បាស់
គិតការកុំចោលចាស់ ដូនក្រែងទាស់នឹងខុសក្រោយ ។
បើជនជាតិឯណា មានវាសនាបុណ្យលោកជួយ
កាន់ច្បាប់ខ្ជាប់មិនធ្លោយ កុសលឱ្យបានសុខា ។
ឱ្យបានសុខទាំងបី សុខលោកិយសុខសួគ៌ា
សុខដល់និព្វានណា ច្បាប់ធម៌ថាសុខស្រេចហោង ។

**(ចប់)**

# ច្បាប់ បណ្ដាំបិតា

## បទកាកគតិ

១- នេះបទកាកគា- តិទើបចងជា ច្បាប់ច្បាស់ទូន្មាន
តាមដោយគន្លង ព្រេងព្រឹទ្ធបុរាណ ប្រាជ្ញលោកទិទាន
ប្រដៅបុត្រភ្ងា ។

ហៃកូនពន្លក ស្ងួនអើយមាសយក បណ្ដាំបិតា
ឪពុកនោះចាស់ ឥតអ្វីឲ្យបា ស្ងួនអើយរក្សា
ពាក្យឪពុកនៅ ។

ឱកូនកំសត់ រៀនឱនរៀនអត់ រៀនគិតក្នុងក្រៅ
រៀនឱនលំទោន កុំឲ្យហ្មងសៅ ដល់ខ្លួនកូនពៅ
កេរ្ដិ៍ដល់ឪពុក ។

ដឹងឈ្លើយត្បិតដង កូនសោតវែងឆ្គង ត្បិតតែឪពុក
ទ្រព្យគង់ត្បិតស្រី ចេះរៀបដាក់ទុក ប្រះដេកឆាប់លក់
ត្បិតឥតបើគិត ។

៥- ចំណោះទាំងឡាយ កិច្ចកលដោះស្រាយ ត្បិតតែគំនិត
ដឹងកិច្ចដឹងកល ដឹងឆ្ងាយដឹងជិត ដូចកលកាំបិត
កាប់ឆ្ការទំលាយ ។

WAT KHEMARARATANARAM

ល្មមទៅល្មមខាន ល្មមដើរបំពាន ពុំគិតក្រងាយ
ល្មមឈប់បង្អង់ ល្មមខាននៅអាយ ក្តីក្រកុំស្រាយ
ក្តីងាយកុំធ្វេស ។

សូវដើរកុំដេក សូវថប់កុំគ្រេក សេចក្តីប្រហែស
សូវខានកុំពារ ចិត្តចង់ចចេស សូវចូលកុំចៀស
វាសរួចសឹមគួរ ។

លឿនកុំបំបោល ពាក្យព្រេងកុំចោល ទឹងកុំម្ងទូ
ស្រាយចេញឱ្យឆាប់ កុំទុកឱ្យយូរ សេចក្តីម្ងទូ
មិនដឹងខុសត្រូវ ។

ដេកកុំដំដើច គេក្រកុំសើច គេភ័យកុំព្រួហ៍
ទោះទឹងប៉ុន្មាន ធ្វើជាឱ្យគួរ តឹងគិតឱ្យធូរ
យូរគិតឱ្យឆាប់ ។

១០- សេចក្តីបម្រុង ពាក្យដើមពាក្យចុង ប្រកាន់ឱ្យខ្ជាប់
សូវនឿយឯខ្លួន កុំឱ្យបង់ទ្រព្យ សូវបង់ក្តីគាប់
កុំឱ្យខ្លួនស្លាប់ ។

សូវស្លាប់ទៅជា កុំបង់ធម្មា ឥរិយាសីលគាប់
ឱ្យគិតជញ្ជីង រំពឹងឱ្យសព្វ ពាក្យស្លែងកុំស្អប់
ពាក្យគាប់ឱ្យយក ។

ចង់គង់ឱ្យទុក ចង់បានក្ដីសុខ ឱ្យស្វែងដើររក
ឃើញច្បាស់ធម៌អាថ៌ ឱ្យយកខ្លួនជ្រក ក្ដីសោកមម៉ោក
ឱ្យចៀសចេញឆ្ងាយ ។

កូនអើយលោកិយ នេះឱ្យរៀនក្ដី រៀនច្បាប់ទាំងឡាយ
រៀនទាំងសម្ដី កុំបីរាយមាយ ក្ដីក្រក្ដីងាយ
ក្ដីគួរក្ដីសម ។

ឱកូនពុំងា ធម្មតាអ្នកជា ឱ្យរៀនថែទាំ
រៀនដាក់រៀនទុក រៀនរៀបរៀនចំ រៀនរកសន្សំ
លក់ចេញទិញចូល ។

១៥- មួយសោតឯច្បាប់ បើបាមានទ្រព្យ មនុស្សផងមកមូល
ពឹងពាក់ប្រាណណា បាយកប្រមូល សន្សំផ្សំចូល
យកមកជាមួយ ។

កូនអើយឯម្លប់ មនុស្សផងចូលឈប់ សម្រាន្តអាត្មា
ព្រោះឈើមានម្លប់ ត្រសុំសាខា ម្ដេចឡើយប្រែជា
ក្ដៅជ្រកពុំបាន ។

មនុស្សផងរំលង រកម្លប់ទៀតហោង ចូលចតសម្រាន្ត
ម្លប់នេះត្រជាក់ ត្រសាក់ក្សេមក្សាន្ត មនុស្សផងចូលថ្កាន
មិនមានហៅអាក់ ។

ឧបមាដូចទឹក ជ្រាលជ្រៅពន្លឹក ជាទីសំណាក់
មច្ឆាមច្ឆា ចេញចូលពឹងពាក់ ព្រោះទឹកត្រជាក់
មិនមានហ្មងសៅ ។
ពុំគិតឡើយហោង ឯទឹកនោះផង ម្តេចប្រែជាក្តៅ
មច្ឆាទាំងឡាយ ព្រាត់ព្រាយរត់ទៅ រកទឹកទៀតនៅ
ពំនាក់អាត្មា ។
២០- កូនអើយបើច្នោះ អសោចកេរ្តិ៍នោះ ត្រូវត្រង់ខ្លួនណា
ព្រៀងលានទាំងឡាយ គេនឹងនិន្ទា ដំនៀលដៀលថា
បាឯងពុំចេះ ។
អាប់ឥតប្រាជ្ញា អាប់ទាំងឥរិយា យោបល់ចំណេះ
អាប់ទាំងមារយាទ អាប់ទាំងតម្រិះ ត្បិតបាឯងនេះ
ពុំចេះរក្សា ។
គណនាដូចទឹក កូនអើយបើល្អឹក ពុំមានមច្ឆា
មួយគ្រាន់ពន្លៀក នៅក្នុងគង្គា ពុំរាប់ហៅថា
ប្រសើរឡើយហោង ។
មួយសោតអ្នកណា គេមកប្រាប់ថា បទបាធ្វើឆ្គង
បាគិតជញ្ជីង រំពឹងដើមទង កុំបាកែងកោង
ក្អេងក្អាងពុំស្តាប់ ។

ទូកហួសកំពង់ ភាចែវបង្អង់ ថយមកចូលចាប់
ពាក្យលឿនហួសខ្នាត ហៅឥតគំនាប់ ថយមករកគាប់
ពុំបានឡើយណា ។

២៥- អង្គុយហួសស័ក្តិ ស្រដីហួសថ្នាក់ បង់ឈោយហួសស្មា
ពុំមើលប្រមាណ នឹងប្រាណអាត្មា ហាហួសចង្កា
ថាហួសសេចក្តី ។

រីឯកង្កែប មុខដូចគេពេប ហាឡើងស្រដី
អួតឯងកម្លាំង ផល់នឹងដំរី ទោះទាំងរាជសីហ៍
ក៏អញពុំខ្លាច ។

មួយសោតចចក ដកកកូក់ អួតឯងអំណាច
នឹងជ្រែកប្រឹថពី ទៅទាំនាគរាជ ដណ្តើមយករាជ្យ
ភូមិភពនាគា ។

រីសត្វអណ្តើក វារឡើងរវើក មកអួតអាត្មា
ថាអញនឹងលោត រំលងបព្វតា ហេតុក្តីមោហា
ពុំដឹងខុសគាប់ ។

រីឯគីង្គក់ លោតឡើងពីភក់ មើលទៅគួរស្អប់
អួតខ្លួនថាល្អ ដូចមាសទឹកដប់ រាងអញចំប្រប់
ដូចរាជសីហា ។

៣០- ហាឡើងមិនធ្យាន ស្ដីមិនប្រមាណ នឹងប្រាណអាត្មា
សូវឱនកុំងើប សូវស្ងៀមកុំថា សូវវាយកុំយារ
សូវកាប់កុំជេះ ។

ឱកូនពន្លក ច្បាប់នេះបាយក ស្ងួនកុំប្រហែស
ច្បាប់នេះប្រសើរ ហោមហារិសេស កូនអើយកុំធ្វេស
នឹងច្បាប់នេះណា ។

មួយសោតឯល្បែង សប្បាយចង់លេង នឹងមានភយា
នឹងកើតទុក្ខក្រោយ នឹងបង់ទ្រព្យា នឹងកើតនិន្ទា
បង់មារយាទគាប់ ។

សប្បាយធ្វើស្រែ ចម្ការជួញប្រែ នោះមានគេរាប់
សប្បាយបានស៊ី សប្បាយបានទ្រព្យ សប្បាយនោះគាប់
សប្បាយយឺនយូរ ។

មួយសោតឯស្រី ចេះលើកយសប្ដី ចេះគិតចេះគូរ
ចេះរៀបចេះចំ ចេះសមចេះគួរ អ្នកផងនឹងសួរ
រកឈ្មោះពុំខាន ។

៣៥- នាងនេះឈ្មោះអ្វី មុខមាត់ប្រិមប្រិយ សមជាអ្នកមាន
ម្លោះហើយនឹងកើត ទ្រព្យផងពុំខាន ព្រោះពាក្យសន្ដាន
ព្រេងលានគេទាយ ។

WAT KHEMARARATANARAM

រីឯពាក្យមនុស្ស ពុំដែលនឹងខុស ហួសពីទំនាយ
ពុំដែលនឹងស្មៀង មិនជិតមិនឆ្ងាយ អ្នកផងទាំងឡាយ
គួរគិតកុំឆ្ងល់ ។

ពាក្យព្រេងលោកថា លោកមានឧបមា ឱ្យគិតឱ្យយល់
ពាក្យលោកទំនឹម មិនមានឱ្យសល់ កូនអើយកុំឆ្ងល់
នឹងពាក្យនេះណា ។

កុំអួតកុំអាង ដើរកុំមើលវាង មើលអង្គអាត្មា
កុំដើរផ្ទះគេ ហួសពេលវេលា កុំទៅធានា
ទ្រព្យគេទាំងឡាយ ។

កុំដេកផ្កាប់មុខ កុំដើរពានថ្លុក ថាឯងសប្បាយ
មានទោសនឹងគេ កុំឱ្យនិយាយ ដើមគេនឹងក្លាយ
កើតទោសទៀតធំ ។

៤០- ខ្លួនទាបកុំតោង ដៃខ្លីកុំឈោង ស្រវាឱបភ្នំ
ចាស់កោងកាន់ច្រត់ អួតអាងប្រគំ កួរអួតផ្លុំ
ប៉ុពកយកខ្យល់ ។

ខ្វាក់ផ្លុះកញ្ចក់ ដកកកូក់ ហាក់ឯងមើលយល់
ខ្វិនអួតនឹងផ្លោះ រំលងលើគល់ ទំពែករកកល
ចង់បានប្រេងលាប ។

ក្មេងចង់រាំ ក្រោកឡើងទន្ទាំ កែងកោងអាបឡាប
ថ្ងង់ចង់ស្ដាប់ច្រៀង ផ្ទៀងផ្ទងទន់ទាប ដៃត្លួចខ្លួនទាប
ចង់ឈោងចាប់ផ្កាយ ។

កូនអើយចូរស្ដាប់ ពាក្យនេះមហាគាប់ គ្រប់តួទាំងឡាយ
បាគិតរំពឹង ជញ្ជឹងឱ្យឆ្ងាយ កុំធ្វើរាយមាយ
នឹងច្បាប់នេះណា ។

មួយសោតគេប្រាប់ ថាបាពុំគាប់ ទោសដល់អាត្មា
កុំបាភិតភាំង ស្លុតស្លាំងកាយា ប្រាណប្រុងឥរិយា
ស្មារតីឱ្យនឹង ។

៤៥- រិះរកគំនិត ភ្នំយោបល់គិត ទង់ទាញសន្ទឹង
ប្រាជ្ញាមួយកាត់ ចាត់ឡើងឱ្យដឹង ចំណេះមួយរឹង
ធ្វើហាក់មិនភ្លឹក ។

កូនអើយលោកថា ពាក្យលោកឧបមា ដូចគជសារសឹក
កាំភ្លើងដៃដុំ ពុំដែលនឹងភ្លឹក ជញ្ជួចគគឹក
គគុកបោលចូល ។

ធម្មតាអ្នកជា អ្នកមានប្រាជ្ញា សន្ដានត្រកូល
ឱ្យគិតឱ្យដឹង រំពឹងឱ្យមូល ប្រាជ្ញាឱ្យចូល
ចងចាំទុកនៅ ។

កុំអួតកុំអាង កុំភូតបំព្រាង កុំឱ្យចៃចូវ
កុំកាច់កុំកិន រអែរអូវ កុំនាំពាក្យទៅ
ប្រាប់ឱ្យកើតទោស ។

កុំរេះកុំរៀន កុំបៀតកុំបៀន កុំស្តីតោសម៉ោស
គ្នាបានជាខុស ឱ្យមានសន្តោស កុំហាឱ្យហួស
ជ្រើសពាក្យទៅមុន ។

៥០- ចូលសឹកកុំញោច ជំពាក់កុំបោច ខ្ជិលកុំចងពន្ធ
ជាគ្រូអាត្មា កុំឱ្យលោកអន់ សេចក្តីទម្ងន់
សន្សឹមកុំបោល ។

កុំអួតកម្លាំង កុំអាងខ្លួនខ្លាំង រត់នឹងស្រមោល
កុំអាងជាធំ កុំងាយពាក្យពោល ពាក្យព្រេងកុំចោល
កុំថ្កោលទោសសង្ឃ ។

កុំចោលផ្លូវវៀច កុំអាងអំណាច ដើរកាត់តម្រង់
ក្រែងបង់ឥរិយា សក្តាកុំគង់ លោកហៅថាល្ងង់
អាប់ឥតប្រាជ្ញា ។

កូនអើយចូរស្តាប់ ពាក្យមួយមហាគាប់ មានមិត្តស្នេហា
ឱ្យមើលមារយាទ មើលសព្វឥរិយា ឱ្យដឹងថាជា
ជាកាចវៀចត្រង់ ។

ឱ្យសមឱ្យសួន ឱ្យល្មមនឹងខ្លួន ឱ្យធួននឹងអង្គ
សឹមយកជាមិត្ត បិតថេរដ៏លង់ ទៅមកតម្រង់
ចេញចូលស៊ីចុក ។

៥៥- មិត្តមួយសោតណា ទៅមកកាន់គ្នា បង្កើតឱ្យសុខ
មិត្តមួយឱ្យទោស បង្កើតជាទុក្ខ មិត្តមួយឱ្យផុក
ឱ្យបង់ទ្រព្យា ។

មិត្តមួយបង្ហិន ទៅមកខ្វាន់ៗ ជក់ថ្នាំស៊ីស្លា
ចុះឡើងឥតអាក់ នឹងហិនអាត្មា កូនអើយលោកថា
អាសារបង់ទ្រព្យ ។

ឱកូនពិសី កូនប្រុសកូនស្រី ស្ងួនអើយបាស្តាប់
ទំនឹមទំនង គន្លងផ្លូវច្បាប់ ទុកជាសណ្តាប់
នៃនរជនជាតិ ។

មួយសោតលោកថា ឬកក្នុងអាត្មា មានបីពុំឃ្លាត
មួយស៊ីមួយដេក មួយដើរជាខ្នាត ស៊ីឥតមារយាទ
ពុំត្រូវសណ្តាប់ ។

ដើរឥតបើគិត ដើរឥតគំនិត ហៅខុសនឹងច្បាប់
ដេកដល់ថ្ងៃរះ ហៅឥតគំនាប់ ចង្រៃអភ័ព្វ
នឹងអាប់អាត្មា ។

៦០- នឹងស្វែងរកទ្រព្យ ចង្រៃអភ័ព្វ មិនឱ្យជំនា
ឱ្យកើតតែទុក្ខ ឱ្យបង់ទ្រព្យា នឹងរកភរិយា
ហាក់ដូចគេណាយ ។

ព្រោះក្ដីអភ័ព្វ ចង្រៃនូវអព- មង្គលទាំងឡាយ
ចូលក្នុងអាត្មា មិនមានទៅឆ្ងាយ ជ្រាបជ្រៅក្នុងកាយ
ក្នុងអង្គអាត្មា ។

ទោះប្រុសទោះស្រី បើមានឫកបី ដូចច្បាប់លោកថា
ឫកដេកឫកដើរ ឫកស៊ីអាហារ ជាអ្នករក្សា
ឥរិយាមារយាទ ។

ខ្លាចមេខ្លាចបា ទោះបីធ្វើការ មិនមានឱ្យឃ្លាត
ទោះបីនឹងសើច នឹងលេងមានខ្នាត ជាអ្នកសង្វាត
ឱ្យឃ្នាតធ្វើការ ។

អ្នកផងទាំងឡាយ ទោះជិតទោះឆ្ងាយ គេយល់ឥរិយា
គេយល់ចំណោះ ជាអ្នករាបសា គេចង់ចងជា
ពន្ធយកជាញាតិ ។

៦៥- មានខ្សត់ពុំគិត យកតែគំនិត យកតែមារយាទ
ឱ្យចេះរៀបចំ ទុកដាក់ជាខ្នាត ឧស្សាហ៍សង្វាត
រក្សាទ្រព្យា ។

រីម្ដាយឪពុក នឹងបានលើកមុខ ដោយកូនពុំងា
អស់ទាំងបងប្អូន ជីដូនជីតា ម្ដាយមីងនូវមា
សឹងស្រួលចូលចិត្ត ។

ត្បិតកូនសុភាព ជាអ្នករាបទាប ត្រូវនឹងគំនិត
គ្រប់អស់បងប្អូន ទោះឆ្ងាយទោះជិត សឹងបានដូចចិត្ត
ដូចដួងចិន្ដា ។

៨៨- កូនអើយចូរស្ដាប់ ចូរចាំឱ្យខ្ជាប់ ទុកក្នុងអាត្មា
ទំនឹមទំនង គន្លងឧបមា បទចងប្រែជា
បទព្រហ្មគីតិ ។

១- កូនអើយស្ងួនតែមួយ ទុកជាត្រួយត្រូលគំនិត
កូនអើយមាសតាំងចិត្ត តាំងចរិតគិតកុំឆ្ងល់ ។
ធម្មតាកើតជាមនុស្ស ទោះស្រីប្រុសគិតឱ្យដល់
ពាក្យលោកតែងខ្វាយខ្វល់ ជាបឋមចប់ម្ល៉េះហោង ។

**(ចប់)**

# ច្បាប់ កូនចៅល្បើក

## បទកាកគតិ

១- នេះបទកាកគតិ[១]   ទើបចងជាបទ   ជាច្បាប់ទូន្មាន
តាមដោយគន្លង   ព្រេងព្រឹទ្ធបុរាណ   អ្នកប្រាជ្ញនិទាន
ប្រដៅបុត្រភ្ងា ។

ហៃកូនពន្លក   ស្ងួនអើយមាសយក   បណ្ដាំបិតា
ឪពុកនេះចាស់   ឥតអ្វីឲ្យបា   ស្ងួនអើយរក្សា
ពាក្យឪពុកនៅ ។

ឲ្យកូនកំសត់   រៀនឲ្យរៀនអត់   រៀនគិតក្នុងក្រៅ
រៀនឱនលំទោន   កុំឲ្យហ្មងសៅ   ដល់ខ្លួនកូនពៅ
កេរ្តិ៍ដល់ឪពុក ។

ដឹងឈ្លើយត្បិតដង   កូនសោតវែងឆ្តង   ត្បិតតែឪពុក
ទ្រព្យគង់ត្បិតស្រី   ចេះរៀបដាក់ទុក   ប្រះដេកឆាប់លក់
ត្បិតឥតបើគិត ។

៥- ចំណោះទាំងឡាយ   កិច្ចកលដោះស្រាយ   ត្បិតតែគំនិត
ដឹងកិច្ចដឹងកល   ដឹងឆ្ងាយដឹងជិត   ដូចកលកាំបិត
កាប់ឆ្ការទំលាយ ។

---

១- ត្រូវអានសម្រួលតាមជើងកាព្យថា៖ នេះបទកាកគត់ ។

ល្មមទៅល្មមខាន ល្មមដើរបំពាន ពុំគិតក្រងាយ
ល្មមគិតបង្អង់ ល្មមខានទូវអាយ ក្ដីក្រកុំស្រាយ
ក្ដីជាកុំធ្វេស ។

សួរដើរកុំដេក សួរថប់កុំត្រេក សេចក្ដីប្រហែស
សួរខានកុំពារ ចចើងចចេស សួរចូលកុំចៀស
វាសរួចសឹមគួរ ។

លឿនកុំបំបោល ពាក្យព្រេងកុំចោល ទឹងកុំអ៊ូទ្រូ
ស្រាយចេញឱ្យឆាប់ កុំឱ្យទុកយូរ សេចក្ដីមួទូ
មិនគិតខុសត្រូវ ។

ដេកកុំដំណើច គេក្រកុំសើច គេភ័យកុំព្យូហ៍
ទោះទឹងប៉ុន្មាន ធ្វើជាឱ្យគួរ តឹងគិតឱ្យធូរ
យូរគិតឱ្យឆាប់ ។

១០- សេចក្ដីបម្រុង ពាក្យដើមពាក្យចុង ប្រកាន់ឱ្យខ្ជាប់
សួរនឿយខ្លួនឯង កុំឱ្យបង់ទ្រព្យ សួរបង់ក្ដីគាប់
កុំឱ្យខ្លួនស្លាប់ ។

សួរស្លាប់ទៅជា កុំបង់ធម្មា ឥរិយាសីលគាប់
ឱ្យគិតជញ្ជឹង រំពឹងឱ្យសព្វ ពាក្យស្លែងកុំស្អប់
ពាក្យគាប់ឱ្យយក ។

ចង់គង់ឱ្យទុក ចង់បានក្តីសុខ ឱ្យស្វែងដើររក
ឃើញច្បាប់ធម៌ផង ឱ្យយកខ្លួនជ្រក ក្តីសោកមម៉ោក
ឱ្យចៀសចេញឆ្ងាយ ។

កូនអើយលោកិយ នេះឱ្យរៀនក្តី រៀនច្បាប់ទាំងឡាយ
រៀនទាំងសម្តី កុំបីរាយមាយ ក្តីក្រក្តីងាយ
ក្តីគួរក្តីសម ។

ឱកូនពុំងា ធម្មតាអ្នកជា ឱ្យរៀនថែទាំ
រៀនដាក់រៀនទុក រៀនរៀបរៀនចំ រៀនរកសន្សំ
លក់ចេញទិញចូល ។

១៥- មួយសោតឯច្បាប់ បើបាមានទ្រព្យ មនុស្សផងមកមូល
ពឹងពាក់ប្រាណណា បាយកប្រមូល សន្សំផ្សំចូល
យកមកជាគ្នា ។

កូនអើយឯម្លប់ មនុស្សផងចូលឈប់ សម្រាន្តអាត្មា
ព្រៃឈើជាម្លប់ ត្រសុំសាខា ម្តេចឡើយប្រែជា
ក្តៅជ្រកពុំបាន ។

មនុស្សផងរំលង រកម្លប់ទៀតហោង ចូលចតសម្រាន្ត
ម្លប់នោះត្រជាក់ ត្រសាក់ក្សេមក្សាន្ត មនុស្សផងចូលថ្កាន
មិនមានហៅអាក់ ។

ឧបមាដូចទឹក ជ្រាលជ្រៅពន្លឹក ជាទីសំណាក់
មច្ឆោមច្ឆា ចេញចូលពឹងពាក់ ព្រោះទឹកត្រជាក់
មិនមានហ្មងសៅ ។
ពុំគិតឡើយហោង ឯទឹកនោះផង ម្ដេចប្រែជាក្ដៅ
មច្ឆាទាំងឡាយ ព្រាត់ព្រាយរត់ទៅ រកទឹកទៀតនៅ
ពំនាក់អាត្មា ។

២០- កូនអើយថាបើ បាឯងអាចធ្វើ ក្ដៅក្ដាត់មហិមា
ព្រៀងលានទាំងឡាយ គេនឹងនិន្ទា ដំនៀលដៀលថា
បាឯងពុំចេះ ។
អាប់ឥតប្រាជ្ញា អាប់ទាំងឥរិយា យោបល់ចំណេះ
អាប់ទាំងមារយាទ អាប់ទាំងតម្រិះ ត្បិតបាឯងនេះ
ពុំចេះរក្សា ។
គណនាដូចទឹក កូនអើយបើល្អឹក ពុំមានមច្ឆា
មួយគ្រាន់ពន្លៀក នៅក្នុងគង្គា ពុំរាប់ហៅជា
ប្រសើរឡើយហោង ។
មួយសោតអ្នកណា គេមកប្រាប់ថា ត្បិតបាធ្វើឆ្គង
បាគិតជញ្ជឹង រំពឹងដើមទង កុំបាតោតត្លូង
ក្មេងក្លាងពុំគាប់ ។

ទូកហួសកំពង់ រាថែវបង្អង់ ថយមកចូលចាប់
ពាក្យល្បឿនហួសខ្នាត ហៅឥតគំនាប់ ថយមករកគាប់
ពុំបានឡើយណា ។

២៥- អង្គុយហួសស័ក្តិ ស្រដីហួសថ្នាក់ បង់បោយហួសស្មា
ពុំមើលប្រមាណ នឹងប្រាណអាត្មា ហាហួសចង្កា
ថាហួសសេចក្តី ។

រីឯកង្កែប មុខដូចគេពេប ហាឡើងស្រដី
អួតឯងកម្លាំង ជល់នឹងដំរី ទោះទាំងរាជសីហ៍
ក៏អញមិនខ្លាច ។

មួយសោតចចក ដកកកូក់ អួតឯងអំណាច
នឹងជ្រែកប្រឹថពី ទៅទាំនាគរាជ ដណ្តើមយករាជ្យ
ភូមិភពនាគា ។

រីឯអណ្តើក វារឡើងរវើក មកអួតអាត្មា
ថាអញនឹងលោត រំលងបព្វតា ហេតុក្តីមាហោ
ពុំដឹងខុសគាប់ ។

រីឯគីង្គក់ លោតឡើងពីភក់ មើលទៅគួរស្អប់
អួតខ្លួនថាល្អ ដូចមាសទឹកដប់ រាងអញចំប្រប់
ដូចរាជសីហា ។

WAT KHEMARARATANARAM

៣០- ហាឡើងមិនធ្យាន ស្តីមិនប្រមាណ នឹងអង្គអាត្មា
ស្ងួវឱនកុំងើប ស្ងួវស្ងៀមកុំថា ស្ងួវវាយកុំយារ
ស្ងួវកាប់កុំជេះ ។

ឱកូនពន្លក ច្បាប់នេះបាយក ស្ងួនកុំប្រហែស
ច្បាប់នេះប្រសើរ ហៅមហាវិសេស កូនអើយកុំធ្វេស
នឹងច្បាប់នេះណា ។

មួយសោតឯល្បែង សប្បាយចង់លេង នេះឯងលោកថា
នឹងកើតទុក្ខក្រោយ នឹងអស់ទ្រព្យា នឹងកើតនិន្ទា
បង់មារយាទគាប់ ។

សប្បាយធ្វើស្រែ ចំការដួញប្រែ នោះមានគេរាប់
សប្បាយបានស៊ី សប្បាយបានទ្រព្យ សប្បាយនោះគាប់
សប្បាយយឺនយូរ ។

មួយសោតឯស្រី ចេះលើកយសប្តី ចេះគិតចេះគួរ
ចេះរៀបចេះចំ ចេះសមចេះគួរ អ្នកផងនឹងសួរ
រកឈ្មោះពុំខាន ។

៣៥- នាងនេះឈ្មោះអ្វី មុខមាត់ប្រិមប្រិយ សមជាអ្នកមាន
ម្លោះហើយនឹងកើត ទ្រព្យផងពុំខាន ព្រោះពាក្យសន្តាន
ព្រៀងលានគេទាយ ។

រីឯពាក្យមនុស្ស ពុំដែលនឹងខុស ហួសនឹងទំនាយ
ពុំដែលនឹងផ្អៀង មិនជិតមិនឆ្ងាយ អ្នកផងទាំងឡាយ
គួរគិតកុំឆ្ងល់ ។

ពាក្យព្រេងលោកថា លោកនឹងឧបមា ឱ្យគិតឱ្យយល់
ពាក្យលោកទំនឹម មិនមានឱ្យសល់ កូនអើយកុំឆ្ងល់
នឹងពាក្យនេះណា ។

កុំអួតកុំអាង ដើរកុំមើលរាង មើលអង្គអាត្មា
កុំដើរផ្ទះគេ ហួសពេលវេលា កុំទៅធានា
ទ្រព្យគេទាំងឡាយ ។

កុំដេកផ្កាប់មុខ កុំដើរពានថ្លុក ថាឯងសប្បាយ
មានទោសនឹងគេ កុំឱ្យនិយាយ ដើមគេនឹងក្លាយ
កើតជាទោសធំ ។

៤០- ខ្លួនទាបកុំតោង ដៃខ្លីកុំឈោង ស្រវាឱបភ្នំ
ចាស់កោងកាន់ច្រត់ អួតអាងប្រគំ ក្លួរអួតផ្ទុំ
ប៉ុពកយកខ្យល់ ។

ខ្លាក់ផ្ទះកញ្ចាក់ ដកកក្ងក់ ហាក់ឯងមើលយល់
ខ្វិនអួតនឹងផ្លោះ រំលងលើគល់ ទំពែករកកល
ចង់បានប្រេងលាប ។

ក្មេងចង់រាំ ក្រោកឡើងទន្ទាំ កេងកោងអាបឡាប
ថ្លង់ចង់ស្តាប់ច្រៀង ផ្អៀងផ្អងទន់ទាប ដៃតូចខ្លួនទាប
ចង់ឈោងចាប់ផ្កាយ ។

កូនអើយចូរស្តាប់ ពាក្យនេះមហាគាប់ គ្រប់តួទាំងឡាយ
បាគិតរំពឹង ជញ្ជឹងឱ្យឆ្ងាយ កុំធ្វើវាយមាយ
នឹងច្បាប់នេះណា ។

មួយសោតគេប្រាប់ ថាបាពុំគាប់ ទោសដល់អាត្មា
កុំបាភិតភាំង ស្លុតស្លាំងកាយា ប្រាណប្រុងតរិយា
ស្មារតីឱ្យនឹង ។

៤៥- រិះរកគំនិត ជុំយោបល់គិត ទង់ទាញសន្ទឹង
ប្រាជ្ញាមួយកាត់ ចាត់ឡើងឱ្យដឹង ចំណោះមួយនឹង
ធ្វើហាក់មិនភ្លឹក ។

កូនអើយលោកថា ពាក្យលោកឧបមា ដូចគជសារសឹក
កាំភ្លើងដៃជុំ ពុំដែលនឹងភ្លឹក ដេញដាលគគឹក
គគុកបោលចូល ។

ធម្មតាអ្នកជា អ្នកមានប្រាជ្ញា សន្តានត្រកូល
ឱ្យគិតជញ្ជឹង រំពឹងឱ្យមូល ប្រាជ្ញាឱ្យចូល
ចងចាំទុកនៅ ។

កុំអួតកុំអាង　កុំភូតបំព្រាង　កុំឱ្យចៃធ្ងរ
កុំកាច់កុំកិន　រអែរអូរ　កុំនាំពាក្យទៅ
ប្រាប់ឱ្យកើតទោស ។

កុំវៀសកុំវៀន　កុំបៀតកុំបៀន　កុំស្ដីឱ្យមោះ
គ្នាបានជាខុស　ឱ្យមានសន្ដោស　កុំហាឱ្យហួស
ជ្រើសពាក្យទៅមុខ ។

៩០- ចូលសឹកកុំញោច　ជំពាក់កុំបោច　ខ្ជិលកុំចងពន្ធ
ជាគ្រូអាត្មា　កុំឱ្យលោកអន់　សេចក្ដីទម្ងន់
សន្សឹមកុំបោល ។

កុំអួតកម្លាំង　កុំអាងខ្លួនខ្លាំង　រត់នឹងស្រមោល
កុំអាងជាធំ　កុំងាយពាក្យពោល　ពាក្យព្រេងកុំចោល
កុំថ្កោលទោសសង្ឃ ។

កុំចោលផ្លូវវៀច　កុំអាងអំណាច　ដើរកាត់តម្រង់
ក្រែងបង់ឥរិយា　សក្ដាពុំគង់　លោកហៅថាល្ងង់
អាប់ឥតប្រាជ្ញា ។

កូនអើយចូរស្ដាប់　ពាក្យមួយមហាគាប់　មានមិត្រស្នេហា
ឱ្យមើលមារយាទ　មើលសព្វឥរិយា　ឱ្យដឹងជាក់ជា
ជាកាចវៀចត្រង់ ។

ឱ្យសមឱ្យសួន ឱ្យល្មមនឹងខ្លួន ឱ្យធួននឹងអង្គ
សឹមយកជាមិត្ត ស្និតស្នេហ៍លង់ ទៅមកតម្រង់
ចេញចូលស៊ីចុក ។

៩៥- មិត្រមួយសោតណា ទៅមកកាន់គ្នា បង្កើតឱ្យសុខ
មិត្រមួយឱ្យទោស បង្កើតជាទុក្ខ មិត្រមួយឱ្យផុក
ឱ្យបង់ទ្រព្យា ។

មិត្រមួយបង្ហិន ទៅមកខ្វាន់ៗ ជក់ថ្នាំស៊ីស្លា
ចុះឡើងមិនអាក់ នឹងហិនអាត្មា កូនអើយលោកថា
អសារបង់ទ្រព្យ ។

ឱកូនពិសី កូនប្រុសកូនស្រី ស្ងួនអើយបាស្តាប់
ទំនឹមទំនង គន្លងផ្លូវច្បាប់ ទុកជាសណ្តាប់
នៃនរជនជាតិ ។

មួយសោតលោកថា ឬកក្នុងអាត្មា មានបីពុំឃ្លាត
មួយស៊ីមួយដេក មួយដើរឥតខ្នាត ស៊ីឥតមារយាទ
ពុំត្រូវសណ្តាប់ ។

ដើរឥតបើគិត ដើរឥតគំនិត ហៅខុសនឹងច្បាប់
ដេកដល់ថ្ងៃរះ ហៅឥតគំនាប់ ចង្រៃអភ័ព្វ
នឹងអាប់អាត្មា ។

៦០- នឹងស្វែងរកទ្រព្យ ចង្រៃអភ័ព្វ មិនឱ្យជំនា
ឱ្យកើតតែទុក្ខ ឱ្យបង់ទ្រព្យា កម្ចិលសោះសា
ហាក់ដូចគេណាយ ។
ព្រោះក្ដីអភ័ព្វ ចង្រៃនូវអព- មង្គលទាំងឡាយ
ចូលក្នុងអាត្មា មិនមានទៅឆ្ងាយ ជ្រាបជាប់ក្នុងកាយ
ក្នុងអង្គអាត្មា ។
ទោះប្រុសទោះស្រី បើមានឫកបី ដូចច្បាប់លោកថា
ឫកដើរឫកដេក ឫកស៊ីអាហារ ជាអ្នករក្សា
ឥរិយាមារយាទ ។
ខ្លាចមេខ្លាចបា ទោះបីធ្វើការ មិនមានឱ្យឃ្លាត
នាបីនឹងសើច នឹងលេងមានខ្នាត ជាអ្នកសង្វាត
ខ្មីឃ្មាតធ្វើការ ។
អ្នកផងទាំងឡាយ ទោះជិតទោះឆ្ងាយ គេយល់ឥរិយា
គេយល់ចំណេះ ជាអ្នកភាបសា គេនឹងចងជា
ពន្ធយកជាញាតិ ។
៦៥- មានឱ្យត់ពុំគិត យកតែគំនិត ឥរិយាមារយាទ
ឱ្យចេះរៀបចំ ទុកដាក់ជាខ្នាត ឧស្សាហ៍សង្វាត
រក្សាទ្រព្យា ។

វីម្តាយឪពុក នឹងបានលើកមុខ ដោយកូនពុំងា
អស់ទាំងបងប្អូន ជីដូនជីតា ម្តាយមីងនូវមា
សឹងស្រួលចូលចិត្ត ។

ត្បិតកូនសុភាព ជាអ្នករាបទាប ត្រូវនឹងគំនិត
គ្រប់អស់បងប្អូន ទោះឆ្ងាយទោះជិត សឹងបានដូចចិត្ត
ដូចដួងចិន្តា ។

៦៨- កូនអើយចូរស្តាប់ ចងចាំឱ្យខ្ជាប់ ទុកក្នុងអាត្មា
ទំនឹមទំនង គន្លងឧបមា ទើបចងប្រែជា
ជាបទព្រហ្មគីតិ ។

## បទព្រហ្មគីតិ

១- ឱកូនស្ងួនតែមួយ ទុកជាត្រួយត្រួលគំនិត
កូនអើយមាសតាំងចិត្ត តាំងចរិតគិតឱ្យឆ្ងល់ ។
ពាក្យចាស់ពាក្យពីព្រេង ទោសខ្លួនឯងមើលពុំយល់
ទោសគេតូចសោតសល់ រមិលយល់ប៉ុនទាំងភ្នំ ។
ចូលព្រៃសត្វសាហាវ រកអំពាវគ្នាមកជុំ
ដល់បានស្កុរទឹកឃ្មុំ ពួនក្នុងផ្ទះស៊ីម្នាក់ឯង ។
បានហើយចង់បានទៀត ទំឆ្លៀតបៀតមិនគិតក្រែង
មើលយល់តែខ្លួនឯង មិនយល់គេឯទៀតផង ។

WAT KHEMARARATANARAM

៥- នឹងស៊ីចង់ពិសា ខ្វិលទំពាឱ្យហ្មត់ហ្មង
យល់នាមថាជាមង យល់ឯជងថាជាក្លួយ ។
យល់តាថាជាដូន យល់ឯកូនថាជាក្មួយ
យល់ពីរថាជាមួយ យល់ឯព្រួយថាជាសុខ ។
យល់ទោសថាជាគុណ យល់ឯបុណ្យថានរក
យល់ល្អថាអាក្រក់ យល់លាមកថាជាផ្កា ។
ស្លៀកស្បង់មិនកោរសក់ ឆ្លុះកញ្ចក់ធ្មេចនេត្រា
យល់សេះថាជាលា យល់គជាថាកណ្តុរ ។
នេះពាក្យលោកពីព្រេង អ្នកណាឈ្វេងប្រាជ្ញាយល់
ឃើញថ្លុកកុំថាថ្នល់ ក្រែងកំហល់កំហុសមាន ។
១០- អ្នកប្រាជ្ញកាន់ពាក្យទៀង កុំឱ្យល្មៀងពាក្យបុរាណ
កុំដើរផ្លូវបំពាន ពាក្យអ្នកចាស់លោកធៀបថា ។
ពាក្យនេះពីព្រេងព្រឹទ្ធ គួរឱ្យគិតពិចារណា
កុំអួតអាងអាត្មា ថាចំណេះចំណាំមាន ។
ដេកយប់កុំដេកយូរ ខ្វាចក្តីទូជិនដល់ប្រាណ
បើស៊ីកុំតាមឃ្លាន មើលប្រមាណអស់គ្នីគ្នា ។
លើកដាក់តាមកម្លាំង កុំភើចខ្លាំងឈើដល់ស្មា
ប្រើគេប្រើឱ្យជា កុំសសន់រាន់សៅដៅ ។
ទោះដើរកុំរួសរាន់ គិតឱ្យគ្រាន់សឹមដើរទៅ

| | | |
|---|---|---|
| | កុំឱ្យអាប់អាស្រូវ | កើតជំណៀលផល់អាត្មា ។ |
| ១៥- | កុំយល់ឆ្អិនជាឆៅ | កិច្ចក្នុងក្រៅមានតម្រា |
| | កុំអាងតែប្រាជ្ញា | ចោលក្បួនច្បាប់លោកព្រេងនាយ។ |
| | ស្រដីឱ្យស្រួលស្រេច | គិតសេចក្ដីគ្រប់កុំគិតងាយ |
| | រំពឹងគិតឱ្យឆ្ងាយ | យល់លង្វែកសព្វនានា ។ |
| | ពាក្យព្រេងលោកស្រដី | ថាកុំបីចញ្ចឹមខ្លា |
| | ពាក្យព្រេងលោកឧបមា | គិតត្រង់ណាធ្វើឱ្យបាន ។ |
| | កាន់កពស់ឱ្យខ្ជាប់ | ខ្លាចក្រឡាប់ខាំឯប្រាណ |
| | អូសទូកកុំឱ្យល្អាន | ទឹកថ្លាសោតកុំឱ្យល្អក់ ។ |
| | ស្លឹកឈើឥតកម្រើក | បើកក្រើកត្បិតខ្យល់បក់ |
| | ទឹកថ្លាល្អឹកបើល្អក់ | ត្បិតរលកខ្លាំងសោះសា ។ |
| ២០- | យល់តូចកុំអាលទំ | គួរសន្សំយកជាគ្នា |
| | បានច្រើនកុំអាលពារ | សន្សឹមតិចៗរៀងទៅ ។ |
| | អ្នកមានរក្សាខ្សត់ | ដូចសំពត់ព័ទ្ធពីក្រៅ |
| | អ្នកប្រាជ្ញរក្សាខ្លៅ | ដូចសំពត់នូវសំប៉ាន ។ |
| | អ្នកខ្ពស់រក្សាទាប | ដោយសភាពធម៌បុរាណ |
| | អ្នកឆ្អែតរក្សាឃ្លាន | នាអ្នករុងរក្សាឆ្នារ ។ |
| | រក្សាទៅមករឹង | ឥតកំដឹងអស់អម្បាល |

WAT KHEMARARATANARAM

ចំណេរចេរកាន់កាល ដូចរបងស្រាស់បន្លា ។
កុំធីឆ្អែតតែឯង មិនគិតក្រែងអស់គ្នីគ្នា
គេឃ្លានក្នុងផ្ទៃផ្សា ឱ្យធីរ៉ាបានឆ្អែតផង ។
២៦- កុំមានចិត្តលលើ ពឹងក្រពើឱ្យចម្លង
កុំកាប់ឳសរបង រាំងចំណារឯអាត្មា ។
មានទូកឱ្យមានថ្នោល មានបង្គោលមានយុថ្កា
ទាំងពួរទាំងច្រវា ដើងថែវណាំឱ្យសព្វគ្រប់ ។
ប្រយ័ត្នក្រែងព្យុះខ្យល់ បក់បោកដល់នឹងទល់ទប់
ប្រយ័ត្នប្រយោជន៍គ្រប់ ទើបហៅជាក់ជាគំនិត ។
ពាក្យព្រេងគិតគួរចាំ ដូចបណ្តាំបណ្តៅចិត្ត
ពាក្យព្រេងគួរឱ្យគិត គិតរំពឹងឱ្យគ្រប់គ្រាន់ ។
ពាក្យនេះជាសណ្តាប់ ទុកជាច្បាប់ទៀងជាក់ស្បាន់
ពាក្យនេះជាកំណាន់ កុំណាត់នៅពុំឃ្លាតឃ្លា ។
៣០- តែងតពាក្យទៅទៀត កុំបៀនបៀតអ្នកព្រឹទ្ធា
កុំសង់ផ្ទះបៀតធ្លា ស្រីសាធារណ៍ពុំគង់ទ្រព្យ ។
ស្រីស្រាលខ្លៅប្រច័ណ្ឌ ស្តីជញ្ជាន់ថាពុំគាប់
ពាក្យនេះឥតគេរាប់ ពាលវែងស្អប់ពាក្យមេបា ។
ប្រឡែងវែងច្រើនឈ្មោះ ពាក្យទ្រគោះច្រើនគេថា
កំណាញ់កើតនិន្ទា នឹងសាធារណ៍ពុំគង់ទ្រព្យ ។

កូនកាចវែងចាញ់ម្ដាយ ពាក្យពាយងាយគេវែងស្អប់
ទ្រឹទ្រព្យគេកញ្ជប់ រកគេទៀតគេថាគ្មាន ។
អ្នកទាបវែងស្អប់ខ្ពស់ ត្បិតពឹងយសគេពុំបាន
អ្នកខ្សត់ស្អប់អ្នកមាន ត្បិតពុំបានឱ្យពឹងទ្រព្យ ។

៣៥- អ្នកខ្លៅវែងស្អប់ចេះ ត្បិតតម្រិះគិតគំនាប់
អ្នកខុសវែងស្អប់គាប់ ត្បិតគេរាប់តែអ្នកត្រូវ ។
ពាក្យនេះអស់ម្ល៉េះហើយ កូនចៅអើយយកទុកទៅ
គ្រាន់បានប្រៀនប្រដៅ តកូនចៅផៅសន្ដាន ។
ពាក្យនេះស្មើខ្លួនហើយ កូនចៅអើយចូរចាំប្រាណ
អស់អាចឱវាទទាន ជាសូរេចម្ល៉េះឯងហោង ។

**(ចប់)**

# ច្បាប់ វិធូរបណ្ឌិត

## បទព្រហ្មគីតិ

១- ព្រះខាន់ហើយឥតស្រោម　　នាផ្ទៃក្រោមឥតមន្ត្រី
ក្សត្រិយ៍ពុំចេះគម្ពីរ　　ស្រីឥតគម្ដែងក្រឡា ។
កើតមកជាបុត្រក្សត្រិយ៍　　ពុំប្រយ័ត្នរៀនសាស្ត្រា
ពុំរៀនពិចារណា　　ពុំដឹងក្រឯទុក្ខរាស្ត្រ ។
ពុំតម្កើងពាក្យពិត　　បញ្ជូវិធសីលវិនាស
យកគលាយកប្បាស　　កុំយកមាសលាយនឹងប្រាក់ ។
ប្រើត្រាប់ឯត្រាជូ　　កុំបង់ផ្លូវដោយតម្រាស់
កុំជិះរទេះចាស់　　បាចសាចខ្សាច់កំបុតត្បូង ។
៥- ជាក្សត្រិយ៍ពុំរៀនធម៌　　ពុំដោះសាជំងឺទ្រូង
រាស្ត្រទាស់នឹងចំកោង　　អាក់ចិត្តខឹងសត្វចោមរោម ។
នឹងកើតក្តៅក្រហាយ　　ទុក្ខអន្តរាយភពផ្ទៃក្រោម
រាស្ត្រផងនឹងខឹងចោម　　ជ្រោមខ្វាត់ខ្វាយទីទៃណា ។
រីមិត្រសង្សារស្នេហ៍　　កុំបីប្រែកែពាក្យថា
ស្រឡាញ់នូវសត្យា　　កុំបីស្អប់ឱ្យសាមាន្យ ។
អ្នកកាចសរ[១]ពើក្តី　　សឹងអប្រិយរំជួលប្រាណ
កើតទោសអាត្មាមាន　　គំនូរខុសជាអសារ ។

---

១- សរពើ ដូចគ្នានឹង សារពើ ។

ទោះឆ្លងព្រះគង្គា សាត់អាត្មាកណ្ដាលវាល
ពារសឹកដេញប្រហារ រត់ចេញទៅប្រទះខ្លា ។
ប្រទះទាំងទាកឈ្លើង សឹងជាប់ឡើងខាំអាត្មា
ចំរូងច្រូងបន្លា ជាប់ដោយជើងជាន់ដិតដី ។
ខ្មោចរក្សាគ្រឹះស្ថាន ទោសនឹងមានភូមិលំនៅ
បិតខ្វែងប្រែក្ដាត់ក្ដៅ សឹងហ្មងសៅធ្វើទោសយើង ។
ទាំងនាយពុំរក្សា បៀនបិណ្ឌាកុំឱ្យថ្កើង
អស់ញាតិពុំបន្ទើង សឹងរត់ចៀសចេញទៅឆ្ងាយ ។
ពឹងថ្មោលៗសោតបាក់ ទូកពំនាក់ភ្លូកព្រាត់ព្រាយ
ពឹងបុណ្យបាបកំចាយ សាត់គឃ្លាយដោយខ្យល់នាំ ។
កុំឱ្យចង្វាចឹក ស្ទូវចុះទឹកក្រពើខាំ
អភ័ព្វនៅសាំទាំ ជាទុក្ខសោកនៅស្លេកស្លក់ ។
នូវកើតឯហោចហីន ត្រមោចក្បែណរឹងអាក្រក់
អំពើដ៏លាមក នូវកើតទោសជាសាមាន្យ ។
ដូចពាក្យនៃមនុស្សផង ស្រដីឆ្លងផតប្រមាណ
ពោលពាក្យពារបំពាន ពុំរំពឹងឯក្រោយភ្នែក ។
ពានរពុំដែលស្ទ័គ្រ ស្រីសាធស័ក្តិពុំដែលស្រែក
រីឯមៀមនិងក្អែក ពុំដែលរួមទ្រនំគ្នា ។

ទោះអ្នកជាតិព្រេងព្រឹទ្ធ ចាំរិះរឹតបុរាណា
គួរចងចិត្តស្នេហា សរពើពិតកេរសព្វស្ថាន ។
យកខាលដងសំណា ដោយចិត្តឆតិតឱ្យបាន
រលាយឯខាលភាណា សឹងពុំបានបង់ខាលសោត ។
២០- ប្រទះបោះកាំបិត បង់សុចរិតនៃអ្នកឆោត
បង់ពីរប្រការសោត ត្រូវដំនៀលលោកនិន្ទា ។
កុំកាន់ពាក្យអសត្យ ប្រុងប្រយ័ត្នអង្គអាត្មា
ដ៏លោកបរលោកា បរិបូណ៌បានសុខសួស្ដីហោង ។
កុំពោលពាក្យមុសា វាទវាចាឱ្យមានប្មង
ចំពួកសត្រូវផង តែងយកទោសនៃអាត្មា ។
កុំពោលពាក្យបំពាន តែងនឹងមានដំនៀលថា
ទុយ៌សពិតពុំជា នូវខ្មាសមុខឯងសព្វថ្ងៃ ។
យកខ្មោចគេមកយំ មើលផ្សំថ្នាំព្យាធិ៍ហិនហៃ
ពុំនីរពុំប្រពៃ ពុំបានជាប្រយោជន៍អង្គ ។
២៥- ធ្វើគុណកើតជាទោស យកឈើងប្រោសក្នុងអន្លង់
យកប៉ុយទៅគ្របភ្លើង គុណប្រឡុងអម្បោះផ្កាយ ។
អណ្ដើកអម្ចាស់មាន ហ៊ានឈ្លានពានយកស្មោរងាយ
ក្រួចផ្ទូរពុំផ្ទូរក្លាយ ពុំប្រយ័ត្នគេយកបាន ។

ហេតុចិត្តពុំគិតថ្មៃ អំពីព្រៃពន់ប្រមាណ
អ្នកថ្លោះយសពីប្រាណ ចិត្តពុំក្សាន្តពុំរសាយ ។
អ្នកខ្ជិលចង់តែឆី អ្នកអប្រិយគេមើលងាយ
រក្សាច្រើនផាផាយ ទ្រព្យខ្វាត់ខ្វាយរង្គោះឡើង ។
ដំរីសារចូលទៅ ក្នុងអំពៅនោះរលើង
ទាំងគុម្ពល្អិតដោយជើង នៃដំរីសារចូលហោង ។
អំពៅអំពល់អស់ រលើងឫសទាំងគុម្ពផង
ទាំងស្រែចំការគ្រង ឋានលំនៅឥតអាស្រ័យ ។
អ្នកខ្លាចអួតអាងហ៊ាន ស្រដីវានពួតជើងដៃ
កម្លាំងមានស្មើថៃ ទើបបើអួតអាងសាធារណ៍ ។
រីឯជាទាបាន ស្ងៀមនៅឋានពុំចរចា
សន្សឹមរកឆីស្លា លុះសឹកដល់បន្លឹមាត់ ។
ដូចស្បែកខ្លាទទូរ សឹងសាយគួរគង់ពុំបាត់
កាលស្លាប់គេលះលាត់ លាយយល់ស្អាត់ដូចដែលហោង។
ដូចពុតពាលពុំជា កុំផ្គន្ធាទោសទណ្ឌផង
ផងតប់ងាល់វាយចង ពុំចេះចោលពុតបាត់បង់ ។
ដូចខ្សៀនកន្ទុយឆ្កែ ទោះនូវប្រែពត់ពុំត្រង់
យកប្រេងទូនរឹតទង់ រោលភ្លើងពត់ពុំត្រង់បាន ។

ដូចពុតពាលសក់ឡក់ ចិត្តអាក្រក់ធ្វើលឹកលាន
យល់ធម៌ដំបូន្មាន ចិត្តពុំចូលពុំចង់ស្ដាប់ ។
ទឹកហូរចេញចូលណា ដោយច្បាប់ថាលោកប្រើគ្រាប់
ជាញាតិសន្ដានស្រាប់ គួរបីគ្រាប់អំពើពង្ស ។
អ្នកតូចឥតមេត្រី ចងជាក្ដីមែនគ្មាចង់
ទ្រព្យធននាយពុំគង់ បទបំណាងឯងឱ្យបាត់ ។
ទោះបីយល់គេខុស កុំប្រទូស្ដប្រទះមាត់
យល់ប្លែកប្រើប្រយ័ត្ន គួរលែងសាធសេចក្ដីធម៌ ។
៤០- ទោះបីជាតិអ្នកចេះ មានចំណេះអាងដឹងអាថ៌
ប្រើធ្ងន់ប្រើដោះសា ដោយសណ្ដាប់ព្រះធម៌ស្រាយ។
វីពាក្យពាលកម្លៅ ពុំដឹងជ្រៅដោយបរិយាយ
នាំពាក្យទៅនិយាយ ដើរប្រាប់ប្រាយឱ្យអប្រិយ ។
អម្ចាស់អ្នកប្រើទៅ វិលវល់នៅពុំខ្វាចក្ដី
ស្វែងទ្រព្យសរពើអ្វី អង់អាលឥទ្រព្យសាធារណ៍ ។
ប្រើទៅជារាជទូត ចិត្តពុំស្លូតធ្វើក្រៅសារ
ចេះចាំនូវអស់អាថ៌ ជារាជសារទូរាគមន៍ ។
ជារាជបុរោហិត រាជបណ្ឌិតគ្រូហោរធំ
ពុំមានប្រព្រឹត្តក្រម លោភក្រៃលែងអ្នកសាមាន្យ។

៤៩- ទោះគេស្រឡាញ់ហោង ប្រើចេះស្នងស្រលាញ់ថ្កាន
បណ្ដាញហាឫទ័យក្សាន្ត សមស្នេហាមិត្រមេត្រី ។
ទោះចេះក្ដីកិច្ចកល ប្រើចេះយល់អាថ៌នោះមិញ
អប្រិយប្រើចៀសចេញ ទូរទីឆ្ងាយឱ្យបាត់ដាន ។
ពុំគួរយកខ្លួនគប់ គួរតែស្អប់ហេតុសាមាន្យ
កុំសេពអាស្រ្រូវប្រាណ ពាក្យដំនៀលត្រូវឯភ្នែក[1]។
កុំយកពងមាន់ផ្ញើ ពូជ៍លើសំបុកក្អែក
អ្នកជំកុំផ្ញើដែក អ្នកប្រមឹកកុំផ្ញើស្រា ។
កុំបីយកសំរិទ្ធ ផ្ញើអ្នកស្និតនោះពុំជា
រីឯអ្នកចំការ កុំយកគ្រាប់ត្រសក់ផ្ញើ ។

៥០- ទោះស្រូវភោជ្ជសាលី ទុកកុដុម្ពិក៍នោះឃាត់ប្រើ
កុំមានចិត្តសើរើ យកមកផ្ញើនៅជលស័យ ។
បញ្ញើបួនប្រការ ពិចារណាឱ្យអស់ក្ដី
កុំមានពាក្យអប្រិយ ខ្លាចចំណោរដំនៀលថា ។
កាលក្អែកចេញធីលុះ រាត្រីនោះមៀមភោក្ដា
មានសឹករកអាសា ទៀបអាត្មាកុំឃ្លាតឆ្ងាយ ។
ទឹកឡើងស្រមោចលង់ លុះចំណង់ត្រីសប្បាយ
ស្រមោចក៏អន្តរាយ លុះចំណោរចំណាប់ល្អ ។

---

១- ឯភ្នែក = ឯនាយ, ខាងមុខ ។

លុះទឹករីងស្ងួតទៅ ត្រីផងនៅអាត្មាមរណ៍
អនេកអនន្តរ លុះចំណោរស្រមោចស្មុង ។
៥៥- នេះមានពៀរវេរា ពីបុរាបុរាណហោង
សព្វឋានកុំកន្លង ហេតុចំណងពីព្រឹទ្ធព្រេង ។
បានឆុកបទវាទី បានជាក្ដីបទចិត្តឯង
ហេតុចិត្តវៀចវង្វេង បង់ទ្រព្យឯងបទចិត្តស្រាល ។
រីអ្នកខ្ជេញខ្ជិលខ្ជាយ កុំបីឱ្យកាន់នូវការ
ពាលាអន្ធពាល កុំឱ្យធម៌ឥតចិត្តចង់ ។
ទោះបានសត្វបក្សី ប្រក្រតីតិចស្លាប់បង់
រីក្ដីដឹងសព្វអង្គ ប្រើគិតផ្សងគំនិតច្បាប់ ។
ប្រើត្រាប់ឯតាំងយូ ក្រឯគ្រូពុំគួរត្រាប់
កុំយល់មួយកណ្ដាប់ ជាមួយនឹងកំបង់ដៃ ។
៦០- កុំយល់សសោភា កុំបីថាជាខ្មៅក្រៃ
បន្តិចនេះប្រពៃ គួរត្រាប់កុំបីភ្លេចឡើយ ។
ទោះបីដំរីបាត់ លោកប្រើស្ដាត់វាជាត្រើយ
តាមនឹងដំរីហើយ កុំបីដើរនឹងជើងលា ។
ទោះទូកដាច់សាត់សោះ យកទូកស្មោះទៅតាមគ្នា
នេះពាក្យព្រេងលោកថា ទុកជាច្បាប់តម្រាប់កេរ ។

រីអ្នកមានប្រាជ្ញា សង្ស័យរាយល់ពុំថេរ
ទុក្ខសោកភ័យចំណេរ ប្រើផ្តាច់ផ្តិលនិរាសស្ថាន ។
ស្រុកមានសឹកកុំបី ទៅជួញទ្វីរកធនធាន
រីខ្លួនកំព្រាប្រាណ ក្រុរក្សាទ្រូវមាសប្រាក់ ។

៦៥- ចោរក្បួយចាំប្លៃប្លន់ ផតតំបន់ណានឹងលាក់
ខ្លួនឯងផតបើដាក់ សារពើទ្រព្យបាត់អស់ឯង ។
តំបន់នទីជ្រៅ កុំងូតនៅម្នាក់ឯងលេង
ទឹកហូររំពងគ្រែង កុំបីអាលចុះទូកឆ្លង ។
ក្រពើក្រពាពាំង សាហាវចាំសព្វព្រែកផង
ចាំចាប់ដោយបំណង បីដូចខ្យល់នឹងភ្លើងព្រៃ ។
ដំរីគជសារធំ ឧទារជុំជាញជល់នៃ
ច្រើនរត់ចៀសចេញវៃ កុំយកខ្លួនទៅទប់ទល់ ។
កម្លាំងតិចពិតអង្គ ឯងថាអ្នកឯណាយល់
ទើបបានខ្លួនទុព៌ល លុះនៅដួលអាត្មាមរណ៍ ។
ព្រះធម៌នេះជាច្បាប់ ប្រសើរគាប់ឱ្យអស់នរ
អ្នកផងចាំបានបរិ- បូណ៌ដល់ត្រីពិធសួគ៌ហោង ។

**(ចប់)**

# ច្បាប់ ត្រីនេតិ

## បទភាកគតិ

១- បពិត្រមហារាជ ទ្រើសទ្រង់អំណាច អញ្ជើញស្ដេចស្ដាប់
ទំនឹមទំនង នេះហោងជាច្បាប់ ទុកជាសណ្ដាប់
នៃនរជនជាតិ ។

នរអ្នកណា នឹងចូលទៅជា វររាជអមាត្យ
សេនាមន្ត្រី កវីជាអាទិ៍ រៀនច្បាប់ជាខ្នាត
តែងទុករៀងទៅ ។

បម្រើព្រះបាទ ព្រះបរមនាថ អធិរាជចមចៅ
ឱ្យសមឱ្យល្មម នឹងក្សត្រានៅ ឱ្យឡើងគាល់ហៅ
អ្នកជាអម្ចាស់ ។

មួយនោះព្រះអង្គ ក្សត្រាទ្រើសទ្រង់ គ្រងផ្ទៃក្រោមក្រាស់
គួរមានមនោរម្យ សុខសមសោមនស្ស រៀនឱ្យច្បាស់លាស់
ត្រង់ច្បាប់នេះណា ។

៥- អស់មុខមន្ត្រី ដោយព្រះបាលី នាសតិរាជា
បើមុខមន្ត្រី ពុំពិចារណា នឹងក្បិណក្សត្រា
ពុំលែងឡើងហោង ។

ត្បិតមុខមន្ត្រី សេនាបតី ពុំដោយគន្លង
លោភោចង់បាន បំពានរាស្ត្រផង រាស្ត្ររឹងក្តៅហោង
អង្គឥតអាស្រ័យ ។

រាស្ត្រដូចមច្ឆា មន្ត្រីសេនា ដូចគង្គានៃ
បើប្រែជាក្តៅ ក្រៃក្រៅវិស័យ រាស្ត្ររឹងកើតភ័យ
អង្គឥតពំនាក់ ។

មន្ត្រីយោធា បីដូចព្យគ្ឃា និងពស់ពញ្ញាក់
រីអស់រាស្ត្រផង ចរចូលពឹងពាក់ ក្បិណាប្រែជាយក្ខ
យង់ឥតករុណា ។

មួយ កុបុត្តំ នាសតិធនំ បទបន្ទែថា
បើមានកូនកាច កំណាចហើយណា សឹងវិនាសប្រា-
កដគឺសន្តាន ។

១០- មួយ កុភូមំ នាសតិធនំ វិនាសធនធាន
នៅភូមិអាក្រក់ នោះនឹងកើតមាន ព្យាធិបៀតប្រាណ
ពិតពុំប្រពៃ ។

មួយ កុគេហំ នាសតិរីជំ បន្ទែនេះនៃ
នៅផ្ទះអាក្រក់ នឹងកើតហឹនហៃ ប្រាជ្ញាញាណញៀយ្យ
អាប់ឥតមង្គល ។

កើតកេរ្តិ៍អាប់យស ដោយនូវពាក្យមនុស្ស គេដើរមកយល់
ហើយគេដឹងថា ផ្ទះអាក្រក់សល់ កើតអពមង្គល
ដោយពាក្យគេថា ។

ឯសុមន្រ្តី ដោយអាថ៌បាលី វុឌ្ឍិរាជា
បើមុខមន្រ្តី មែនមានប្រាជ្ញា ដឹងអស់អធ្យា-
ស្រ័យគ្រប់ប្រការ ។

តម្រង់មហាក្សត្រ សោយរាជសម្បត្តិ ក្សេមក្សាន្តភពភារ
អស់រាស្ត្រមណ្ឌល សកលបរិពារ សឹងអស់រង្គាល
ដល់តិចឡើយហោង ។

១៥- ឯសុបុត្តំ វុឌ្ឍិកុលំ ថាបើកូនផង
មែនមានគំនិត ល្អឥតឯហ្មង សឹងចម្រើនបង
ប្អូនសាច់សន្តាន ។

ឯសុភូមំ វុឌ្ឍិធនំ ថាទោះភូមិស្ថាន
ល្អហើយនោះនឹង ចម្រើនធនធាន សារពើសឹងបាន
ដូចចិត្តប្រាថ្នា ។

ឯសុគេហំ វុឌ្ឍិវីជំ ថានៅគ្រឹហា
ល្អហើយនោះនឹង ចម្រើនប្រាជ្ញា សារពើប្រាថ្នា
ពិតពុំកម្រ ។

ទោះអ្នកផងដើរ គេសឹងសរសើរ ថាផ្ទះនោះល្អ
ចម្រើនសួស្ដី ចម្រើនមាត់ម- នុស្សផងគេសរ-
សើរផ្ទះនោះនៃ ៕

ច្បាប់នេះត្រកាល សូមព្រះភូបាល បរមក្សត្រិយ៍ថ្លៃ
ទ្រង់ព្រះតម្រិះ ត្រិះដោយញាណញៀយ្យ ទុកក្នុងហឫទ័យ
ជាច្បាប់ទៅហោង ៕

២០- បពិត្រព្រះបាទ ព្រះបរមនាថ លើសលោកកន្លង
ជាតិជាឥស្សរ កំពូលរាស្ត្រផង ព្រះអង្គជាច្បង
ឯងឥតផ្ទឹមដល់ ៕

យកព្រះប្រាជ្ញា យកព្រះញាណថ្លា ថ្លែងព្រះយោបល់
ត្រេកត្រិះកម្រាប អ្នកបាបកំហល់ ឱ្យនីរព្យសន៍[១]សល់
បានដូចប្រាថ្នា ៕

ទុក្ខរាស្ត្រទាំងឡាយ ក្នុងក្រោមបន្ទាយ សព្វព្រះមាត្រា
ព្រះឱស្ឋបណ្ដាំ ទុកលើសិរសា ទម្ងន់អាជ្ញា
លើរាជមន្ត្រី ៕

បពិត្រមហារាជ ទ្រើសទ្រង់អំណាច ចេស្ដារិទ្ធី
អញ្ជើញស្ដេចស្ដាប់ ជាច្បាប់គម្ពីរ សព្វព្រះវេណី
ថ្កល់ថ្កើងចំពោះ ៕

១- ព្យសន៍ ទុក្ខ, អំពើអាក្រក់, សេចក្ដីវិនាស,

បី ៗ អសារ បីៗឥតការ បីៗសូន្យសោះ
ម្តេចហៅអសារ ឥតការដូច្នោះ ម្តេចហៅសូន្យសោះ
ទេទៅឥតត្រើយ ។

២៥- នាហៅអសារ មានទ្រព្យឥតការ ពុំធ្វើបុណ្យឡើយ
ពុំសងគុណគេ អ្នកឯទៀតឡើយ ញាតិឯងជាត្រើយ
ពិតពុំស្រោចស្រង់ ។

នាហៅឥតការ ចាំសីលាចារ មោះឥតពាក្យត្រង់
ចិត្តចង់បានបុណ្យ ពុំប្រណិប័តន៍សង្ឃ ចង់យសបានអង្គ
ពិតពុំឧស្សាហ៍ ។

នាហៅសូន្យសោះ ពួធម៌ពីរោះ ពុំស្តាប់ធម្មា
យល់ក្រឹត្យក្រមច្បាប់ ពុំស្តាប់ក្រឹត្យជា ដឹងព្រះធម្មា
ពុំធ្វើបរិសុទ្ធ ។

បីផ្គង់ស្នេហា បីផ្គង់ភរិយា បីៗផ្គង់បុត្រ
ម្តេចហៅស្នេហា ភរិយាបរិសុទ្ធ ម្តេចហៅផ្គង់បុត្រ
អស់ន័យនេះផង ។

នាផ្គង់ស្នេហា រស់គាប់ពិសា កុំភ្លេចឡើយហោង
សំណេះសំណួរ សាកសួរស្នេហ៍ស្នង ឧត្បាតនេះហោង
ពុំបង់ឡើយនៃ ។

៣០- នាផ្គង់ភរិយា រណ្ដាប់គ្រឹហា ខ្ជាប់ខ្ជួនប្រពៃ
ទោះទ្រព្យរបស់ អម្រស់ទុកដៃ រក្សាសំចៃ
ពុំធ្លោយឡើយណា ។

នាហៅផ្គង់បុត្រ ប្រពៃបរិសុទ្ធ ឱ្យរៀនសាស្ត្រា
សិល្បសារពើគាប់ ជាច្បាប់អាត្មា អរឱ្យភរិយា
ដូចដោយចិត្តថ្វាត់ ។

បីៗបានល័ក្ខណ៍ បីៗបានស័ក្តិ បានសួស្ដីថ្វាត់
ម្ដេចហៅបានល័ក្ខណ៍ បានស័ក្តិបង់បាត់ បានសួន្យទៀងទាត់
ន័យនេះសោតហោង ។

នាបានលក្ខណា សរសើរអាត្មា ឯងចេះកន្លង
ពោលឥតគេស្ដាប់ សូរស័ព្ទសាសង ចូលស្ថានអ្នកផង
ឥតគេស្រដី ។

នាហៅបានល័ក្ខណ៍ ស័ព្ទគងព្យជាក់ ឥតស័ព្ទភេរី
មានមហាក្សត្រា ឥតមានក្សត្រី មានរាជធានី
ហើយគ្មានបន្ទាយ ។

៣៥- នាបានសួស្ដី ល័ក្ខណ៍ផ្ទះអប្រិយ ភូមិសោតរំសាយ
ស័ក្តិសឹងពុំជា យាត្រាទៀបឆ្ងាយ និមិត្តស្អុនកាយ
អង្គឱ្យអប្រិយ ។

បី ៗ បាត់ស្និទ្ធ បីៗបាត់មិត្ត បីបាត់ពន្លឺ
ម្ដេចហៅបាត់ស្និទ្ធ បាត់មិត្តមេត្រី ពន្លឺរស្មី
បាត់បង់នោះណា៎ ។

នាហៅបាត់ស្និទ្ធ ពោលពាក្យខុសចិត្ត ខ្សឹបខ្សៀវជេរថា
ធ្វើមុខអាក្រក់ កុហកមុសា ហេតុនោះលោកថា
បាត់ស្និទ្ធពុំមាន ។

វិន័យបាត់មិត្ត ពោលពាក្យពុំគិត សត្យាសងសាន
នាស្ពានលំនៅ ពុំទៅមកថ្កាន ខ្វិទ្រព្យបង្ខាន
មុខពុំឱ្យយល់ ។

នាបាត់ពន្លឺ ភ្នែកពិតពុំភ្លឺ ពុំយល់បរិបូណ៌
ឥតសាច់ឥតញាតិ ស្ដាប់ស័ព្ទស្ដាប់សូរ ពិតពុំបរិបូណ៌
វិញ្ញាណឯងអាច ។

៤០- បីបាត់ខុនណាង បីៗបាត់ជាង បីៗបាត់ប្រាជ្ញ
ម្ដេចបាត់ខុនណាង បាត់ជាងឯងអាច ម្ដេចហៅបាត់ប្រាជ្ញ
ទាំងបីនេះណា៎ ។

នាហៅបាត់ខុន ណាងនេះជាមុន ស្រីមានលក្ខណា
ពុំស្ដាប់អម្ចាស់ យប់ថ្ងៃឡើយណា៎ ខ្លួនចាស់ព្រឹទ្ធា
ស្រដីឡេះឡោះ ។

| | | |
|---|---|---|
| វិបាត់ជាងជាតិ | ធ្វើការឥតខ្នាត | ពុំស្រេចការនោះ |
| វាតែងឲ្យឃ្លាត | នឹងខ្នាតស្វន្យសោះ | ពុំត្រូវចំពោះ |
| | នឹងក្បួនច្បាប់ឡើយ ។ | |
| នាបាត់ប្រាជ្ញប្រុះ | កាលជំនុំនោះ | ស្ងៀមស្ងាត់ព្រងើយ |
| ពាក្យពុំស្រដី | តិរ្ថិយឥតត្រើយ | ពុំសេពគប់ឡើយ |
| | មារយាទអប្រិយ ។ | |
| បីៗបានរស | បីៗសប្បុរស | បីៗពន្លឺ |
| ម្ដេចហៅមានរស | សប្បុរសមេត្រី | ពន្លឺរស្មី |
| | ចាយចែងចរចា ។ | |
| ៤៥- ទោះមានរសកាល | សេពសោយអាហារ | មានរសពិសា |
| អ្នកមានសប្បុរស | កបរសវាចា | មែនមានភរិយា |
| | មារយាទប្រពៃ ។ | |
| វិសប្បុរិសា | ប្រកបលក្ខណា | មានធម៌សោតនៃ |
| ស្រដីនូវអាថ៌ | ជាធម៌ឈ្លាសវៃ | គាល់អម្ចាស់ថ្លៃ |
| | មានពិចារណា ។ | |
| វិពន្លឺនោះ | កាលហ្វូបបាយឆ្លោះ | ទៀងទើបភោក្តា |
| ពោលពាក្យនូវអ្នក | មានព្រះប្រាជ្ញា | ប្រកបភរិយា |
| | ប្រណិប័តន៍សព្វកាល ។ | |

បី ៗ ហ៊ានហោច បីៗត្រមោច បីៗសាធារណ៍
ម្តេចហៅហ៊ានហោច ត្រមោចឥតការ ម្តេចហៅសាធារណ៍
ស្រេចស្រាយចេញហោង ។
នាហៅហ៊ានហោច អសារអសោច ខ្លួនខ្លៅធ្វើឆ្គង
គប់នូវអ្នកផឹក ប្រមឹកស្រាផង ប្រពន្ធសោតហោង
ស្រដីមាយា ។

៥០- នាហៅត្រមោច ត្រមោលកណ្តោច កណ្តែងកំព្រា
ឯងមានរបៀប ឥតប្រៀបអ្នកណា ឥតបុត្រស្នូនភ្ជា
ត្រមោចសោតសល់ ។
នាហៅសាធារណ៍ មានព្រៀងឥតការ បំបែកកិច្ចកល
ប្រពន្ធឫស្យា អាត្មាទុព៌ល រឹងព្រួតបំណុល
លើខ្លួនទៀតក្ងរ ។
បីៗសាមាន្យ បីអន្តរធាន បីៗអាស្រូវ
ម្តេចហៅសាមាន្យ អន្តរធានក្ងរ ម្តេចហៅអាស្រូវ
ពាក្យនេះលោកថា ។
នាហៅសាមាន្យ សង់ផ្ទះនាស្ថាន ទៀបផ្សារពុំជា
គប់នូវអ្នកពាល សាធារណ៍មោហា ប្រពន្ធនោះណា៎
ច្រើនបំណុលនៅ ។

រីអន្តរធាន　សង់ផ្ទះនាស្ថាន　នោះនៅជិតផ្លូវ
ខ្លួនវែងអប្រិយ　មានក្តីអាស្រូវ　ប្រពន្ធនោះកូវ
ប្រមឹកស្រាផង ។

៥៥- នាហៅអាស្រូវ　សង់ផ្ទះជិតផ្លូវ　ធ្លានោះសោតហោង
ម៉ែក្មេកពុំជា　មាត់រឹងកន្លង　ប្រពន្ធនោះហោង
គេលែងទៀតទ្វិ ។

បីៗបរលោក　បីៗពុំថោក　បីៗលោកិយ
ម្តេចហៅបរលោក　ពុំថោកនោះក្តី　ម្តេចហៅលោកិយ
គួរដឹងសោះសា ។

នាហៅបរលោក　រកគ្រូនាលោក　ដ៏មានប្រាជ្ញា
ខ្លួនសោតពុំទ្វិល　ចាំសីលភាវនា　ចិត្តថ្លាសទ្ធា
ពុំដែលដាច់ឡើយ ។

នោះហៅពុំថោក　រក្សាប្រាណលោក　ដំណឹងខ្លួនហើយ
អង្គុយខ្ពង់ខ្ពស់　ថ្កើងយសជាត្រើយ　ភរិយាគាប់ហើយ
ត្រកូលថ្លៃផង ។

នាហៅលោកិយ　ពុំយល់ឯងក្តី　មានច្បាប់សោតហោង
ពាក្យពោលសត្យា　ចរចាឥតហ្មង　ពាក្យពីរោះផង
សាន្តសមសាទរ ។

WAT KHEMARARATANARAM

៦០- បី ៗ ប្រាសលោក បីៗថយថោក ប្រាសលោកុត្តរ
ម្តេចហៅប្រាសលោក ថយថោកពុំប- រិបូណ៌លោកុត្តរ
ឲ្យពិចារណា ។

នាហៅប្រាសលោក ស្រដីថយថោក ពាក្យនោះពុំជា
ខ្លួនឯងតំអឹង ពាក្យរឹងមហិមា យល់ចាស់ព្រឹទ្ធា
ពិតពុំប្រណិប័តន៍ ។

ថោកប្រាណពេកណាំ ទុរយសអសារ អង្គុយថយក្តាត់
អាហារថយផ្ងង់ បម្រុងពីមាត់ នេះហោងលោកកាត់
ហៅថយថោកហោង ។

រីប្រាសលោកកូវ គួរនោះពុំត្រូវ ដោយធម៌ទំនង
យល់សង្ឃឥតចិត្ត ប្រណិប័តន៍សង្ឃផង សីលទាននោះហោង
ពុំស្គាល់ឡើយណាំ ។

មានតែបំបាត់ ជីវិតសព្វសត្វ ឥតមានមេត្តា
ហៅប្រាសលោកកូវ គួរនៅឯណា មានពន្ធបីប្រា-
ការអកុសល ។

៦៥- ព្រះអង្គមហាក្សត្រិយ៍ សោយរាជសម្បត្តិ គ្រងរាជ្យមណ្ឌល
រើសរកសេនា ឲ្យជាសុខពល ហើយនឹងតម្កល់
ស្នងព្រះនេត្រន័យន៍ ។

ក្រឡាពាសធំ ជាមេកងជុំ ការសង្គ្រាមជ័យ
ស្រាល់រកអ្នកណា ចេះអធ្យាស្រ័យ មានប្រាជ្ញាវៃ
ស្គាល់គ្រប់រាជការ ។

ស្គាល់ទោសស្គាល់គុណ ស្គាល់ក្រោយស្គាល់មុន ដើមចុងកណ្ដាល
ស្គាល់បាបស្គាល់បុណ្យ ស្គាល់ធ្ងន់ស្គាល់ស្រាល ស្គាល់ប្រាជ្ញស្គាល់ពាល
ស្គាល់ខ្លាចស្គាល់ហ៊ាន ។

ស្គាល់តិចស្គាល់ច្រើន សង្ខាតក្រវើន ស្គាល់អត់ស្គាល់ឃ្លាន
ស្គាល់វៀចស្គាល់ត្រង់ ស្គាល់ភូតស្គាល់មែន ស្គាល់ដីស្គាល់ដែន
ស្គាល់ព្រៃស្គាល់ត្រាញ់(១) ។

ស្គាល់គាប់ស្គាល់ខុស ស្គាល់ស្លាប់ស្គាល់រស់ ស្គាល់ឈ្នះស្គាល់ចាញ់
ស្គាល់បាញ់ស្គាល់បោះ ស្គាល់ដោះស្គាល់ដេញ ស្គាល់ចូលស្គាល់ចេញ
ស្គាល់បាត់ស្គាល់មាន ។

៧០- ស្គាល់តឹងស្គាល់ធូរ ស្គាល់ឆាប់ស្គាល់យូរ ស្គាល់ហូលស្គាល់ខៀន
ស្គាល់ដើរស្គាល់ដេក ស្គាល់ស្រេកស្គាល់ឃ្លាន ស្គាល់បង់ស្គាល់បាន
ស្គាល់មានស្គាល់ខ្សត់ ។

បើមានកង្វល់ កលិយុគមកដល់ គេប្រាប់ប្រាកដ
បាកុំឆោតឆល់ វិលវល់រន្ធត់ កុំផ្សរឃ្លរត់
តំអក់តំអឹង ។

---

១- ត្រាញ់, វាលតូចមានស្មៅទាបៗ ។

កុំច្រើនវង្វេង ងងោងងងេង មមីមមមឹង
កុំច្រើនប្រទូស្ត រឹងរូសរបឹង កុំខ្ជិលរំពឹង
តែងដេកនិទ្រា[១] ។

កុំលោភចង់បាន ទ្រព្យគេបំពាន ពន្លឹកសោះសា
កុំរៀនកំណាញ់ ស្វិតស្វាញឫស្យា ពុំស្គាល់កាចជា
ពាក្យពេចន៍ទ្រគោះ ។

កុំលេងជាល្បែង រំពឹងយល់ល្បែង ពាក្យពុំពីរោះ
ស្រដីឱ្យដាច់ ឱ្យស្រេចឱ្យស្មោះ កុំធ្វើឡេះឡោះ
សសោះអន្ទង ។

៧៥- កុំធ្វើហេងហាង កុំអួតកុំអាង ខុសក្ដីបំណង
កុំច្រើនក្រអែស ប្រហែសលេងលង ឱ្យរៀនត្រង់រង
នូវក្ដីអំណត់ ។

អ្នកណាអាចស្គាល់ អាចដឹងអស់អាថ៌ ជាក់ជាងប្រាកដ
ធ្វើការសង្គ្រាម ព្យាយាមចំហុត ពុកេរ្តិ៍ប្រាកដ
ដូចព្រះរាមា ។

ស្ដេចផ្ចាញ់អសុរ អស់ឥតសំណល់ ដល់មួយឡើយណា
បើបានសណ្ដាប់ ក្រមច្បាប់សាស្ត្រា ទុកអង្គអាត្មា
ទីទៃគ្រប់ប្រាណ ។

---
១- ដំណើរដេកលក់ ។

វិច្បាប់នេះណា បើអ្នកឯណា យកទុកឱ្យបាន
ក្នុងអង្គអាត្មា ជាសណ្តាប់ប្រាណ អ្នកនោះនឹងបាន
ជាអង្គអ្នកប្រាជ្ញ ។

បើអ្នកឯណា បានមើលអក្ខរា ថាឱ្យស្រួលស្រេច
ជួយជួសសេចក្តី អស់អាថ៌សេចគ្រេច ឱ្យទានបន្តិច
កុំសើចឡើយហោង ។

៨០- ជួយកែឱ្យត្រូវ តម្រង់តម្រូវ ដោយនូវគន្លង
ថាច្បាប់បុរាណ ពិតពីព្រេងហោង ឱ្យត្រូវបំណង
ព្រេងព្រឹទ្ធបុរាណ ។

សេចក្តីនេះណា និទានអស់អាថ៌ ចប់បរិបូណ៌បាន
នេះហោងជាច្បាប់ សណ្តាប់គ្រប់ប្រាណ ឱ្យឱវាទទាន
និដ្ឋិតំចប់ហោង ។

**(ចប់)**

# ច្បាប់រាជនេតិ ឬ ច្បាប់ព្រះរាជសម្ភារ[១]

## បទភាគគតិ

១- ហៃសាធុជនផង នេះគឺចំណាង បទបាលីថា
គម្ពីររសធម៌ អាណាក្រិត្តិកា គួរគប្បីមហា-
ជនផងត្រងត្រាប់ ។

ធម៌នេះដំបូន្មាន រួមរក្សាប្រាណ ឲ្យបានក្តីគាប់
ដល់លោកបរលោក ហៅរស់ពុំស្លាប់ ធម៌នេះជាច្បាប់
ក្តីគាប់បរិយាយ ។

កុំទុកចិត្តបរទេស កុំទុកចិត្តអភិនេស្រ្កម៏ កុំទុកចិត្តអភិប្រាយ
ប្រើស្ងំលែងខ្ពស់ រំពឹងឲ្យឆ្ងាយ ស្តាប់ពាក្យបរិយាយ
បណ្ដិបមេជី ។

កុំជឿងដោយខ្យល់ កុំឲិនពាក្យពល កុំខ្វល់ដោយស្រី
កុំកាន់ពិសយង់ គប់នឹងស្ត្រី សមណៈជនជី
កុំឲ្យក្តីត្រូវ ។

៥- កុំនៅញ៉ាំងឈ្មោះ កុំស្តាប់អសុរោះ កុំស្តាប់អាស្រូវ
កុំដើរពានស្មុន កុំស្កាត់ប្រកផ្លូវ កុំធ្វើស្រែស្រូវ
នៅផ្លូវដំរី ។

---

១- " ច្បាប់ព្រះរាជសម្ភារ " ហៅតាមនាមលោកអ្នកតែង គឺព្រះស្រីធម្មរាជា ព្រះរាជសម្ភារ ។

ផ្អែមពីរប្រការ ចំណីនៅដាល កុំអាលឱ្យធី
ផ្អែមមួយពាក្យពាល វែងវាលរកក្តី ផ្អែមមួយពាក្យស្រី
ស្រដីមាយា ។

ពាក្យគ្រូវែងរឹង ស្រាវែងស្រវឹង ពុំដែលពិសា
ពាក្យពិតវែងស្វែង ពុំពីរោះថា បណ្ឌិបមេបា
វែងថាពុំគាប់ ។

ខ្លាវែងស្អប់ចេះ ខ្សត់ឥតចំណេះ ស្អប់អ្នកមានទ្រព្យ
ស្រីស្រាលប្រចណ្ឌ វែងស្អប់ខ្ញុំគាប់ ពាលពិតឥតច្បាប់
វែងស្អប់ប្រដៅ ។

ចង់បុណ្យបានបាប ចចើងចង់លាភ វែងបាត់ធនទៅ
មានះបាត់មិត្ត ឥតអ្នកជាផៅ គ្រេវគ្រោធឃោរឃៅ
វមែងបាត់អង្គ ។

១០- ស្វែងគាប់បានយស ចង់ស្វែងរបស់ ប្រើចេះផ្គត់ផ្គង់
ចង់ធំកុំអួត ដើមមានពូជពង្ស ចង់ឱ្យខ្លួនត្រង់
ប្រើផ្គាប់អ្នកមុខ ។

ខ្វែងហើរត្បិតខ្យល់ នាយថ្កើងត្បិតពល រក្សាឱ្យសុខ
ទ្រព្យគង់ត្បិតស្រី ចេះសំចៃទុក ផ្ទះធំស្រណុក
ត្បិតភរិយាជា ។

បាត់យសត្បិតខ្ជិល បាត់ញាណទានសីល ត្បិតសេពសុរា
ប្រមាថបាត់បុណ្យ ទឹងបាត់ប្រាជ្ញា លេញលេងដៀលថា
បាត់ឥរិយាគាប់ ។

អត់ឱនឥតទោស ធ្វើចិត្តសន្តោស បង្កើតជាទ្រព្យ
មេត្រីជាញាតិ រក្សាដល់ស្លាប់ ចៀសក្តីពុំគាប់
ជាគន្ធពិដោរ ។

ទឹកបាក់ទៅទាប បុណ្យបាត់ត្បិតបាប លាភបាត់ត្បិតឃោរ
ទឹកថ្លាត្បិតរលក ពុំយល់ស្រមោល ទោសកើតត្បិតពោល
លួមមាត់ឈ្លានពាន ។

១៥- ខ្លៅវែងស្អប់ប្រាជ្ញ នាអ្នកខ្លួនខ្លាច វែងធ្វើជាហ៊ាន
ខ្សត់ខ្សោយស្មុតទ្រុឌ វែងធ្វើជាមាន អ្នកឥតសន្តាន
វែងមើលគេងាយ ។

ទាហានថ្កើងត្បិតសឹក ធ្វើស្រែត្បិតទឹក ត្រឹកពលត្បិតបាយ[១]
សិស្សប្រាជ្ញត្បិតគ្រូ ដេរពោលដំវាយ ពលជាត្បិតនាយ
ហ៊ឹកហ៊ឺនខឹះខំ ។

រៀនក្តីគួរគិត ចាស់ឥតប្រព្រឹត្ត នៅប្រែប្រទ្បំ
អ្នកជាជាកាច តូចប្រែជាធំ ពង្សព្ធជឧត្តម
ប្រទ្បំជារាស្ត្រ ។

---
១- ត្រឹក ពាក្យបុរាណ ប្រែថា: ដឹកនាំ, ក្រើនរំលឹក ។

ឃើញសេះជាលា ក្ងានជាទា ពពាយជាទាស[1]
សំណជាប្រាក់ ស្ពាន់ឆ្លាក់ជាមាស បង្គួយជាជាស
កប្បាសជាគ ។

ហេតុនេះគួរគិត គួររិះរកបិត ដឹងរសគន្ធ
ពិដោរអសុដោរ ពីសាសាទរ បិតហើយសឹមប-
រិភោក្ដាក្ដិត ។

២០- ល្ពឹកព្យាក្យពេចន៍ សាកសួររកសាច់ សន្ដានព្រេងព្រឹទ្ធ
រករិះកលអ្វី សុចរិតទុច្ចរិត ហើយហោងគួរគិត
ឱ្យដឹងខ្ពស់ទាប ។

ដូចខ្លាក់បាំងស្បែក មួយដូចតំពែក ចង់សុំប្រេងលាប
ដូចថ្លង់ស្ដាប់ច្រៀង ទះដៃព្រាកៗ ដូចខ្វិនអាបឡាប
ចង់ចងក្បិនរត់ ។

ពុតញ្ញាយមានបី មួយដូចដំរី សាហាវឥតបទ
អាចផ្ទុះផ្សាំបាន កង្វេរកាន់កត់ ដាលដេញគោតគត់
ប្រាំមួយហត្ថហោង ។

មួយចង់ឈ្មោនីស ចិត្តចង់ចចេស កុំដោយគន្លង
ពាក្យពោលអ្នកធំ ប្រទ្បាំស្ងួរសង ពុំគិតក្ដីហ្មង
ចង់ចេរអន្ដរាយ ។

---

១- ឈ្មោះវល្លិ៍ព្រៃមួយប្រភេទ សន្ដានពពាយជ្រុង ប៉ុន្ដែប្រើការដូចពពាយជ្រុងពុំកើតទេ ។

មួយស្រីពេស្យា បំពេញព្រហ្មចា- រីរួសអភិប្រាយ
អំពើទាំងបី ហៅពិសពុតញ្ញាយ សាធុសម្ដាយ
ចៀសកុំបីគ្រាប់ ។

២៥- ប្រាជ្ញពុំស្មើពុត បម្រើលំអុត ពុំស្មើក្ដីគាប់
មានគុណពុំស្មើ អ្នកមានបុណ្យភ័ព្វ ស្វែងរៀនរកច្បាប់
ពុំស្មើចិត្តជា ។

ស័ក្ដិពុំស្មើយស អ្នកមានរបស់ ពុំស្មើសក្កា
ស្ងួរបង់ធនធាន កុំខុសអាជ្ញា ស្ងួរមានរោគា
កុំឱ្យមើលងាយ ។

ស្ងួរសុំកុំយក គ្នាស្មើកុំរក ដូចបាវនិងនាយ
ខុសគាប់ស្ងួរអត់ កុំឱ្យព្រឆ្ងាយ ក្ដីសុខុមទាំងឡាយ
កុំខ្វាយស្ងួរស័ព្ទ ។

ធម៌នេះដំបូន្មាន រួមរក្សាប្រាណ ឱ្យមានក្ដីគាប់
ស្ងួរបង់ធនធាន កុំឱ្យខ្លួនស្លាប់ ស្ងួរស្លាប់គួរគាប់
រសធម៌កុំបីបង់ ។

បណ្ដាំមេបា អំបូរលោកថា ទុកតាមកំពង់
សំពៅតាមខ្យល់ ចង្កូតតម្រង់ មេលឹម[១]តែងត្រង់
ត្រីវិស័យជាមុខ ។

១- ទង់តូចសណ្ឋានកន្ទុយអន្ទង់ សម្រាប់ដាក់នៅចុងដងក្ដោង ឬនៅចុងដងទង់ ។

៣០- ដូចចិត្តប្តីជា ដូចមានភរិយា នៅផ្ទះស្រណុក
ដូចកូនទទួល យកពាក្យអាពុក ដូចខ្ញុំឱ្យមុខ
អម្ចាស់ប្រើហៅ ។

បណ្តាំមេបា អំបូរលោកថា ព្រេងព្រឹទ្ធប្រដៅ
ទើងធីប្រើរក ទើងស្វែងប្រើទៅ ទើងស្នេហ៍ប្រើហៅ
មិត្រមកជាមិត្រ ។

ពាក្យខុសកុំស្តាប់ ក្តីខុសកុំគ្រាប់ អ្នកកាចកុំផ្ចិត
លង់កុំស្រដី ខ្សត់កុំទុកចិត្ត ពោលាកុំផ្ចិត
ជាមិត្រមេត្រី ។

ប្រើថ្លឹងឱ្យស្មើ ទោះបីនឹងប្រើ ប្រើអ្នកចេះក្តី
កុំយកពាក្យស្លោក ផ្ទឹមនឹងគម្ពីរ កុំយកពាក្យជី
ផ្ទឹមនូវពាក្យពាល ។

មើលភ្នែកជញ្ជីង ក្នុងចិត្តឱ្យដឹង ណាធ្ងន់ណាស្រាល
កុំយកមណីរតន៍ មាសមានជាកាល ចិត្តកុំបណ្តាល
នូវបង់សីលធម៌ ។

៣៥- ប្រើដឹងតុលហាប ប្រើដឹងខ្ពស់ទាប មានភ្នែកយល់ល្អ
ទោះដឹងទឹកមាស ពុំចេរនៅថ្ម ទោះដឹងជីស
ពុំចេរសំបុត្រ ។

ធ្វើស្រែមើលស្មៅ សន្តានមើលផៅ បម្រើមើលពុត
ទោះដឹងពុតជា ពុំចេរពុតត្បុត ដឹងចិត្តបរិសុទ្ធ
ពុំចេរឥរិយា ។

ទេពីមើលក្រឹត្យ ក្សត្រាមើលឫទ្ធិ៍ ទាហានមើលចេស្តា
ជាងមើលអំពើ អំពីហត្ថា ទោះយកភរិយា
មើលនាលំនៅ ។

អសារក្តីបី បណ្តាំមេជី ព្រេងព្រឹទ្ធប្រដៅ
អង្គុរសសុទ្ធ ចម្អិនឱ្យឆៅ ពិសីហើយខ្លៅ
ប្រាជ្ញឥតមារយាទ ។

អ្នកបួសឥតក្រឹត្យ ចាស់ឥតប្រព្រឹត្ត ខ្សត់ច្រើនប្រមាទ
ភរិយាផុយផាយ ចាយវាយឥតខ្នាត ពពាលសុទ្ធសាធ
ប្រដៅក្របាន ។

៤០- ផ្ទះភ្លើងមានបី អំពើពុតស្រី ទឹងឥតប្រមាណ
កូនកាចចចេស ពុំដោយដំបូន្មាន ខ្ញុំកាចភៀសប្រាណ
កុំឱ្យម្ចាស់ប្រើ ។

ហោរាប្រើគូរ ភមូ[១]ប្រើមូល ស្ទង់ទឹកប្រើស្មើ
បន្ទាត់ប្រើត្រង់ ពលផ្ទង់គប្បីប្រើ ពុំហើយគប្បីធ្វើ
កុំលែងគប្បីភ្វា ។

១- ចិញ្ចើម, រោមចិញ្ចើម ។

ក្តីកោតមានបី កោតមួយពួកស្រី ស្រដីមាយា
កោតមួយពាក្យពិស អាស្រ្តូវជេរថា កោតមួយពាក្យពា-
លោលោភទុជ៌ន ។

ពិសពស់នានា កុយខ្លាយទន្តា កាលគត់ស្តាប់មន្ត
ត្រង់ពិសពាក្យពាល រោលរាលពុំស្រន់ សូម្បីអស់ជន្ម
ក្រមន្តបោសបាន ។

ហេតុនោះគួរគិត គួររិះរកហិត ថ្នាំពិសឱ្យស្រាន្ត
ដ៏លោកនេះគួរ រកអ្នកទ្រង់ញាណ សេពសាងសីលទាន
ជាថ្នាំលោកិយ ។

៥៤- វីថ្នាំបរលោក ចៀសចាកទុក្ខសោក បង់បញ្ចិន្ទ្រិយ
គប្បីផឹកសត្តតិង្ស- ពោធិបក្ខិយ អាចនាំដល់ត្រី-
ពិធសម្បត្តិសារ ។

ពិដោរផ្កាបី ពិដោរមេត្រី សួស្តីសីលាចារ
ពិដោរបរិសុទ្ធ កុសលសម្ភារ ពិដោរនេះដាល
ដល់សួគ៌ពុំស្បើយ ។

ពិដោរផ្កាបី ក្រៃលែងក្លិនភ្ញី ផតផងល្ហែល្ហើយ
ដោយខ្យល់ប្រាសខ្យល់ នៅត្រើយឆ្លងត្រើយ ពិដោរពុំស្បើយ
ហៅរសគន្ធា ។

ពិសាផ្លែប្រាំ ពិសាររសធម៌ ពិសាសត្យា
ពិសាសីលទាន ទ្រើសទ្រង់ករុណា ពិសាររសវា-
ចាចេញមធុរ ។

ពិសាផ្លែប្រាំ គិតជានាយនាំ ឥន្ទ្រិយទៅចូល
ត្រីពិធសម្បត្តិ ទិព្វរតន៍អនុកូល ចំណោរទៅចូល
មោក្ខមង្គាល័យ ។

៥០- ធម៌នេះជាច្បាប់ ប្រសើរមហាគាប់ ឧត្តមពេកក្រៃ
ក្រអ្នកណាបាន ប្រាជ្ញាឈ្លាសវៃ អាចដឹងដោយន័យ
រសធម៌គាថា ។

គួរចេះគួរចាំ គួរតាមបណ្ដាំ ទូលទុកសិរសា
ធម៌នេះស្មើក្បៀរ អម្រឹតធារា សម្ដេចភគវា
សាធុប្រោសប្រាណ ។

អ្នកណាបានស្ដាប់ អ្នកណាបានត្រាប់ អ្នកណាបានធ្យាន
រសធម៌នេះគាប់ ជាច្បាប់ទូន្មាន អ្នកនោះស្មើបាន
ដល់និព្វានហោង ៕

**(ចប់)**